# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ថុល សុជាតា**

**ក. សន សុខគីម**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឃឹម គីរី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Science Economiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ថុល សុជាតា**

**ក. សន សុខគីម**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឃឹម គីរី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ថុល សុជាតា** និងនាងខ្ញុំឈ្មោះ **សន សុខគីម** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមសម្ដែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុក **ពេជ្រ ចាន់ថុល** និងអ្នកម្ដាយ **ស្រី បុប្ផាជាតិ**

លោកឪពុក **មឿន ម៉ុនឆាង** និងអ្នកម្ដាយ **លឹម សុខហៀង**

កូនៗសូមថ្លែងអំណរអរព្រះគុណ និងអរគុណដល់លោកអ្នកមានគុណទាំងពីរដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀបប្រដៅ ព្រមទាំងបានលះបង់គ្រប់បែបយ៉ាង ទាំងពេលវេលា ទាំងកម្លាំងកាយចិត្ត បញ្ញាស្មារតី ផ្គត់ផ្គង់ និងលើកទឹកចិត្តគ្រប់បែបយ៉ាង តាំងពីកូនចាប់កំណើតមក រហូតដល់កូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៃថ្នាក់ឧត្ដមសិក្សា និងទទួលបានជោគជ័យគួរឲ្យមានមោទនៈ។ ដែលគុណនូបការៈ និងព្រហ្មវិហារធម៌របស់អ្នកមានគុណទាំងពីរចំពោះយើងជាកូនៗនេះពិតជាមានទំហំធំធេងដែលរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទាំងនេះហើយបានធ្វើឲ្យកូនៗចងចាំជានិច្ច គ្មានថ្ងៃបំភ្លេចបាន ហើយករុណាធិគុណនេះ និងស្ថិតនៅចិត្តកូនជារៀងរហូតគ្មានថ្ងៃបំភ្លេចឡើយ។

**ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការ លុយ ចន្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង រួមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយនូវកម្លាំងកាយចិត្តក្នុង ការបង្ហាត់បង្រៀន ផ្ដល់ជាឯកសារ ក៏ដូចជាដំណើរការនៃការសិក្សា និងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំផងដែរ។

លោកសាស្ត្រាចារ្យ **បណ្ឌិត ឃឹម គីរី** ដែលជាសាស្ត្រាចារ្យដឹកនាំផ្ទាល់ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ លោកបានណែនាំ បង្ហាត់បង្រៀន ផ្ដល់ដំបូន្មានល្អៗ និងលើកទឹកចិត្តដល់យើងខ្ញុំអោយខិតខំប្រឹងប្រែងក្នុងការសម្រេចកិច្ចការនេះ ព្រមទាំងចែករំលែកចំណេះដឹង បទពិសោធន៍ ដល់យើងខ្ញុំផងដែរ។ ពិសេសលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្ដល់នូវសេចក្ដីណែនាំ និងកែលម្អរាល់ចំណុចខ្វះខាតដែលកើតមានក្នុងដំណើរការនៃការធ្វើសារណានេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមជូនពរ និងបួងសួងវត្ថុសក្ដិសិទ្ធទាំងឡាយនៅក្នុងលោក សូមជួយតាមថែរក្សា លោកឪពុក អ្នកម្ដាយ លោកសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យ និងមិត្ត

ទាំងអស់ អោយជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ ព្រមទាំងសម្រេចនូវកិច្ចការទាំងអស់។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំកន្លងមក យើងខ្ញុំទាំងពីរមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើ នីតិកម្មសិទ្ធិបញ្ញា ជាពិសេសសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដោយហេតុថាបច្ចុប្បន្ននេះអ្នកនិពន្ធ ឬម្ចាស់ស្នាដៃកំពុងតែជួបប្រទះនូវការរំលោភបំពានសិទ្ធិ លើស្នាដៃរបស់ពួកគេ។ មូលហេតុដែលបណ្តាលមកពីប្រជាជនភាគច្រើនពុំទាន់បានយល់ដឹងពីសិទ្ធិទាំងនេះបានច្បាស់លាស់នៅឡើយទេ ម្យ៉ាងទៀត ឯកសារពាក់ព័ន្ធដើម្បីធ្វើការស្រាវជ្រាវពុំសូវមានច្រើន ដែលជាផលវិបាកក្នុងការរិះរកដំណោះស្រាយ។

ផលវិបាកទាំងនេះហើយដែលជំរុញឲ្យអ្នកសិក្សាមួយចំនួន រួមទាំងរូបខ្ញុំផ្ទាល់ពិបាកក្នុងការស្វែងយល់ពីបញ្ហាទាំងនេះ យើងខ្ញុំក៏សម្រេកចិត្តជ្រើសរើសយក ប្រធានបទមួយស្តីពី **ការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា** ដើម្បីធ្វើការស្រាវជ្រាវ និងចងក្រងឯកសារទាំងនេះឡើង។ តាមរយៈការខិតខំស្រាវជ្រាវមួយនេះសង្ឃឹមថា យើងខ្ញុំនឹងទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន និងចែករំលែកចំណេះដឹងទាំងនេះដល់មិត្តអ្នកអាន ក៏ដូចជានិស្សិតជំនាន់ក្រោយទៀត ដើម្បីជាចំណេះដឹងបន្ថែមផ្នែកច្បាប់ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញានេះ។

ការយល់ដឹងពីច្បាប់ គឺជាចំណុចមួយដ៏សំខាន់ដែលមនុស្សទូទៅគួរតែយល់ដឹងព្រោះវាបានជួយឲ្យយើងរួចផុតពីការរំលោភបំពាន ការឆបោក និងអំពើទុច្ចរិតផ្សេងៗ។ ប្រសិនបើ ប្រទេសមួយសម្បូរទៅដោយធនធានមនុស្សនាំឲ្យប្រទេសនោះមានភាពរីកចម្រើន និងអភិវឌ្ឍន៍។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមធ្វើការអភ័យទុកជាមុននូវរាល់កំហុសឆ្គងនានា រួមមានពាក្យពេចន៍ អក្ខរាវិរុទ្ធ និងចំណុចខ្វះខាតទាំងឡាយដែលកើតមានឡើងដោយអចេតនា ព្រោះតែការយល់ដឹង និងបទពិសោធន៍ផ្ទាល់របស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ យើងខ្ញុំរីករាយ និងទទួលនូវការរិះគុណក្នុងន័យស្ថាបនាពីលោក លោកស្រី ជាសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដើម្បីធ្វើឱ្យសារណាមួយនេះមានភាពល្អប្រសើរឡើង។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអានសារណាមួយនេះពីដើមរហូតដល់ចប់។

# បញ្ជីពាក្យកាត់

| | |
|---|---|
| AFD | Agnese Françoise de Development<br>ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ |
| IP | Intellectual Property<br>កម្មសិទ្ធិបញ្ញា |
| IPR | Intellectual Property Rights<br>សិទ្ធិកម្មសិទ្ធិបញ្ញា |
| WTO | World Trade Organization<br>អង្គការពាណិជ្ជកម្មពិភពលោក |
| WIPO | World Intellectual Property Organization<br>អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| TRIPS | Agreement on Trade-Related Aspects of Intellectual Property Rights<br>កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញា |

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..........១

## ជំពូកទី ១
## សញ្ញាណទូទៅ

**១.១ អ្វីទៅជាកម្មសិទ្ធិបញ្ញា** ..........៤

១.១.១ និយមន័យ ..........៤

១.១.២ ប្រភេទនៃកម្មសិទ្ធិបញ្ញា..........៥

១.១.៣ គោលបំណងនៃការបង្កើតនីតិកម្មសិទ្ធិបញ្ញា ..........៨

**១.២ ប្រវត្តិនៃការកកើតនីតិកម្មសិទ្ធិបញ្ញានៅកម្ពុជា** ..........៨

១.២.១ ទីតាំងរបស់នីតិកម្មសិទ្ធបញ្ញា..........១១

១.២.២ គណកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ..........១១

១.២.៣ ក្រសួងពាក់ព័ន្ធក្នុងការរៀបចំច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា..........១៣

## ជំពូកទី ២
## ការការពារសិទ្ធិអ្នកនិពន្ធ

**២.១ សញ្ញាណគតិយុត្ត**..........១៦

២.១.១ និយមន័យ..........១៦

២.១.២ ការកំណត់ឋានៈជាអ្នកនិពន្ធ ..........១៦

២.១.៣ ស្នាដៃដែលទទួលបាននូវការការពារ ..........១៨

**២.២ លក្ខខណ្ឌដើម្បីទទួលបាននូវកិច្ចការពារ** ..........១៩

២.២.១ ស្នាដៃដើម ..........១៩

២.២.២ លក្ខខណ្ឌគ្រឹះ..........២០

២.២.៣ លក្ខខណ្ឌទម្រង់..........២២

**២.៣ សិទ្ធិ និងប្រយោជន៍ដែលទទួលបាន**..........២៤

២.៣.១ សិទ្ធិដែលទទួលបាន ........ ២៤
២.៣.២ ផលប្រយោជន៍ដែលទទួលបាន ........ ២៧
២.៣.៣ រយៈពេលនៃការការពារ ........ ២៨
២.៣.៤ វិធានប្រឆាំងការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ........ ២៩
**ជំពូកទី ៣**
**ការការពារសិទ្ធិប្រហាក់ប្រហែល**
**៣.១ សញ្ញាណគតិយុត្ត** ........ ៣៥
៣.១.១ និយមន័យ ........ ៣៥
៣.១.២ ប្រធាននៃសិទ្ធប្រហាក់ប្រហែល ........ ៣៥
៣.១.៣ ស្នាដៃដែទទួលបាននូវការការពារ ........ ៣៨
**៣.២ លក្ខខណ្ឌដើម្បីទទួលបាននូវការការពារ** ........ ៣៨
៣.២.១ លក្ខខណ្ឌគ្រឹះ ........ ៣៨
៣.២.២ លក្ខខណ្ឌទម្រង់ ........ ៣៩
**៣.៣ សិទ្ធិ និងប្រយោជន៍ដែលទទួលបាន** ........ ៣៩
៣.៣.១ សិទ្ធិដែលទទួលបាន ........ ៣៩
៣.៣.២ ផលប្រយោជន៍ដែលទទួលបាន ........ ៤២
៣.៣.៣ រយៈពេលនៃការការពារ ........ ៤២
៣.៣.៤ វិធានការប្រឆាំងការរំលោភបំពានសិទ្ធិប្រហាក់ប្រហែល ........ ៤៣
**សេចក្ដីសន្និដ្ឋាន** ........ ៤៥
**អនុសាសន៍** ........ ៤៧
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ដោយសង្កេតឃើញថាការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចពិភពលោកកំពុងមានសន្ទុះ នាពេលបច្ចុប្បន្ន នេះ និងទៅពេលអនាគត ទន្ទឹមនឹងភាពរីកចម្រើននេះដែរក៏មានយន្តការរបស់ អង្គការអន្តរជាតិច្រើន ដែលផ្តោតលើបញ្ហានេះ ដូចជាអង្គការពាណិជ្ជកម្មពិភពលោក(WTO) ដែលមានគោលដៅបង្កើតឱ្យ បាននូវបែបបទ នៃការប្រកួតប្រជែងនៅក្នុងទីផ្សារសេរី ក៏ដូចជាជំរុញនូវការអនុវត្ត ច្បាប់ស្តីពីកម្មសិទ្ធិ បញ្ញាផងដែរ។ នៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះបច្ចេកវិទ្យាក៏មានការរីកលូតលាស់ដែរ បច្ចេកទេសទាំងនោះកើតឡើងពី ការច្នៃប្រឌិត និងការប្រកួតប្រជែង របស់មនុស្ស ដូច្នេះអ្វីដែលគួរឱ្យ យកចិត្តទុកដាក់បន្ថែមទៀតនោះ គឺបញ្ហានៃការការពារកម្មសិទ្ធិបញ្ញា និងសិទ្ធិប្រហាក់ប្រហែល។ ប្រទេសជាច្រើននៅ លើពិភពលោកកំពុងតែយកចិត្តទុកដាក់ ដោយគេបានបង្កើតស្ថាប័នមួយដែល ផ្តោតទៅលើកការយកចិត្តទុកដាក់ និងជំរុញដល់ការអនុវត្តន៍កម្មសិទ្ធបញ្ញានោះ គឺអង្គការកម្មសិទ្ធិ បញ្ញាពិភពលោកដែលហៅកាត់ថា WIPO ។

កម្មសិទ្ធិបញ្ញា ជាសិទ្ធិតាមផ្លូវច្បាប់ដែលកើតចេញពីសកម្មភាពបញ្ញារបស់មនុស្ស នៅក្នុង វិស័យឧស្សាហកម្ម វិទ្យាស្សស្រ្ត អក្សរសាស្ត្រ និងសិល្បៈ ជាដើម។ ចំពោះ ការសិក្សាទៅលើសិទ្ធិអ្នក និពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជាយើង ក៏មានសារៈសំខាន់ណាស់ចំពោះ និស្សិតខ្មែរគ្រប់រូប និងអ្នកអនុវត្តច្បាប់ទាំងអស់ ដែលត្រូវតែយល់ដឹងថាអ្វីទៅ ជាសិទ្ធិអ្នកនិពន្ធ នៅ កម្ពុជា ទើបអាចថែរក្សាតម្លៃអ្នកនិពន្ធ និងលើកកម្ពស់លើការសិក្សាស្រាវជ្រាវព្រមទាំងធ្វើឱ្យប្រទេស ជាតិមានការរីកចម្រើនទៅមុខ។

ប្រទេសមួយអាចមានការរីកចម្រើនបាន លុះត្រាតែមានអ្នកនិពន្ធ និងអ្នកសិក្សាស្រាវជ្រាវ ច្រើន ហើយថែរក្សាតម្លៃស្នាដៃរបស់អ្នកនិពន្ធ និងស្នាដៃប្រហាក់ប្រហែល ទាំងអស់នោះឱ្យបានគង់វង្ស ជៀសផុតពីការលួចចម្លងស្នាដៃដោយខុសច្បាប់។

សិទ្ធិអ្នកនិពន្ធ សំដៅទៅលើស្នាដៃដែលទាក់ទងទៅនឹងការបង្កើតថ្មី ដែលកើតចេញពីគំនិត របស់បុគ្គលម្នាក់ ឬច្រើននាក់ដែលរួមគ្នា ដើម្បីបង្កើតនូវស្នាដៃដែលរួមមាន៖ អក្សរសាស្ត្រ សិល្បៈ តូរ្យតន្ត្រី នាដកម្ម និងស្នាដៃអេឡិចត្រូនិច។ អ្នកនិពន្ធស្នាដៃ ជាអ្នកទទួលបាននូវសិទ្ធិ ជាម្ចាស់កម្ម សិទ្ធិផ្តាច់មុខលើស្នាដៃនោះហើយ ជាសិទ្ធិដែលច្បាប់ទទួលស្គាល់។ សិទ្ធិនេះរួមមាន សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។ អ្នកនិពន្ធ មានសិទ្ធិប្រើប្រាស់ស្នាដៃរបស់ខ្លួន ឬអនុញ្ញាតឱ្យគេប្រើប្រាស់នូវស្នាដៃ ជំនួសខ្លួនបាន។ តតិយជន អាចប្រើប្រាស់ស្នាដៃរបស់អ្នកនិពន្ធ បានលុះណាតែមានការអនុញ្ញាតពី អ្នកនិពន្ធជាមុនសិន។ ការប្រើប្រាស់ស្នាដៃនេះ ត្រូវបានធ្វើឡើងក្រោមរូបភាព ដូចមានចែងក្នុង ច្បាប់

ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺការផលិតឡើងវិញ និងការផ្សាយឡើងជា សាធារណៈ និងការបង្កើតស្នាដៃបន្ត។

សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ គឺជាសិទ្ធិមួយដែលអាចផ្ទេរបាន និងស្តែងឡើងក្រោមរូបភាពច្រើនយ៉ាងរួមមាន ការផ្ទេរតាមរយៈកិច្ចសន្យាជាដើម។ ម៉្យាងវិញទៀត សិទ្ធិនេះជាសិទ្ធិដែលមានអាជ្ញាយុកាលកំណត់ក្នុងការទទួលបាននូវការការពារ។ លើសពីនេះទៅទៀត ការធ្វើអាជីវកម្មលើសិទ្ធិបេតិកភណ្ឌ នៃអ្នកនិពន្ធត្រូវបានច្បាប់កម្រិត ដើម្បីជៀសវាងការរំលោភសិទ្ធិ។

នៅក្នុងសង្គមខ្មែរ នាពេលបច្ចុប្បន្ននេះ ការប្រកបរបរជាអ្នកនិពន្ធតែម៉្យាង គឺមិនអាចផ្គត់ផ្គង់ជីវភាពរស់នៅបានគ្រប់គ្រាន់ ឬក៏មានជីវភាពធូរធារបាននោះទេប៉ុន្តែអ្វីដែល ជាកត្តាចម្បងក្នុងការជំរុញឱ្យកវីនិពន្ធទាំងឡាយ នៅតែបន្តការសរសេររបស់ខ្លួននោះ គឺជាទឹកចិត្តមួយដែលស្រលាញ់វប្បធម៌ អរិយធម៌ជាតិ របស់អ្នកនិពន្ធទាំងនោះ។ ដូច្នេះ ហើយទឹកចិត្តរបស់កវីនិពន្ធ ពិតជាមានអត្ថន័យជ្រាលជ្រៅបំផុត និងមានគុណនុបការៈធំធេងណាស់ ដល់ប្រទេសជាតិ ដែលមនុស្សគ្រប់រូបត្រូវយកចិត្តទុកដាក់ និងគោរពកោតសរសើរ។ ជាក់ស្តែង នៅពេលបច្ចុប្បន្ននេះ អ្វីដែលអ្នកនិពន្ធទទួលបាននោះ គឺការព្រួយបារម្ភ និងសេចក្តីសោកស្តាយ ចំពោះស្នាដៃរបស់ខ្លួនដែលខំបង្កើតឡើងតែត្រូវបានជនខិលខូចមួយចំនួនលួចយកទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ហើយពីមួយថ្ងៃទៅមួយថ្ងៃការបាក់ទឹកចិត្តបានបណ្តាលឲ្យអ្នកនិពន្ធជាច្រើនបានបោះបង់ចោលការតែងនិពន្ធរបស់ខ្លួន ឬអ្នកដែលមានចំណេះដឹងជ្រៅជ្រះលើផ្នែកនេះ លែងហ៊ានចង់ចងក្រងតាក់តែងជាស្នាដៃរបស់ខ្លួន ដូចជាអត្ថបទសិក្សា តន្ត្រី ទំនុកភ្លេង ទំនុកបទចំរៀង ជាដើម។

កត្តាដែលបង្ក ជាការបាក់ទឹកចិត្តដល់អ្នកនិពន្ធភាគច្រើននោះ គឺ"ការរំលោភបំពានសិទ្ធអ្នកនិពន្ធ"។ តើការរំលោពបំពានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជាបានស្តែងឡើងតាមរយៈសកម្មភាពបែបណា? ការរំលោភបំពានលើសិទ្ធអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា បានស្តែងឡើងតាមរយៈសកម្មភាពមួយចំនួនដូចជា ការថតចម្លង ការយកគំរូ យកលំនាំតាម ឬការយកទៅច្នៃធ្វើជាស្នាដៃរបស់ខ្លួនដោយមិនមានការអនុញ្ញាតពីអ្នកនិពន្ធ។ ទង្វើអសីលធម៌បែបនេះហើយ បានបង្កជាផលប៉ះពាល់យ៉ាងខ្លាំង ដល់អ្នកនិពន្ធភាគច្រើន និងការរីកចម្រើនរបស់ប្រទេសជាតិ ពីព្រោះអ្នកនិពន្ធត្រូវបាត់បង់ផលកម្រៃពីស្នាដៃរបស់ខ្លួន បាត់បង់កេរ្តិ៍ឈ្មោះ ដែលជះឥទ្ធិពលយ៉ាងខ្លាំង ដល់ស្ថានភាពរស់នៅរបស់ពួកគេ ជាពិសេស គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះអ្នកនិពន្ធ ណាដែលយកការតែងនិពន្ធ ជាអាជីពតែមួយរបស់ខ្លួន។ ហើយអ្វី

ដែលខាតបង់ធំបំផុតរបស់ប្រទេសជាតិនោះ គឺលែងមានអ្នកនិពន្ធដែលខិតខំស្រាវជ្រាវនូវស្នាដៃថ្មីៗ ឬការបង្កើតអ្វីដែលថ្មីសម្រាប់ប្រទេសជាតិ និងមនុស្សជំនាន់ក្រោយ។

ដើម្បីការពារសិទ្ធអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្ដីព្រាងច្បាប់ស្ដីពី "សិទ្ធអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល" តាមសំណើររបស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដាក់ជូនរដ្ឋសភាអនុម័ត និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣។

គោលបំណងនៃកិច្ចសិក្សាស្រាវជ្រាវលើប្រធានបទ **ការការពារសិទ្ធអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅកម្ពុជា** ដើម្បីស្វែងយល់ឲ្យបានកាន់តែច្បាស់ពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា និងដើម្បីឲ្យសិស្សនិស្សិតគ្រប់រូបបានយល់ដឹង និងចូលរួមគោរពសិទ្ធិអ្នកនិពន្ធ រួមទាំងការពារនូវ ផលិតផលវប្បធម៌ ស្នាដៃនិពន្ធ អ្នកសម្ដែង ផលិតករ ជាអាទ៍។ ចំពោះការសិក្សាអំពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នេះត្រូវបានពឹងផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលចេញដោយ ក្រសួងស្ថាប័នពាក់ព័ន្ធ សៀវភៅអាន និងឯកសារជាច្រើនផ្សេងៗទៀតព្រមទាំងបានរំលេចនូវស្ថានភាព ជាក់ស្ដែងដែលកើតឡើងក្នុងសង្គមខ្មែរបច្ចុប្បន្ន។

សារណាបញ្ចប់ការសិក្សានេះនឹងអាចចូលរួមចំណែកក្នុងការផ្ដល់ជាចំណេះដឹងបន្ថែទាក់ទងនឹងការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា ដែលបានអនុលោមតាមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ ក៏ដូចជាបានចូលរួមចំណែកលើកស្ទួយដល់ការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដើម្បីកាត់បន្ថយការរំលោភសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា។

តើអ្វីទៅជាសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល? តើស្នាដៃអ្វីខ្លះដែលត្រូវទទួលបានការការពារពីច្បាប់? សំណួរទាំងនេះនឹងត្រូវបានស្រាយបំភ្លឺនៅក្នុងប្រធានបទស្ដីពី **ការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅកម្ពុជា** ដែលនឹងត្រូវធ្វើការបង្ហាញនៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ។

# ជំពូកទី ១
# សញ្ញាណទូទៅ

# ជំពូកទី ១
# សញ្ញាណទូទៅ

## ១.១ អ្វីទៅជាកម្មសិទ្ធិបញ្ញា

### ១.១.១ និយមន័យ

**កម្មសិទ្ធិបញ្ញា** សំដៅទៅដល់ការច្នៃប្រឌិតដែលកើតចេញពីគំនិតបញ្ញារបស់មនុស្ស ដែលមានដូចជា ការបង្កើតស្នាដៃផ្នែកអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ការបង្កើតថ្មី ម៉ាក និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ជាអាទ៍។[1]

**តាមន័យទូលាយ** ពាក្យថា "កម្មសិទ្ធិបញ្ញា" គឺចង់សំដៅទៅដល់សិទ្ធិតាមផ្លូវច្បាប់ដែលកើតចេញពីបញ្ញារបស់មនុស្សក្នុង វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ។

ហើយមូលហេតុ ចម្បងដែលជម្រុញអោយប្រទេសភាគច្រើននៅលើពិភពលោកបង្កើតឲ្យមានច្បាប់ស្តីពីកម្មសិទ្ធិបញ្ញានេះ គឺក្នុងគោលបំណងដើម្បី៖[2]

- ផ្តល់នូវសិទ្ធិផ្នែកសីលធម៌ និងសិទ្ធិផ្នែកសេដ្ឋកិច្ចអោយទៅដល់អ្នកបង្កើតស្នាដៃថ្មី និងជាការផ្តល់សិទ្ធិអោយដល់សាធារណៈជន ដើម្បីទទួលបាននូវសិទ្ធិ ក្នុងការប្រើប្រាស់នូវស្នាដៃដែលបង្កើតថ្មីទាំងនោះ
- ជាគោលនយោបាយរបស់រដ្ឋ ដើម្បីលើកទឹកចិត្តដល់សកម្មភាព នៃការបង្កើតនូវស្នាដៃថ្មី និងជម្រុញឲ្យមានភាពស្មើគ្នាក្នុងការធ្វើពាណិជ្ជកម្ម ជាពិសេសជួយលើកតម្កើង ដល់ការអភិវឌ្ឍន៍ធនធានមនុស្ស សង្គម និងសេដ្ឋកិច្ចជាតិ។

និយាយជារួម ការបង្កើតឲ្យមានច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា គឺក្នុងគោលបំណងការពារដល់អ្នកបង្កើតថ្មី អ្នកផលិត អ្នកច្នៃប្រឌិតថ្មី និងជាពិសេសធ្វើការការពារសិទ្ធិរបស់អ្នកទាំងនោះ នៅក្នុងរយៈពេលមួយដែលកំណត់ជាក់លាក់ ដើម្បីងាយស្រួលធ្វើការគ្រប់គ្រង ប្រើប្រាស់ដែលកើតចេញពីបញ្ញាផលិតផលបញ្ញារបស់ពួកគាត់។ ដែលសិទ្ធិទាំងនេះមិនបានរាប់បញ្ចូលនូវកម្លាំងពលកម្មដែលភ្ជាប់ជាមួយនឹងការបង្កើតថ្មីទាំងនោះទេ តែវាត្រូវបានជំនួសមកវិញដោយការបង្កើតដោយកម្លាំងបញ្ញា។

---

[1] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញាឆ្នាំ២០០៩ ទំព័រទី២( សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី )

[2] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញាឆ្នាំ២០០៩ ទំព័រទី២( សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី )

កម្មសិទ្ធិបញ្ញា បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនចំពោះ វិស័យសេដ្ឋកិច្ច ជាពិសេស គឺជួយជម្រុញដល់ ការបង្កើតថ្មី នវានុវត្តន៍[3] និងទំនើបកម្មលើវិស័យផ្សេងៗទៀត។

### ១.១.២ ប្រភេទនៃកម្មសិទ្ធិបញ្ញា

កម្មសិទ្ធិបញ្ញា ត្រូវបានបែងចែកជាពីរផ្នែកធំៗ ដែលមានដូចជា កម្មសិទ្ធិឧស្សាហកម្ម និងកម្មសិទ្ធិអ្នកនិពន្ធ។

នៅក្នុងកម្មសិទ្ធិឧស្សាហកម្មនេះមានដូចជា៖

- តក្កកម្ម ជាស្នាដៃដែលបានបង្កើតថ្មី និងត្រូវបានទទួលការការពារដោយ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- គំនូរឧស្សាហកម្ម តាមន័យទូទៅ គឺជាសកម្មភាពមួយដែលប្រកបទៅដោយការច្នៃប្រឌិតនៃការបង្កើត ឬជាសកម្មភាពនៃការតាក់តែងឲ្យចេញនូវរូបរាងសម្រាប់វត្ថុជាតុដែលគេផលិតចេញមក ហើយបំពេញតម្រូវការសម្រាប់ការមើលឃើញវត្ថុនោះដោយភ្នែកទទេ ឬសំដៅទៅលើសិទ្ធិដែលគេបានផ្តល់ឲ្យទៅតាមប្រព័ន្ធនៃការចុះបញ្ជី ដើម្បីការពារនូវប្រភពដើមដែលបានបង្កើតឡើងនោះ។
- ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយវាអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗបាន។ ម៉ាកដែលប្រើប្រាស់ម្រាប់ទំនិញហៅថា "**ពាណិជ្ជសញ្ញា**" ហើយម៉ាកដែលប្រើប្រាស់សម្រាប់សេវា ហៅថា "**សេវាសញ្ញា**"។[4] ម៉ាកមានច្រើនរូបភាពច្រើន ដូចជា:
    - **ពាក្យ** (Words) មានន័យថាពាក្យក៏អាចបង្កើតជាម៉ាកបានផងដែរ តែពាក្យទាំងនោះមិនត្រូវមានន័យមិនល្អ ឬធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កេរ៏ឈ្មោះ ឬកិត្តិយសរបស់អ្នកដ៏ទៃឡើយ។[5] ឧទាហរណ៍៖ កូកា-កូឡា

[3] នវានុវត្តន៍ គឺជាការច្នៃប្រឌិត ឬការបង្កើតគំនិតថ្មី ដែលភាគច្រើនពាក់ព័ន្ធទៅនឹងបច្ចេកវិទ្យា វិទ្យាសាស្ត្រ ឬ ព័ត៌មានវិទ្យាជាដើម ។ ដោយឡែក បើក្នុងបរិបទនៃអាជីវកម្មវិញ មិនមែនសំដៅសុទ្ធតែការផ្សារភ្ជាប់ទៅនឹងបច្ចេកវិទ្យានោះទេ ប៉ុន្តែការរកឃើញនូវរបៀបគ្រប់គ្រង ប្រព័ន្ធគ្រប់គ្រង ឬអ្វីដែលថ្មីដោយមិនចាំបាច់ផ្សារភ្ជាប់ទៅនឹងបច្ចេកវិទ្យាក៏អាចនិយាយបានថាជា នវានុវត្តន៍បានផងដែរ។

[4] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[5] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញាឆ្នាំ២០០៩ ទំព័រទី៥១(សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី)

- **អក្សរ** (Latter) មានន័យថាអក្សរដែលអាចបង្កើត ជាម៉ាកបានលុះត្រាតែអក្សរដែលយកទៅប្រើជាម៉ាកនោះ មានការរចនា ពីរូបរាងទូទៅនៃអក្សរនោះ និងជាពិសេសអក្សរដែលយកទៅប្រើនោះដាច់ខាត ត្រូវតែខុសពីតួអក្សរដែលមានស្រាប់នៅក្នុងតួអក្សរនៃម៉ាស៊ីនកុំព្យូទ័រ។[6] ឧទាហរណ៍៖ LG
- **លេខ** (Numeral) មានន័យថាលេខអាចបង្កើត ជាម៉ាកបានដូចគ្នានឹងអក្សរ និងមានលក្ខខណ្ឌរបស់វាពុំមានអ្វីខុសគ្នា ពីម៉ាកដែលបង្កើតឡើងដោយអក្សរដែរ គឺត្រូវតែជាលេខដែលត្រូវបានគេធ្វើការរចនាឡើង ដូចជា កាវ502 ទឹកក្រូច7UP ជាដើម។[7]
- **រូបសញ្ញា** (Logos) គឺជារូបភាពមួយប្លែក ដែលមានលក្ខណៈពិសេសបង្កប់នូវអត្ថន័យរបស់ផលិតផល ឬក៏ជាសញ្ញាសម្គាល់អ្វីមួយដែលដាក់នៅលើទំនិញ ឬសេវា ដូចជា៖ Burberry, Nestle ជាដើម។[8]
- **និមិត្តសញ្ញា** (Devices) គឺជាសញ្ញាដែលមានក្បូរក្បាច់ មានរូបតំណាង ឬអាចជាការផ្គុំបញ្ចូលគ្នាជាឡូហ្គូ លេខ អក្សរ ជាដើម។[9]
- **ស្លាកសញ្ញា** (Labels) មានប្រភេទខុសៗគ្នាអាចជាក្រដាស ផ្លាស្ទិក ក្រណាត់ អំបោះសូត្រ ដែលនៅលើស្លាកសញ្ញានោះអាចមានអក្សរ ឬឡូហ្គូ។[10]
- **ការរួមបញ្ចូលគ្នានៃពាក្យ** អាចជាអក្សរ លេខ និមិត្តសញ្ញា ស្លាកសញ្ញា ឈ្មោះ និងហត្ថលេខា។[11]
- **ពណ៌** អាចជាពណ៌ ឬពណ៌ច្រើនចម្រុះគ្នា ឬពណ៌ដែលប្រើមានបែបផែនត្រឹមត្រូវ ហើយមិនអាចលាយបានដោយងាយ មានន័យថា ជាពណ៌ដែលម្ចាស់ម៉ាកអាចប្រើផ្ដាច់មុខបាន ហើយពណ៌នោះត្រូវតែមានការច្នៃប្រឌិត មានភាពពិតប្រាកដ ដែលវាបានបង្ហាញនូវសារៈសំខាន់ចំពោះពាណិជ្ជនាម។[12]

---

[6] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០០៩ ទំព័រទី៥០(សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី)

[7] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០០៩ ទំព័រទី៥០(សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី)

[8] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦០(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណវ័ត្ន )

[9] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦០(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណវ័ត្ន)

[10] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦១(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណវ័ត្ន)

[11] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦១(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណវ័ត្ន)

[12] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦១សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណវ័ត្ន)

- **ឈ្មោះ** (Name)
- **ហត្ថលេខា** (Signatures)
- **ទម្រង់បីខ្នាត** ឬសញ្ញាដែលអាចមើលធ្លុះបីជ្រុង អាចជារូបរាងនៃទំនិញ ឬជាការវេចខ្ចប់របស់ទំនិញ[13]
- **សញ្ញាសំលេង** (Audible Marks) អាចជាបទភ្លេង ឬអ្វីដែលថតបាន ឬក៏ជានិមិត្តសញ្ញា។[14] ឧទាហរណ៍៖ ការយំរបស់សត្វ ឬសំលេងទឹកហូរជាដើម
- **សញ្ញាក្លិន** (Factory Mark) ដែលជាក្លិននៃផលិតផល ដូចជា ផលិតផលទឹកអប់របស់ប្រទេសណាមួយ[15]

- ម៉ាកត្រូវបានការពារដោយ ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។
- ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រទំនិញ ឬម៉ាកសម្គាល់ប្រភពដើមនៃទំនិញ សំដៅដល់ឈ្មោះសញ្ញាសម្គាល់ ឬរូបភាពផ្សេងៗទៀតដែលមានលក្ខណៈញែកដាច់ ដែលជាឈ្មោះ ឬតំណាងឲ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយ ហើយឈ្មោះសញ្ញាសម្គាល់ ឬរូបភាពនោះ សម្រាប់កំណត់អត្តសញ្ញាណ ទំនិញមានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្តល់ជាដល់មូលដ្ឋានគ្រឹះដល់គុណភាព កិត្តិស័ព្ទ ឬចរិកលក្ខណៈផ្សេងៗទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ។[16] ឧទាហរណ៍ ម្រេចរតនៈគិរី
- អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ជាអំពើនៃការប្រកួតប្រជែងណា ដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងទាត់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ មានដូចជា ការបង្កើតឲ្យមានការភាន់ច្រឡំ ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ និងការបញ្ឆោក់ឬ ការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ដែលធ្វើឲ្យមានការយល់ច្រឡំ
- ការបង្កើតថ្មី ការច្នៃប្រឌិតថ្មី។

---

[13] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦១(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណរ័ត្ន)

[14] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦១(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណរ័ត្ន)

[15] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី៦២(សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណរ័ត្ន)

[16] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០០៩ ទំព័រទី៤៧(សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី)

កម្មសិទ្ធិអ្នកនិពន្ធ ត្រូវបានរាប់បញ្ចូលនូវសិទ្ធិដូចជាមាន សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ សិទ្ធិអ្នកនិពន្ធរួមមាន ស្នាដៃអក្សរសាស្ត្រ ដូចជាការសរសេរអត្ថបទ ការនិពន្ធសៀវភៅ ការតាក់តែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ការសរសេរអត្ថបទបឋកថា សង្កថា ធម្មទេសនា ជាដើម។ ចំណែកឯ សិទ្ធិប្រហាក់ប្រហែលរួមមាន សកម្មភាពនៃការសម្តែង ដូចជាការសម្តែងភាពយន្ត ការសម្តែងសៀក ការសម្តែងកាយវិការ ការរាំ ការច្រៀង សិល្បៈករ ភាពយន្ត និងបណ្តាញទូរផ្សាយ ជាអាទ៍។

### ១.១.៣ គោលបំណងនៃការបង្កើតនីតិកម្មសិទ្ធិបញ្ញា

ការបង្កើតច្បាប់ស្តីពីកម្មសិទ្ធិបញ្ញានេះ ត្រូវបានបង្កើតឡើងនៅ ក្នុងគោលបំណងដូចខាងក្រោម៖

- ការពារអ្នកបង្កើតថ្មីអ្នកផលិត អ្នកច្នៃប្រឌិតថ្មី ជាពិសេសការពារដល់សិទ្ធិអ្នកទាំងនោះក្នុងរយៈពេលមួយជាក់លាក់ដើម្បីធ្វើការគ្រប់គ្រង ប្រើប្រាស់ដែលកើតចេញពីផលិតផលបញ្ញារបស់ពួកគាត់។ សិទ្ធិទាំងនោះមិនរាប់បញ្ចូលនូវកម្លាំងពលកម្មដែលភ្ជាប់ជាមួយនឹង ការបង្កើតថ្មីទាំងនោះ តែវាត្រូវបានជំនួសមកវិញដោយការបង្កើតដោយកម្លាំងបញ្ញា។[17]
- ធានាការគោរពសិទ្ធិ និងការពារនូវស្នាដៃរបស់ម្ចាស់ស្នាដៃ
- ធានាការធ្វើអាជីវកម្មត្រឹមត្រូវស្របច្បាប់ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ
- លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី ចំពោះការស្រាវជ្រាវការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ជំរុញនិងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស និងការវិនិយោគ
- លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

## ១.២ ប្រវត្តិនៃការកើតនីតិកម្មសិទ្ធិបញ្ញានៅកម្ពុជា

កម្មសិទ្ធិបញ្ញាបានកើតមានឡើង និងត្រូវបានទទួលការការពារដោយច្បាប់ជាយូរណាស់មកហើយ។ ជាពិសេស សិទ្ធិនេះទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងកំឡុងបដិវត្តឧស្សាហ៍កម្ម តាមរយៈវត្តមាននៃកិច្ចព្រមព្រៀងអន្តរជាតិធំៗចំនួនពីរ គឺអនុសញ្ញាទីក្រុង Paris ឆ្នាំ១៨៨៣ និងអនុសញ្ញាទីក្រុង Berne ឆ្នាំ១៨៨៦ ហើយបានបន្តឥទ្ធិពលរបស់ខ្លួនរហូតមកដល់បច្ចុប្បន្ន។

[17] ឯកសារមេរៀននីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០០៩ ទំព័រទី២(សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី)

ព្រះរាជាណាចក្រកម្ពុជាយើង បានចូលជាសមាជិក អង្គការកម្មសិទ្ធិបញ្ញា នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ បន្ទាប់ពីបានចូលជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោករួចមក ព្រះរាជាណាចក្រកម្ពុជាយើង ក៏បានបន្តចូលជាសមាជិកនៃអនុសញ្ញានៃទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៨។ បន្ទាប់ពីបានមើលឃើញពីការវិវត្តន៍សេដ្ឋកិច្ចជាសកលរួចមក ព្រះរាជាណាចក្រកម្ពុជាយើងក៏បានបន្តចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក ដែលក្នុងនោះមានកិច្ចព្រមព្រៀងទ្រីឌ ជាកិច្ចព្រមព្រៀងមួយដែលដាក់លក្ខខណ្ឌដល់ការការពារកម្មសិទ្ធិបញ្ញា ក៏ព្រោះតែកម្ពុជាយើងបាន និងកំពុងចាប់ផ្តើមកសាងនីតិកម្មសិទ្ធិបញ្ញារបស់ខ្លួន ដោយការស្នើរសុំចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក(WIPO)[18]បន្ទាប់ពីបានក្លាយជាសមាជិករបស់សមាគមអាស៊ានរួច។[19] សម្រាប់កម្ពុជាយើង វត្តមាននៃនីតិកម្មសិទ្ធិបញ្ញាត្រូវបានមើលឃើញថាជាលក្ខខណ្ឌចាំបាច់ដែលមិនអាចខ្វះបាន ទាំងសម្រាប់ការបើកចំហរទីផ្សារទៅកាន់ពិភពលោក ឧទា.៖ ការចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក និងសម្រាប់ការទាក់ទាញវិនិយោគ បរទេសឲ្យចូលមកកម្ពុជាផងដែរ។ នៅក្នុងការកសាងនីតិថ្មីមួយនេះ កម្ពុជាបានទទួលជំនួយបច្ចេកទេសពីជំនាញការបារាំង ជាពិសេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដែលកម្ពុជាបានចូលជាសមាជិក។ ជាលទ្ធផល ច្បាប់កម្មសិទ្ធិបញ្ញា ចំនួនប្រាំត្រូវបានអនុម័តរួចរាល់ជាស្ថាពរ និងជាបន្តបន្ទាប់គ្នាដោយមានការជម្រុញរបស់ក្រសួងមានសមត្ថកិច្ចទៅតាមជំនាញដោយឡែកៗពីគ្នា រួមមាន ៖

- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់ក្រសួងពាណិជ្ជកម្ម
- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

[18] កម្ពុជាបានចូលជាសមាជិកទី១៤៨ នៃអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ខែតុលាឆ្នាំ២០០៤

[19] កម្ពុជាបានចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងរួម នៃប្រជាជាតិអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យកម្មសិទ្ធិបញ្ញាចុះថ្ងៃទី៣០ខែមេសាឆ្នាំ១៩៩៩

- ច្បាប់ស្តីពីការបង្កាត់ និងគ្រប់គ្រងពូជដំណាំ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ក្រសួងកសិកម្ម និងរុក្ខាប្រម៉ាញ់ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[20] (នៅក្រោមជំនួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ហៅកាត់ថា AFD) និងកំពុងរៀបចំបង្កើតឡើងជាច្រើនទៀតផងដែរ។

[20]ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នេះទើបនឹងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ *នស/រកម/០១១៤/០០៦* ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

### ១.២.១ ទីតាំងរបស់នីតិកម្មសិទ្ធបញ្ញា

ដើម្បីងាយស្រួលយល់ឲ្យបានកាន់តែច្បាស់ពីនីតិកម្មសិទ្ធិបញ្ញា គឺត្រូវដឹងជាមុនអំពីទីតាំងរបស់នីតិកម្មសិទ្ធិបញ្ញាជាមុនសិន ហើយខាងក្រោមនេះជាតារាងដែលបង្ហាញពីទីតាំងរបស់នីតិកម្មសិទ្ធិបញ្ញា៖




### ១.២.២ គណៈកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

គោលបំណងនៃការបង្កើតឲ្យមានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានៅឆ្នាំ២០០៨ គឺដើម្បីជម្រុញ ធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផ្សព្វផ្សាយ អនុវត្តច្បាប់ និងបទបញ្ញត្តិកម្មសិទ្ធិបញ្ញា។ នៅ

ពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហការទទួល និងប្រើប្រាស់ជំនួយពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីអង្គការជាតិ និងប្រទេសនានាឲ្យមានប្រសិទ្ធិភាពខ្ពស់។[21]

**១.២.២.១ សមាសភាពគណៈកម្មការគ្រប់គ្រងកម្មសិទ្ធិបញ្ញា**

គណៈកម្មាធិការគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានសមាសភាពដូចខាងក្រោម៖[22]

- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន
- រដ្ឋលេខាធិកាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុប្រធាន
- រដ្ឋលេខាធិកាក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងពត៌មាន សមាជិក
- តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងរុក្ខាប្រម៉ាញ់ និងនេសាទ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងយុត្តិធម៌ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក

---

[21] អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៨ មាត្រា២

[22] អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៨ មាត្រា៣

### ***១.២.២.២ ភារកិច្ចគណៈកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា***

ភារកិច្ចរបស់គណៈកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានភារកិច្ចមួយចំនួនដូចខាងក្រោម ៖[23]

- ទទួលបន្ទុកជាចំណុចកណ្ដាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ក្នុងវិស័យកម្មសិទ្ធិបញ្ញាជាមួយបណ្ដាប្រទេស និងអង្គការជាតិនានា
- សម្របសម្រួលឲ្យមានភាពរលូនលើរាល់ការងារដែលទាក់ទងនិងកម្មសិទ្ធិបញ្ញា និងក្រសួងស្ថាប័នពាក់ព័ន្ធ
- សហការជម្រុញ រៀបចំសេចក្ដីព្រាងច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា និងក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា
- ទទួល និងប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធ និងវិស័យកម្មសិទ្ធិបញ្ញាពីបណ្ដាប្រទេស និងអង្គការអន្តរជាតិ
- សហការជាមួយក្រសួងពាក់ព័ន្ធផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិនានា ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាដល់មហាជន មន្ត្រីអនុវត្តច្បាប់ និងសិស្សនិស្សិតតាមគ្រឹះស្ថានអប់រំ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និងបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា
- សហការសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនិងកម្មសិទ្ធិបញ្ញា ដើម្បីពិចារណាពីអត្ថប្រយោជន៍ ចំណុចខ្លាំង ចំណុចខ្សោយ មុននឹងរាយការណ៍សុំការយល់ព្រមចូលជាសមាជិកពីប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលយ៉ាងតិចមួយឆ្នាំម្ដង និងតាមតំណាក់កាលនីមួយៗ។

### **១.២.៣ ក្រសួងពាក់ព័ន្ធក្នុងការរៀបចំច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា**

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ក្រសួងស្ថាប័នដែលមានយុត្តាធិកាក្នុងការបញ្ញត្តិច្បាប់រួមមានដូចជា៖[24]

---

[23] អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា៤

[24] នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ទំព័រទី១២(សាស្ត្រាចារ្យ ឥន ឃឿន និង អ៊ុក វណ្ណរ័ត្ន)

*១. ក្រសួងពាណិជ្ជកម្ម*

ក្រសួងពាណិជ្ជកម្ម បានធ្វើបញ្ញត្តិដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាមានដូចជា ៖

- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២
- ច្បាប់ស្តីពីការបង្ហាញពីលក្ខណៈភូមិសាស្ត្រទំនិញ(សេចក្តីព្រាង)
- ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម ដែលមិនបញ្ចេញពត៌មាន(សេចក្តីព្រាង)
- ច្បាប់ស្តីពីសិទ្ធិធ្វើអាជីវកម្មពិសេសច្បាប់អាជ្ញាប័ណ្ណ(សេចក្តីព្រាង)
- អនុក្រឹតលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨

*២. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល*

- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាកម្ម និងម៉ូដែលមានអត្ថប្រយោជន៍ ឆ្នាំ២០០៣
- ច្បាប់ស្តីពីការការពារអឺសេរួមបញ្ចូលគ្នា (សេចក្តីព្រាង)

*៣. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ*

- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣
- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ឆ្នាំ២០១១(សេចក្តីព្រាងលើកទី២)
- ប្រកាសលេខ ១៥០ប្រក.វវស ស្តីពីការគ្រប់គ្រងអាជីវកម្មសេវាថតចម្លង ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២
- ប្រកាសលេខ៦០ប្រក.វវស ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០០៣ ស្តីពីការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- សេចក្តីជូនដំណឹង លេខ២២ ស.ជ.ណ ចុះថ្ងៃទៅ០៥ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការធ្វើអាជីវកម្មស្នាដៃអក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍
- សេចក្តីជូនដំណឹង លេខ៣៣ ស.ជ.ណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្រគល់សិទ្ធិគ្រប់គ្រងលើស្នាដៃអក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រីដែលគ្មានមរតកសាសន៍

*៤. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*

- ច្បាប់ស្តីពីការការពារបញ្ជូនសញ្ញាតាមប្រព័ន្ធផ្កាយរណប (សេចក្តីព្រាង)

*៥. ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ*

- ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨

# ជំពូកទី ២
# ការការពារសិទ្ធិអ្នកនិពន្ធ

# ជំពូកទី ២
# ការការពារសិទ្ធិអ្នកនិពន្ធ

## ២.១ សញ្ញាណគតិយុត្ត

### ២.១.១ និយមន័យ

សិទ្ធអ្នកនិពន្ធ គឺជាសិទ្ធមួយក្នុងចំណោមសិទ្ធិទាំងឡាយនៃកម្មសិទ្ធិបញ្ញា ដែលអ្នកនិពន្ធបានបង្កើតឡើងនៅក្នុងការតាក់តែងនិពន្ធផ្សេងៗ គំនូរ ស្នាដៃស្ថាបត្យកម្ម និងស្នាដៃជាច្រើនផ្សេងទៀត។

សិទ្ធិអ្នកនិពន្ធ ជាសិទ្ធិរបស់ម្ចាស់ស្នាដៃក្នុងការទទួលបាននូវកិច្ចការពារស្របច្បាប់លើស្នាដៃរបស់ខ្លួនដែលត្រូវបានបង្កើតឡើងដោយបញ្ញាស្មារតី និងមនោសញ្ចេតនារបស់អ្នកនិពន្ធ។ ស្នាដៃអ្នកនិពន្ធ ត្រូវបានការពារស្របច្បាប់នៅពេលដែលស្នាដៃនោះត្រូវបានបង្កើតឡើងជាស្នាដៃរូបិយ។

អ្នកនិពន្ធ គឺជាជនដែលបង្កើតបានស្នាដៃ។[25] ស្នាដៃ គឺជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ដែលកើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា។[26]

### ២.១.២ ការកំណត់ឋានៈជាអ្នកនិពន្ធ

ក្នុងការកំណត់គុណភាពជាអ្នកនិពន្ធស្នាដៃមួយ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល បានបង្កើតនូវគោលការណ៍មួយចំនួន គឺអ្នកនិពន្ធជាបុគ្គលដែលបង្កើតស្នាដៃ(១) ក៏ប៉ុន្តែចំពោះបញ្ហាដែលថានីតិបុគ្គល ឬរូបវ័ន្តបុគ្គល អាចចាត់ទុកថាជាអ្នកនិពន្ធដែរឬទេ ក៏នឹងត្រូវធ្វើការបកស្រាយអោយបានច្បាស់លាស់ផងដែរ (២) ។

#### *១. អ្នកនិពន្ធជាបុគ្គលបង្កើតស្នាដៃ*

អនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលប្រកាសអោយប្រើនៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៣ បានកំណត់ថាជនដែលបង្កើតស្នាដៃ គឺជាអ្នកនិពន្ធ ដើម្បីជាការលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃទាំងឡាយ ដោយនៅក្នុងអត្ថន័យនេះ អ្នកនិពន្ធត្រូវតែជាបុគ្គលដែល

[25] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា២ ចំណុច ខ

[26] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា២ ចំណុច ក

បានបង្កើតស្នាដៃនោះដោយផ្ទាល់ ទើបអាចក្លាយជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីអ្នកនិពន្ធបានបង្កើតឡើង។[27]

ម៉្យាងវិញទៀត ឋានៈជាអ្នកនិពន្ធ គឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាម៉ីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ។[28] ឋានៈជាអ្នកនិពន្ធ សំដៅលើគុណសម្បត្តិដើម្បីអាចក្លាយជាអ្នកនិពន្ធ។ យោងតាមមាត្រា១១ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជា គោលការណ៍នៃការទទួលបានឋានៈ ឬគុណភាពជាអ្នកនិពន្ធស្នាដៃត្រូវបានដាក់អោយចំណុះទៅនឹងលក្ខខណ្ឌគ្រឹះតែមួយគត់ ពោលគឺស្ថានភាពនៃការបង្កើតស្នាដៃដែលច្បាប់មួយទទួលស្គាល់។ ចំណែកឯការផ្សព្វផ្សាយនូវស្នាដៃរបស់ខ្លួនជាសាធារណៈ គឺគ្រាន់តែជាលក្ខខណ្ឌទម្រង់មួយ ដើម្បីអនុញ្ញាតអោយសាធារណៈជនបានដឹងលឺ ឬអំពីគុណសម្បត្តិជាអ្នកនិពន្ធស្នាដៃ ដែលត្រូវបានច្បាប់ការពាររួចហើយប៉ុណ្ណោះ។

ការទទួលស្គាល់នូវគោលការណ៍នេះ ក៏អាចត្រូវបានបកស្រាយប្រសិនបើគ្មានបណ្តឹងជំទាស់ណាមួយពីសំណាក់អ្នកនិពន្ធពិតប្រាកដដែលបានបង្កើតស្នាដៃនោះទេ នោះនឹងអាចបកស្រាយនៅក្នុងសម្មតិកម្មពីរយ៉ាង៖ បុគ្គលដែលបានប្រើប្រាស់ឈ្មោះលើស្នាដៃនោះហើយ គឺជាអ្នកនិពន្ធស្នាដៃ ឬជាអ្នកទទួលសិទ្ធជាអ្នកតំណាងអោយអ្នកនិពន្ធដែលបានបង្កើតស្នាដៃនោះ ទាំងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌រហូតដល់គុណសម្បត្តិជាអ្នកនិពន្ធពិតប្រាកដត្រូវបានអះអាង នេះមានន័យថាអ្នកតំណាងមិនមែនកើតចេញពីកិច្ចព្រមព្រៀងណាមួយឡើយ គឺកើតចេញពីការសន្មតដោយច្បាប់។

### ២. *អ្នកនិពន្ធត្រូវតែជារូបវ័ន្តបុគ្គល*

អ្នកនិពន្ធជាជនបង្កើតស្នាដៃ ដោយស្នាដៃនោះត្រូវតែកើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនាពិតប្រាកដរបស់មនុស្ស។ ក្នុងន័យនេះយើងអាច សន្និដ្ឋានបានថាច្បាប់របស់កម្ពុជា គឺទទួលស្គាល់តែអ្នកនិពន្ធដែលជារូបវ័ន្តបុគ្គលតែប៉ុណ្ណោះដោយសំអាងថា ការប្រើប្រាស់គំនិត ឬការប្រើមនោសញ្ចេតនា គឺកើតចេញពីការគិតរបស់បុគ្គលម្នាក់ៗផ្សេងៗគ្នា ព្រោះយើងមិនអាចខ្ចីគំនិត ឬមនោសញ្ចេតនាអ្នកដ៏ទៃបានឡើយ។

ដោយយោងតាមស្មារតី នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជា បានចែងទាក់ទងជាមួយនឹងស្នាដៃនិពន្ធ ដែលត្រូវបានគេសំដៅទៅដល់ស្នាដៃដែល

[27] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា៤

[28] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា១១

បង្កើតឡើងដោយ ជនដែលមានសញ្ជាតិខ្មែរ ឬជនដែលមានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវតែស្របទៅតាម ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ទន្ទឹមនឹងគ្នានេះផងដែលក៏ត្រូវមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[29]

តាមរយៈបញ្ញត្តិនេះ វាដូចជាមានភាពស្រពិចស្រពិលក្នុងការកំណត់ឋានៈអ្នកនិពន្ធ ប៉ុន្តែមាត្រា១៣ នៃច្បាប់នេះដដែលបានបែងចែកពីការទទួលស្គាល់នីតិបុគ្គល ក្នុងឋានៈជាអ្នកនិពន្ធស្នាដៃសមូហភាពវិញ។[30]

### ២.១.៣ ស្នាដៃដែលទទួលបាននូវការការពារ

ស្នាដៃដែលទទួលបានការការពារមានដូចជា៖[31]

- សៀវភៅអានគ្រប់ប្រភេទ ឯកសារដែលទាក់ទងទៅនឹង អក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ
- អត្ថបទបាឋកថា[32]សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា
- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី
- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី
- ការសម្តែងសៀកនិងការសម្តែងកាយវិការ
- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង
- ស្នាដៃសោតទស្សន៍
- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬក៏ជាស្នាដៃផ្សេងៗ ផ្នែកខាងសិល្បៈសូន្យរូប ឬសិល្បៈអនុវត្ត
- ស្នាដៃថតរូបជាស្នាដៃទាំងឡាយណាដែលសម្រេចបានដោយសារមានជំនួយពីឧបករណ៍បច្ចេកទេសដូចគ្នានឹងការថតរូប
- ស្នាដៃស្ថាបត្យកម្ម

---

[29] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា៣-១-ក

[30] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា១៣

[31] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៧

[32] បាឋកថា មានន័យថា សម្តីថ្លែងសេចក្តី(មាត់ទទេ), កថាសម្តែងរឿងរ៉ាវ, កថាសូត្របាលី។ យកពីវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួនណាត

- ផែនទី ប្លង់ គំនូសវាស ឬស្នាដៃដែលស្តែងចេញជារូប ដែលទាក់ទងទៅនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា
- កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ
- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ។

ប៉ុន្តែមានស្នាដៃមួយចំនួនទៀត ក៏មិនត្រូវអនុញ្ញាតឲ្យទទួលបានការការពារតាមរយៈសិទ្ធិអ្នកនិពន្ធឡើយមានដូចជា អត្ថបទច្បាប់ និងបទដ្ឋានគតិយុត្តរបស់រដ្ឋដែលត្រូវបានអនុម័តដោយសភាជាតិ បទដ្ឋានគតិយុត្ត ឬលិខិតរដ្ឋបាលចេញដោយរាជរដ្ឋាភិបាល និងអាជ្ញាធរសាធារណៈរបស់រដ្ឋ។ ចំពោះស្នាដៃប្រភេទនេះ បុគ្គលណាក៏អាចមានសិទ្ធិថតចម្លងយកទៅសិក្សាស្វែងយល់ផងដែរ។

## ២.២ លក្ខខណ្ឌដើម្បីទទួលបាននូវកិច្ចការពារ

ដើម្បីឲ្យស្នាដៃមួយអាចទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ ស្នាដៃនោះត្រូវតែមានទម្រង់ណាមួយជាក់លាក់ មិនមែន ស្ថិតនៅក្នុងគំនិតអរូបិយ។ គំនិត ដែលស្ថិតនៅជាលក្ខណៈអរូបិយ គឺគេមិនអាចការពារបានទេ។ គេការពារបាន លុះត្រាតែគំនិតនោះ ត្រូវបញ្ចេញមកខាងក្រៅ ក្នុងទ្រង់ទ្រាយណាមួយជាក់លាក់ ដែលតាមច្បាប់ គេឲ្យឈ្មោះថា “ស្នាដៃ” ដូចជា៖

- ការនិពន្ធ មានសៀវភៅ បទភ្លេង ចម្រៀង ប្រលោមលោក ភាពយន្ត
- ការសម្តែង មានការសម្តែងរបាំ ឬការប្រគុំតន្ត្រី
- ការផ្សាយជាសំឡេង រូបភាព ឬឯកសារនានា តាមវិទ្យុ ឬ ទូរទស្សន៍។[33]

### ២.២.១ ស្នាដៃដើម

ស្នាដៃដែលអាចចាត់ទុកថាជាស្នាដៃដើមបាននោះ គឺជាស្នាដៃទាំងឡាយណាដែលត្រូវបានបង្កើតឡើងតាមគំនិតប្រាជ្ញារបស់អ្នកនិពន្ធនៃស្នាដៃនោះ។[34] តាមន័យនេះ មានន័យថាគ្រប់ស្នាដៃទាំងឡាយមិនត្រូវបានការពារឡើយ ក្នុងករណីដែលស្នាដៃនោះមិនមែនជាការបង្កើតឡើងពីគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធ តែជាការលួចចម្លងពីស្នាដៃដើមទៅវិញដោយគ្មានការអនុញ្ញាតពីម្ចាស់ស្នាដៃ។ ម៉្យាងវិញទៀត ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលបានចែងថា ស្នាដៃដែលមិនទទួលបាននូវការការពារមានដូចជា៖[35]

[33] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣

[34] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤

[35] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា១០

ក. រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានផ្លូវការនានា

ខ. ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ

គ. សេចក្តីសម្រេច សាលក្រម ឬសាលដីការផ្សេងៗ របស់តុលាការ

ឃ. អត្ថបទបកប្រែជាភាសាបរទេសនៃអត្ថបទ ក្នុងចំណុច ក ចំណុច ខ និងចំណុច គ ខាងលើក្នុងមាត្រានេះ

ង. គំនិត នីតិវិធី ប្រព័ន្ធ របៀបប្រតិបត្តិការ ទស្សនៈ គោលការណ៍ ការរុករកឃើញ ឬទិន្នន័យសាមញ្ញទោះបីត្រូវបានផ្សព្វផ្សាយ អធិប្បាយ ពន្យល់ ឬមានក្នុងស្នាដៃណាមួយក៏ដោយ។

### ២.២.២ លក្ខខណ្ឌគ្រឹះ

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ បានបង្កើតលក្ខខណ្ឌគ្រឹះមួយចំនួន ដើម្បីអោយស្នាដៃដែលត្រូវបានបង្កើតរួចរាល់ហើយអាចទទួលបាននូវកិច្ចការពារពីច្បាប់ ឬអាចនិយាយបាន ម៉្យាងទៀតថា បង្កើតសិទ្ធិដល់អ្នកដែលខិតខំប្រឹងប្រែងបង្កើតស្នាដៃនោះ។ ក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនោះ លក្ខខណ្ឌដែលសំខាន់ជាងគេ និងត្រូវតែបំពេញដាច់ខាច ចំពោះស្នាដៃទាំងឡាយ គឺភាពដើមនៃស្នាដៃ។ ម៉្យាងទៀត លក្ខខណ្ឌសញ្ជាតិរបស់អ្នកនិពន្ធស្នាដៃ ក៏ដូចជាលក្ខខណ្ឌដែនដី បានបោះពុម្ពផ្សាយ គឺតម្រូវអោយមានចៀសមិនបាន។ លើសពីនេះ បើទោះបីជាលក្ខខណ្ឌគ្រឹះបានបំពេញត្រឹមត្រូវដោយស្នាដៃនិពន្ធក៏ដោយ ក៏ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅតែបង្កើតអញ្ញត្រកម្ម គឺបានរាយឈ្មោះស្នាដៃអ្នកនិពន្ធដែលមិនទទួលបានកិច្ចការពារពីច្បាប់នេះដែរ។

#### *២.២.២.១ ភាពដើម*

ដើម្បីទទួលស្គាល់សញ្ញាណនៃភាពដើមនេះ មាត្រា៥ និង មាត្រា៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានបញ្ជាក់ពីការការពារយ៉ាងដាច់ខាតដល់ស្នាដៃដើមមួយ ប្រឆាំងទប់ទល់នឹងការបង្កើតស្នាដៃបន្ត "ស្នាដៃមួយទោះបីពុំទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី ស្នាដៃនោះត្រូវចាត់ទុកថាបានបង្កើតឡើងដោយ ចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិតប្រាជ្ញាអ្នកនិពន្ធ"។[36]

#### *២.២.២.២ កម្រឹតភាពដើម*

ការកម្រឹតភាពដើមនេះ អាចនឹងមានការប្រែប្រួលទៅតាមលក្ខណៈ នៃការប្រើប្រាស់គំនិតប្រាជ្ញារបស់អ្នកនិពន្ធទៅបង្កើតស្នាដៃមួយ។ យើងនឹងវិភាគពីភាពដើមដាច់ខាត និងភាពដើមមិនដាច់ខាតនៃស្នាដៃអ្នកនិពន្ធ។

---

[36] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៥

ភាពដើមដាច់ខាត សំដៅដល់ការប្រើប្រាស់គំនិតប្រាជ្ញាផ្ទាល់ របស់អ្នកនិពន្ធទៅបង្កើត។[37] ក្នុងករណីនេះ ច្បាប់កំណត់ឈ្មោះស្នាដៃដែលជាផលិតផលនៃភាពដើមដាច់ខាតថា "ស្នាដៃដើម"។ ទន្ទឹមនឹងនេះ ច្បាប់ក៏បានទទួលស្គាល់នូវសញ្ញាណនៃភាពដើមមិនដាច់ខាតពោល គឺការខ្ចីទម្រង់នៃភាពដើមពីគេដូចជា ការបកប្រែ ការយកលំនាំដើម ការកែសម្រួល ការកែឆ្នៃ ឬការកែលម្អស្នាដៃមួយទៅបង្កើតស្នាដៃថ្មីមួយទៀត ដែលនៅក្នុងករណីនេះច្បាប់ឲ្យឈ្មោះថា "ស្នាដៃបន្ត"។[38] ថ្វីត្បិតតែស្នាដៃបន្តនេះ គឺបានខ្ចីនូវលក្ខណៈណាមួយពីស្នាដៃដើមដែលនឹងអាចនាំឲ្យភាពដើមផ្ទាល់របស់វាក្លាយជា "ពុំសុទ្ធ" ឬ "លាយ" ប៉ុន្តែស្នាដៃបន្តនេះនៅតែទទួលបានការការពារពីច្បាប់ដដែល កាលបើមានភាពដើមផ្ទាល់របស់ខ្លួនវា ពោល គឺគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធ។ ក្នុងន័យនេះដែរ ស្នាដៃចម្លងពីស្នាដៃបន្តមួយ និងពុំមានភាពដើមផ្ទាល់នោះឡើយហើយពុំត្រូវទទួលបានការការពារ ។

ដោយសារតែស្នាដៃបន្តនេះ បានខ្ចីភាពដើមរបស់ស្នាដៃផ្សេងទៀតមកប្រើប្រាស់ ដូចនេះស្នាដៃបន្តនឹងអាចចាត់ទុកថាស្របច្បាប់ ហើយអាចទទួលបានការការពារពីច្បាប់បានលុះត្រាតែមានការយល់ព្រមពីម្ចាស់ស្នាដៃដើម។ ការលួចខ្ចីដោយពុំមានការយល់ព្រមពីម្ចាស់ស្នាដៃដើម គឺជាការរំលោភបំពានលើ សិទ្ធអ្នកនិពន្ធ ដែលនាំឲ្យភាពដើមផ្ទាល់របស់ស្នាដៃបន្តនោះត្រូវបាត់បង់ការទទួលស្គាល់ពីច្បាប់ ហើយចាត់ទុកថាជាការលួចចម្លងស្នាដៃទៅវិញ។ ម៉្យាងទៀត ការលួចចម្លងស្នាដៃទោះបីជាស្ថិតក្រោមទម្រង់ជាស្នាដៃបន្តក៏ដោយ វានៅតែពុំមានភាពដើមផ្ទាល់ ហើយមិនត្រូវបានការការពារស្របច្បាប់ឡើយ។

**លក្ខខណ្ឌតាមផ្លូវច្បាប់**

- **គោលការណ៍ការពារស្នាដៃដែលបង្កើតដោយជនមានសញ្ជាតិខ្មែរ**

យោងតាម មាត្រា៣៨ វាក្យខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលចែងថា រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះ ជាស្វ័យប្រវត្តិ។ តាមរយៈពាក្យ ត្រូវទទួលបានកិច្ចការពារជាស្វ័យប្រវត្តិ អាចឲ្យយើងបកស្រាយបានពីការបង្កើតកាតព្វកិច្ច ទៅដល់អាជ្ញាធររដ្ឋដែលមានសមត្ថកិច្ចទាំងអស់ក្នុងកិច្ចការពាររាល់ស្នាដៃដែលបានបំពេញលក្ខខណ្ឌ។ ក្នុងន័យនេះ ច្បាប់នឹងមិនតម្រូវឲ្យម្ចាស់ស្នាដៃត្រូវតែយកស្នាដៃដែលខ្លួនខិតខំបង្កើតនោះទៅបំពេញនូវលក្ខខណ្ឌទម្រង់ណាមួយដើម្បីទទួលបាននូវកិច្ចការពារនោះទេ។ ដូចនេះ រាល់ការបដិសេធមិនទទួលស្គាល់ សិទ្ធិអ្នកនិពន្ធពីសំណាក់អាជ្ញាធរមិនត្រូវបានចាត់ទុកជាអំពើស្របច្បាប់ឡើយ។

[37] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤

[38] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៨

➢ **អញ្ញត្រកម្មការពារស្នាដៃរបស់ជនបរទេសដែលមានលំនៅនៅកម្ពុជា**

គោលការណ៍ នៃការការពារខាងលើបានទទួលរងនូវអញ្ញត្រកម្មចំនួនពីរគឺៈ កាលបើកម្ពុជាបានជាប់កាតព្វកិច្ចការពារស្នាដៃឲ្យជនបរទេស ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងអន្តរជាតិ ណាមួយ នឹងកាលបើកម្ពុជាខ្លួនឯងបានប្រកាសនៅក្នុងច្បាប់ជាតិរបស់ខ្លួន អំពីកាតព្វកិច្ចការពារដល់ស្នាដៃនោះ។ ក្នុងន័យនេះ មាត្រា៣ ចំណុច ១ ទាំងមូលបានប្រកាសថានឹងការពារដល់ស្នាដៃដែលបង្កើតដោយជនបរទេសកាលបើៈ[39]

- ស្នាដៃនោះត្រូវបានបង្កើតឡើងដោយជនបរទេសដែលមានលំនៅអចិន្ត្រៃយ៍នៅកម្ពុជា
- ស្នាដៃនោះត្រូវបានបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា ឬត្រូវបានបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ប៉ុន្តែត្រូវបានយកមកបោះពុម្ពផ្សាយនៅកម្ពុជាក្នុងកំឡុងពេល៣០ថ្ងៃ (ចាប់រាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយលើកដំបូង)។
- ស្នាដៃនោះជាស្នាដៃសោតទស្សន៍ ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃនោះជាស្នាដៃស្ថាបត្យកម្ម ដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗដែលភ្ជាប់ទៅនឹងអាគារ ឬរចនាសម្ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃនោះជាស្នាដៃ ដែលព្រះរាជាណាចក្រកម្ពុជាមានការព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ។

## ២.២.៣ លក្ខខណ្ឌទម្រង់

### *ក. គោលការណ៍នៃការការពារដោយស្វ័យប្រវត្តិ*

យោងតាម មាត្រា៣៨ វាក្យខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានចែងថា រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះ ជាស្វ័យប្រវត្តិ។ តាមរយៈពាក្យត្រូវទទួលបានកិច្ចការពារជាស្វ័យប្រវត្តិ អាចឲ្យយើងបកស្រាយបានពីការបង្កើតកាតព្វកិច្ច ទៅដល់អាជ្ញាធររដ្ឋដែលមានសមត្ថកិច្ចទាំងអស់ក្នុងកិច្ចការពាររាល់ស្នាដៃដែលបានបំពេញលក្ខខណ្ឌ។ ក្នុងន័យនេះ ច្បាប់នឹងមិនតម្រូវឲ្យម្ចាស់ស្នាដៃត្រូវតែយកស្នាដៃដែលខ្លួនខិតខំបង្កើតនោះទៅបំពេញនូវលក្ខខណ្ឌទម្រង់ណាមួយដើម្បីទទួលបាននូវកិច្ចការពារនោះទេ។ ដូចនេះ រាល់ការបដិសេធមិនទទួលស្គាល់ សិទ្ធិអ្នកនិពន្ធពីសំណាក់អាជ្ញាធរមិនត្រូវបានចាត់ទុកជាអំពើស្របច្បាប់ឡើយ។

[39] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣

## ខ. ការចុះបញ្ជី និង ការតម្កល់ទុក

### ខ.១ ការចុះបញ្ជីស្នាដៃ

យោងតាម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជា ការចុះបញ្ជីអាចធ្វើទៅបានដោយស្ម័គ្រចិត្តនៅ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។[40] រាល់ការចុះបញ្ជីត្រូវតែចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃបានផ្សព្វផ្សាយជាលើកដំបូង និង ចុះថ្ងៃ ខែឆ្នាំ នៃការបង្កើតស្នាដៃ ព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ។ តាមគោលការណ៍ស្ម័គ្រចិត្ត អ្នកនិពន្ធ គ្រប់រូបអាចយកស្នាដៃដែលខ្លួនបានបង្កើតទៅធ្វើការចុះបញ្ជីនៅ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាស្ថាប័នមានសមត្ថកិច្ចលើវិស័យនេះ។ តាមរយៈមាត្រាខាងលើនេះ ការសម្រេចពុំយកស្នាដៃរបស់ខ្លួនទៅ ចុះបញ្ជីមិនមានន័យថា ស្នាដៃនោះមិនត្រូវបានទទួលនូវកិច្ចការពារនោះទេ។

ការចុះបញ្ជីនេះ ក៏ទាមទារឲ្យមានការបង់កម្រៃផងដែរ។ បន្ថែមពីនេះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវចេញនូវវិញ្ញាបនបត្រចំពោះស្នាដៃដែលបានចុះបញ្ជីរួច។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរបស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។[41]

### ខ.២ ការតម្កល់ស្នាដៃ

ក្នុងករណីចុះបញ្ជីដែរ វាក្យខណ្ឌទី២ នៃមាត្រា៣៨ ចែងថាអ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ពាក្យ អាច ក្នុងន័យនេះ គឺសំដៅលើការផ្តល់ជម្រើសដល់អ្នកនិពន្ធក្នុងការសម្រេចតម្កល់ ឬមិនតម្កល់ស្នាដៃរបស់ខ្លួន ដែលការសម្រេចនេះ ពិតជាពុំអាចនាំឲ្យប៉ះពាល់ដល់កិច្ចការពារស្នាដៃឡើយ។ ប៉ុន្តែ ខុសពីករណីនៃការចុះបញ្ជីស្នាដៃ ការតម្កល់ស្នាដៃទុកនេះ ពុំត្រូវបានច្បាប់នេះបញ្ជាក់ឲ្យច្បាស់ថា តើអ្នកនិពន្ធ ឬម្ចាស់សិទ្ធិត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ? ឬគ្រាន់តែយកស្នាដៃខ្លួនទៅទុកជាការស្រេច? តើត្រូវបង់កម្រៃណាមួយឬទេ?[42]

## គ. ភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិអ្នកនិពន្ធ

ស្នាដៃដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីនឹងចេញវិញ្ញាបនបត្របញ្ជាក់អំពីការចុះបញ្ជីស្នាដៃ។ វិញ្ញាបនបត្រនេះជាភស្តុតាងដ៏រឹងមាំ ដែលអាចបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើស្នាដៃ។ ក្រៅពីវិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីសិទ្ធិអ្នកនិពន្ធ ម្ចាស់ស្នាដៃអាចបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើស្នាដៃរបស់ខ្លួនតាមរយៈមធ្យោបាយផ្សេងទៀតមានជាអាទ៍៖

---

[40] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣៩

[41] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤០

[42] ចំពោះបែបបទនៃការតម្កល់ស្នាដៃគឺត្រូវធ្វើឡើងតាមស្ថានភាពជាក់ស្តែងដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតម្រូវ

- ឯកសារបញ្ជាក់ពីការបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា៖ បណ្ណាល័យជាតិ ឬបណ្ណាល័យរបស់គ្រឹះស្ថានសិក្សារដ្ឋនានា។
- ឯកសារបញ្ជាក់ពីការតម្កល់ស្នាដៃនៅស្ថាប័នរដ្ឋ ឬឯកជននៅកម្ពុជា៖ បណ្ណាល័យនៃគ្រឹះស្ថានអប់រំឯកជន
- ឬកិច្ចសន្យាស្តីអំពីការបោះពុម្ពស្នាដៃ ការផ្តល់សិទ្ធិចែកចាយស្នាដៃក្នុងដែនដីកម្ពុជា កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាបោះពុម្ពជាមួយរោងពុម្ព កិច្ចសន្យាការងារចំពោះស្នាដៃសមូហភាព។

ដូចនេះនៅពេលដែលមានវិវាទ អ្នកនិពន្ធអាចប្រើប្រាស់មធ្យោបាយបង្ហាញភស្តុតាងសមស្របណាមួយដែលអាចធ្វើបាន។

## ២.៣ សិទ្ធិ និងប្រយោជន៍ដែលទទួលបាន

### ២.៣.១ សិទ្ធិដែលទទួលបាន

អ្នកនិពន្ធទទួលបានសិទ្ធិផ្តាច់មុខលើស្នាដៃ។ សិទ្ធិអ្នកនិពន្ធមាន២ប្រភេទគឺ សិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។

#### *២.៣.១.១ សិទ្ធិសីលធម៌*

**សិទ្ធិសីលធម៌** គឺជាសិទ្ធិដែលនៅជាប់ជាមួយអ្នកនិពន្ធជានិរន្តរ៍លើខ្លឹមសារទម្រង់ទាំងមូលនៃស្នាដៃ សិទ្ធិនេះជាសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកនិពន្ធដែលមិនអាចដកចេញបានឡើយ។[43]

សិទ្ធិសីលធម៌របស់អ្នកនិពន្ធរួមមាន៖

ក- អ្នកនិពន្ធ មានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីររបៀប និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយការផ្សព្វផ្សាយ។

ខ- អ្នកនិពន្ធ មានសិទ្ធិកំណត់ឲ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណៈជន។

គ- អ្នកនិពន្ធ មានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំភ្លៃស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារជាហេតុធ្វើឲ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះខ្លួន។

---

[43] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា១៩

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានលក្ខណៈពិសេស៤យ៉ាង៖

- **អចិន្ត្រៃយ៍**

សិទ្ធិនេះនៅជាប់អ្នកនិពន្ធជានិច្ចទោះបីជាអ្នកនិពន្ធបានផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនទៅឲ្យតតិយជនក៏ដោយ។ ជាក់ស្តែង នៅក្នុងមាត្រា១៦ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣ ក៏បានកំណត់ពីបញ្ហានេះដែរ។

- **មិនអាចលក់ដូរបាន**

អ្នកនិពន្ធមិនអាចលះបង់ ឬលក់ដូរសិទ្ធិសីលធម៌នេះបានទេ ទោះបីជាអ្នកនិពន្ធចុះកិច្ចសន្យាផ្ទេរក្តីក៏សិទ្ធិនេះពុំអាចបាត់បង់ពីអ្នកនិពន្ធឡើយ។ ពាក្យ មិនអាចលក់ដូរបាន សំដៅលើសិទ្ធិសីលធម៌ពេលដែលអ្នកនិពន្ធនៅមានជីវិតនៅឡើយ។ ផ្ទុយទៅវិញ សិទ្ធិសីលធម៌អាចត្រូវបានផ្ទេរដោយមូលហេតុមរណភាពរបស់អ្នកនិពន្ធ។ ហេតុនេះសិទ្ធិសីលធម៌អាចត្រូវបានផ្ទេរទៅឲ្យទាយាទ ឬអច្ច័យលាភីតាមបញ្ញត្តិមរតកសាសន៍បាន។[44]

- **មិនអាចរឹបអូសបាន**

សិទ្ធិសីលធម៌ ជាសិទ្ធិពុំអាចរឹបអូសបានទេ។ ម្ចាស់បំណុលរបស់អ្នកនិពន្ធពុំមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំរឹបអូសនេះបានឡើយ ដរាបណាអ្នកនិពន្ធពុំទាន់ផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈនោះម្ចាស់បំណុលរបស់អ្នកនិពន្ធពុំអាចបង្ខំរឹបអូសស្នាដៃនោះឡើយ ព្រោះថាសិទ្ធិក្នុងការផ្សព្វផ្សាយស្នាដៃជាសាធារណៈជាសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។

- **មិនមានអាជ្ញាយុកាល**

សិទ្ធិសីលធម៌ មិនមានអាជ្ញាយុកាលនោះទេ សិទ្ធិនេះផ្ទុយពីសិទ្ធិបេតិកភណ្ឌដែលមានរយៈពេលការពារដោយច្បាប់។ សិទ្ធិនេះអាចផុតរលត់ជាមួយស្នាដៃ ដរាបណាស្នាដៃនៅតែមានអត្ថិភាពនោះ សិទ្ធិសីលធម៌របស់អ្នកនិពន្ធនៅតែមានបន្ត។

### ២.៣.១.២ សិទ្ធិបេតិកភណ្ឌ

**សិទ្ធិបេតិកភណ្ឌ** គឺជាសិទ្ធិផ្តាច់មុខរបស់ អ្នកនិពន្ធក្នុងការប្រកបអាជីវកម្ម ឬទាញផលប្រយោជន៍ពីស្នាដៃតាមរយៈការផលិត ការផលិតឡើងវិញ ការបោះពុម្ពផ្សាយជាសាធារណៈ ឬការបង្កើតស្នាដៃបន្ត។[45] សិទ្ធិបេតិកភណ្ឌអាចហៅម៉្យាងទៀតបានថាជា សិទ្ធិសេដ្ឋកិច្ច មានន័យថា ជាសិទ្ធិដែលអាចទូទាត់ ជាសាច់ប្រាក់បានតាមរយៈការអនុវត្តសិទ្ធិរបស់អ្នកនិពន្ធ។ សិទ្ធិនេះត្រូវរួម

[44] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា១៩

[45] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា១៨

បញ្ចូលទាំងសិទ្ធិក្នុងការផ្ទេរ សិទ្ធិបេតិកភណ្ឌទៅឲ្យតតិយជនដើម្បីធ្វើអាជីវកម្ម ផលិតឡើងវិញ និងចែកចាយស្នាដៃ ស្របច្បាប់តាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចសន្យារួមមាន កិច្ចសន្យាអនុប្បទានសិទ្ធិ ឬកិច្ចសន្យាជាអាជ្ញាប័ណ្ណ។

***២.៣.១.៣ ការកម្រិតសិទ្ធិ***

អ្នកនិពន្ធ មិនអាចធ្វើការហាមឃាត់ ចំពោះការសម្តែងដោយសេរី និងមានលក្ខណៈឯកជនដែលធ្វើឡើងក្រោមរូបភាព៖[46]

ក- ការសម្តែងស្នាដៃ ជាឯកជនដោយមិនគិតកម្រៃ ជាការសម្តែងក្នុងរង្វង់គ្រួសារ ឬញាតិមិត្ត

ខ- ការរៀបចំទុកក្នុងបណ្ណាល័យ នូវសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឲ្យបានគង់វង្ស ឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ

គ- ការប្រើប្រាស់ស្នាដៃ សម្រាប់ការសិក្សាដោយគ្មានរកកម្រៃ

ឃ- ការបកប្រែស្នាដៃ ពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ

ទោះបីជាយ៉ាងនេះក្តី ផលចំណេញផ្នែកគនទានចាំបាច់ត្រូវប្រគល់ទៅឲ្យអ្នកកាន់កាប់សិទ្ធិ។ ហេតុនេះ ហើយជនណាក៏អាចធ្វើការចម្លងស្នាដៃរបស់អ្នកនិពន្ធណាម្នាក់ ដើម្បីប្រើប្រាស់ជាផលប្រយោជន៍ផ្ទាល់ខ្លួន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកនិពន្ធនោះទេ។ ការធ្វើបែបនេះមិនមែនជាប្រការខុសច្បាប់ទេ ចំពោះការប្រើប្រាស់ស្នាដៃដែលបានបោះពុម្ពរួចហើយ ក្នុងគោលបំណងដើម្បីបង្ហាញដោយគ្មានការបង់កម្រៃ ឬដោយគ្មានការយល់ព្រមពីអ្នកនិពន្ធ ឲ្យតែគេបានផ្តល់គនទាន ជាកេរ្តិ៍ឈ្មោះទៅឲ្យអ្នកនិពន្ធនោះ។ <u>ឧទាហរណ៍</u>៖ ក្នុងការសរសេរសារណា អ្នកអាចដកស្រង់នូវគោលគំនិតមួយចំនួនចេញពីសៀវភៅណាមួយដោយពុំចាំបាច់មានការអនុញ្ញាត ពីអ្នកនិពន្ធនោះទេ ឲ្យតែអ្នកបានបង្ហាញពីប្រភពនោះឲ្យបានច្បាស់លាស់រួមមានគំនិត និងឈ្មោះអ្នកនិពន្ធនោះ។ ការធ្វើបែបនេះពុំមែនជាការរំលោភ លើសិទ្ធិសីលធម៌របស់អ្នកនិពន្ធឡើយ ព្រោះការទទួលស្គាល់នូវប្រភពស្នាដៃជាការផ្តល់គនទានខាងកេរ្តិ៍ឈ្មោះឲ្យទៅអ្នកនិពន្ធរួចហើយ។

[46] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា២០

### ២.៣.២ ផលប្រយោជន៍ដែលទទួលបាន

*១.ផលប្រយោជន៍សម្រាប់វិស័យវប្បធម៌*

ស្នាដៃដែលបង្កើតឡើងដោយអ្នកនិពន្ធ គឺជាផ្នែកមួយក្នុងការផ្សព្វផ្សាយ និងចែករំលែកអំពីការយល់ដឹងអំពីវប្បធម៌។ សិទ្ធិអ្នកនិពន្ធ ជាផ្នែកមួយនៃសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស និងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ របស់អង្គការសហប្រជាជាតិ និងជាច្បាប់ដ៏សំខាន់មួយសម្រាប់ការពារសិទ្ធិលើស្នាដៃវប្បធម៌។ ស្នាដៃមួយនៃវប្បធម៌ ជាស្នាដៃដែលមនុស្សបានបង្កើតឡើងដើម្បីធ្វើឲ្យប្រសើរឡើងនូវចិត្តគំនិត និងការត្រិះរិះពិចារណារបស់មនុស្ស។ ស្នាដៃវប្បធម៌ មិនរាប់បញ្ចូលនូវការបង្កើតគ្រឿងម៉ាស៊ីន ឬបច្ចេកវិទ្យា ដែលរួមចំណែកសម្រាប់បង្កើនភាពងាយស្រួលនៃរបៀបរស់នៅ និងការងារ។ វត្ថុទាំងអស់នេះមិនចាត់ទុកជាស្នាដៃវប្បធម៌ឡើយព្រោះជាការទាក់ទងសំខាន់ទៅនឹងការអភិវឌ្ឍន៍បច្ចេកវិទ្យានៃអារ្យធម៌ដូចនេះហើយទើបច្បាប់ការពារសិទ្ធិលើវត្ថុទាំងនោះ ជាច្បាប់ផ្សេងពីសិទ្ធិអ្នកនិពន្ធ។ ដូច្នេះ ពាក្យស្នាដៃវប្បធម៌រួមមាន គ្រប់ទម្រង់នៃការសម្តែងគំនិត មានរូបគំនូរ តូរ្យតន្ត្រី ភាពយន្ត និងលទ្ធផលនៃការសិក្សាខាងវិទ្យាសាស្ត្រដែលមានភាពស្មុគស្មាញ។ ស្នាដៃវប្បធម៌ អាចមានន័យ ជាការសម្តែងចេញនូវការបង្កបង្កើតដោយគំនិតបញ្ញា និងមនោសញ្ចេតនារបស់មនុស្ស។ ការសម្តែងបែបនេះអាចមានឥទ្ធិពលលើចិត្តគំនិត និងការរំភើបរបស់មនុស្សផ្សេងទៀត។ ដោយហេតុនេះហើយ ច្បាប់បានទទួលស្គាល់ជនដែលបង្កើតបាននូវស្នាដៃវប្បធម៌ ហើយជននោះមានសិទ្ធិផ្តាច់មុខលើស្នាដៃ និងធានាទទួលបាននូវផលប្រយោជន៍ពេលណាមានអ្នកផ្សេងធ្វើអាជីវកម្មលើស្នាដៃរបស់ខ្លួន។ អ្នកនិពន្ធជាមនុស្សសេរី និងជាអ្នកច្នៃប្រឌិតបង្កើតថ្មី ដែលត្រូវការដឹងរឿងរ៉ាវក្នុងធម្មជាតិ និងសង្គមជាច្រើនដើម្បីយកមកប្រឌិតប្រៀបធៀបទៅតាមទំនោរនៃឆន្ទៈរបស់ខ្លួនទុកជាការកំសាន្ត និងពិចារណាសំដៅទៅរកការបង្កើតគំនិតថ្មី។ អ្នកនិពន្ធ អាចតាក់តែងព្រឹត្តិការណ៍មួយទៅជាកំណាព្យ ជារឿងប្រឌិត ជាចម្រៀង ភាពយន្ត និងរូបថ្លុកកំប្លុកកំប្លែងផងដែរ ទៅតាមជំនាញ ឬទេពកោសល្យរបស់ខ្លួនដោយរើសយកស្ថានការណ៍សង្គមណាមួយទុកឲ្យអ្នកអានពិចារណា។ និយាយរួម តាមរយៈស្នាដៃរបស់អ្នកនិពន្ធ ពិតជាអាចស្តែងឲ្យឃើញអំពីតម្លៃវប្បធម៌របស់សង្គមជាតិមួយ មានន័យថាកាលណានៅក្នុងប្រទេសមួយដែលមានភាពរីកចម្រើនលើការតែងនិពន្ធស្នាដៃថ្មីៗ ដោយបង្កើតជាភាពពេញលេញនិយមមួយទៅដល់សាធារណជន គឺបង្ហាញឲ្យឃើញពីភាពរីកចម្រើន លូតលាស់ និងភាពរុងរឿងនៃវប្បធម៌ជាតិទាំងមូលផងដែរ។

*២.ផលប្រយោជន៍សម្រាប់សង្គមជាតិ*

កិច្ចការពារសិទ្ធិរបស់អ្នកនិពន្ធ ជាកត្តាចាំបាច់មួយសម្រាប់លើកទឹកចិត្តដល់អ្នកនិពន្ធទាំងអស់ដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្ត ពេលវេលាក្នុងការរិះរកនូវស្នាដៃថ្មីមួយសម្រាប់ជាការកំសាន្តដល់មនុស្សគ្រប់វ័យ និងគ្រប់ស្រទាប់វណ្ណៈទាំងអស់។ មិនតែប៉ុណ្ណោះ ការការពារសិទ្ធិនេះជាការធានាដល់កម្រិតជីវភាពល្អប្រសើររបស់អ្នកនិពន្ធ និងអ្នកពាក់ព័ន្ធ ជាពិសេស កិត្តិយសសេចក្តីថ្លៃថ្នូរ និងធានាការរីកចម្រើនក្នុងវិស័យសិល្បៈទាំងមូលទៀតផង។ ថ្វីត្បិតតែ អ្នកនិពន្ធ ជាអ្នកដែលទទួលបានផលប្រយោជន៍ពីស្នាដៃខ្លួនក៏ដោយ ឆ្លើយតបជាមួយនឹងផលប្រយោជន៍ដែលសង្គមជាតិទទួលបានតាមរយៈវិស័យអ្នកនិពន្ធនេះ គឺសង្គមទទួលបាននូវកម្រៃតិចតួចប៉ុណ្ណោះពីការចុះបញ្ជីស្នាដៃ ប៉ុន្តែវាជាមោទនភាពមួយដល់កម្ពុជាដែលអ្នកនិពន្ធទាំងនោះជាជនជាតិខ្មែរបានបង្កើតនូវស្នាដៃដែលជារបស់ខ្លួនឯងផ្ទាល់។

**២.៣.៣ រយៈពេលនៃការការពារ**

សិទ្ធិអ្នកនិពន្ធ បានបង្កើតអាជ្ញាយុកាលមួយជាគោលការណ៍ ដល់ម្ចាស់សិទ្ធិបេតិកភណ្ឌពេល គឺតាមរយៈអាជ្ញាយុកាលនេះម្ចាស់សិទ្ធិ នៃស្នាដៃមួយអាចទទួលបាននូវការការពាររយៈពេលពេញមួយជីវិតអ្នកនិពន្ធ និងបូកបន្ថែម ៥០ឆ្នាំទៀត នៅក្រោយមរណៈភាពរបស់អ្នកនិពន្ធស្នាដៃ។[47] អាជ្ញាយុកាលតាមគោលការណ៍នេះ អាចអនុវត្តបានតែចំពោះស្នាដៃដែលត្រូវបានបង្កើតឡើងដោយអ្នកនិពន្ធមួយរូបគត់ និងដែលអត្តសញ្ញាណរបស់អ្នកនិពន្ធរូបនោះត្រូវបានស្គាល់ទៀតផង។ ដោយឡែក ស្នាដៃសមូហភាព ឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ឆាមរណ គឺ៧៥ឆ្នាំ គិតចាប់ពីបំណាច់ឆ្នាំនៃប្រតិទិន ដែលស្នាដៃនោះបានផ្សព្វផ្សាយលើកដំបូងត្រឹមត្រូវតាមច្បាប់[48] និងប្រសិនបើពុំមានការបោះពុម្ពផ្សាយក្នុងកំឡុងពេល ៥០ឆ្នាំនោះទេ អាជ្ញាយុកាល គឺ១០០ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើតឡើង។ ចំពោះស្នាដៃអនាមិក ឬស្នាដៃរហស្សនាម គឺ ៧៥ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំ ដែលស្នាដៃនោះបានបោះពុម្ពផ្សាយជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ[49] និងប្រសិនបើពុំមានការបោះពុម្ពផ្សាយក្នុងកំឡុងពេល ៥០ឆ្នាំទេ អាជ្ញាយុកាល គឺ ១០០ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំ ដែលស្នាដៃនោះបានបង្កើតឡើង។ ចំណែកឯ

[47] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣០

[48] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣១ កថាខណ្ឌ៤

[49] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៣១ កថាខណ្ឌ១

សិទ្ធិសីលធម៌របស់អ្នកនិពន្ធ ត្រូវទទួលបាននូវការការពារជានិរន្តរ៍ មិនអាចដូរ មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាលឡើយ។

## ២.៣.៤ វិធានប្រឆាំងការរំលោភបំពានសិទ្ធិអ្នកនិពន្ធ

### *២.៣.៤.១ អំពើរំលោភសិទ្ធិអ្នកនិពន្ធ*

តើអំពើណាខ្លះ ដែលចាត់ទុកថាជាអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ? ជាទូទៅត្រូវបានគេចាត់ទុកថាជាអំពើរំលោភសិទ្ធិអ្នកនិពន្ធ គឺរាល់អំពើនៃការប្រើប្រាស់ ការចម្លងទាំងស្រុង ឬដោយឡែក ការផ្សព្វផ្សាយទាំងស្រុង ឬដោយឡែកតាមគ្រប់មធ្យោបាយដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធ។ អំពើរំលោភសិទ្ធិនេះ សំដៅលើការរំលោភសិទ្ធិបេតិកភណ្ឌ ឬសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសីលធម៌ របស់អ្នកនិពន្ធ។

ការរំលោភសិទ្ធិបេតិកភណ្ឌ សំដៅលើការធ្វើអាជីវកម្ម ការផលិតឡើងវិញនូវស្នាដៃ ឬការចែកចាយនូវស្នាដៃដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធស្នាដៃ។ ចំណែកឯអំពើរំលោភសិទ្ធិសីលធម៌វិញ សំដៅលើអំពើនៃការកែប្រែខ្លឹមសារស្នាដៃ ការដក ឬដាក់បន្ថែមនូវខ្លឹមសារ ឬធាតុណាមួយនៃស្នាដៃដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

រាល់អំពើរំលោភសិទ្ធិអ្នកនិពន្ធ គ្រប់រូបភាព ដោយមធ្យោបាយបែបណាក៏ដោយត្រូវបានចាត់ជាបទល្មើស និងត្រូវបានដាក់ទោសតាមច្បាប់។

❖ **រូបភាពនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ**

សិទ្ធិបេតិកភណ្ឌ ឬសិទ្ធិសេដ្ឋកិច្ចរបស់អ្នកនិពន្ធ សំដៅលើសិទ្ធិដែលមិនអាចប្តូរជាប្រាក់បានតាមរយៈការធ្វើអាជីវកម្មលើស្នាដៃ។ ការផ្ទេរសិទ្ធិបេតិកភណ្ឌលើស្នាដៃទៅឲ្យតតិយជនដោយទទួលបាននូវកម្រៃតបស្នង។ សកម្មភាពដូចបានរៀបរាប់ខាងលើដោយពុំមានការងនុញ្ញាតពីម្ចាស់ស្នាដៃត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិ។ បុគ្គលណាដែលបានលួចចម្លងដោយពុំមានការអនុញ្ញាត ក្នុងគោលបំណងធ្វើអាជីវកម្មបន្តដើម្បីប្រយោជន៍ផ្ទាល់ខ្លួននិងត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិអ្នកនិពន្ធ និងត្រូវទទួលទណ្ឌកម្មតាមច្បាប់។

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ បានកំណត់នូវអំពើដែលចាត់ទុកថាជាអំពើរំលោភសិទ្ធិអ្នកនិពន្ធ គឺតាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃ ដែលប្រើតាមមធ្យោបាយណាក៏ដោយ។[50]

[50] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៤ កថាខណ្ឌទី១

អំពើដែលចាត់ទុកថាជាបទល្មើសមានដូចជា៖[51]

- ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាម ក្នុងគោលបំណងឲ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនូវស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឲ្យខូចខាតគុណភាពនូវច្បាប់ចម្លង
- ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឲ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធី ផ្សាយតាមសញ្ញាលេខកូដដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈ តាមវិធីផ្សេងៗរួមមាន ការផ្សាយតាមផ្កាយរណប
- ការលុបចោល ឬការកែប្រែពត៌មានស្តីពីរបបសិទ្ធិ[52] តាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ
- ការចែកចាយ ឬការនាំចូល ដើម្បីចែកចាយការផ្សាយ តាមអង្គភាព ទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនសាធារណជននូវស្នាដៃ ឬការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថាពត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិច ជាពត៌មានដែលត្រូវគេលុបចោល ឬកែប្រែរួចហើយ

### ***២.៣.៤.២ វិធានការផ្នែករដ្ឋបាល***

ជាគោលការណ៍ ម្ចាស់សិទ្ធិមានសិទ្ធិរកដំណោះស្រាយតាមប្រព័ន្ធតុលាការ តាមរយៈការដាក់ពាក្យបណ្តឹងអំពីអំពើរំលោភសិទ្ធិនោះ។ ប៉ុន្តែក្នុងវិស័យកម្មសិទ្ធិបញ្ញា ភាគីអាចបើកឱកាសឲ្យមានការចរចាលើការបញ្ឈប់អំពើតាមរយៈ ការជូនដំណឹងហៅថា “លិខិតព្រមាន” ទៅអ្នករំលោភសិទ្ធិ ឬ/និងទាមទារសំណងព្យសនកម្មទទួលរងដោយអំពើល្មើសនោះ។

វិធានការរដ្ឋបាលអាចត្រូវបានអនុវត្តដោយអាជ្ញាធររដ្ឋបាលដែនដី នៅក្នុងករណីបទល្មើសទូទៅ ឬដោយអាជ្ញាធររដ្ឋបាលគយ និងរដ្ឋាករ ក្នុងករណីនៃបទល្មើសឆ្លងព្រំដែន។វិធានការនេះអាចបានត្រឹមជាការឃាត់ទុកនូវផលនៃអំពើល្មើសនៅក្នុងរយៈពេលបណ្តោះអាសន្នមួយ ដោយតម្រូវឲ្យមានការបញ្ជូនទៅវិនិច្ឆ័យសេចក្តីនៅតុលាការជាបន្ទាប់ទៀត។

---

[51] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា ៦២

[52] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់បប្រហែល មាត្រា ៦៣ កថាខណ្ឌ១

**ក.វិធានការជូនដំណឹង**

វិធានការនេះ អាចត្រូវបានចាត់ទុកជាវិធានការទន់ភ្លន់របស់ម្ចាស់សិទ្ធិនៅក្នុងការជូនដំណឹងដល់អ្នករំលោភសិទ្ធិដើម្បីបញ្ឈប់អំពើរំលោភនេះ និងទាមទារនូវសំណងសមរម្យ។ តាមរយៈវិធានការនេះ ម្ចាស់សិទ្ធិអាចធ្វើជាលិខិតព្រមាន ឬជូនដំណឹងអំពីការរំលោភសិទ្ធិអ្នកនិពន្ធ របស់គាត់ទៅតតិយជនឲ្យធ្វើការបញ្ឈប់អំពើបំពាននោះ។ វិធានការនេះ គ្រាន់តែជាការរំលឹក ដាស់តឿន ទៅដល់ជនបំពាននោះ អំពីអំពើរំលោភសិទ្ធិរបស់ម្ចាស់សិទ្ធិ និងចរចាក្នុងការបញ្ឈប់អំពើបំពាននោះតែប៉ុណ្ណោះ។ រីឯវិធានការបន្ទាប់ទៀត និងត្រូវបានអនុវត្តដោយម្ចាស់សិទ្ធិ ប្រសិនបើមានភស្តុតាងច្បាស់លាស់បញ្ជាក់ថាអ្នករំលោភសិទ្ធិនោះពុំបានបញ្ឈប់អំពើរំលោភបំពាននោះទេ។

**ខ. វិធានការបណ្តោះអាសន្ន**

វិធានការបណ្តោះអាសន្ន មានគោលដៅទប់ស្កាត់អំពើរំលោភបំពានដែលកំពុងតែកើតមាន និងរក្សាភស្តុតាងដែលទាក់ទងទៅនឹងបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធ។ នីតិវិធីនៃវិធានការនេះ ពុំត្រូវបានចែងក្នុងច្បាប់សិទ្ធិអ្នកនិពន្ធឡើយ មានន័យថាវិធានការបណ្តោះអាសន្នត្រូវអនុវត្តតាម ក្រមនីតិវិធីរដ្ឋប្បវេណីទាំងស្រុង។ ក្នុងករណីនេះ តុលាការអាចចេញវិធានការបណ្តោះអាសន្ន ដើម្បីទប់ស្កាត់អំពើរំលោភសិទ្ធិ និងរឹបអូសនូវផលិតផលដែលផលិតចេញពីការចម្លងខុសច្បាប់នូវស្នាដៃដើម្បីរក្សាទុកជាភស្តុតាង។[53] ការរឹបអូសវត្ថុតាង នេះត្រូវធ្វើឡើងតាមរយៈដីការក្សាការពាររបស់តុលាការមានសមត្ថកិច្ច។

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ការរឹបអូសភស្តុតាង ដែលផលិតចេញពីការរំលោភសិទ្ធិអ្នកនិពន្ធ អាចត្រូវបានធ្វើឡើងតាមរយៈ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុ ដែលជាកម្មសិទ្ធិនៃវិវាទ។ ក្នុងករណីដែលមានការបារម្ភថាម្ចាស់សិទ្ធិ និងមិនអាចអនុវត្តសិទ្ធិ និងមានការលំបាកនៅក្នុងការអនុវត្តសិទ្ធិ ដោយសារតែមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។[54] ដើមបណ្តឹងត្រូវបញ្ជាក់ភស្តុតាងអំពីអត្ថិភាព នៃសិទ្ធិលើស្នាដៃនៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។ នៅក្នុងនីតិវិធីនេះ អ្នកប្រព្រឹត្តបទល្មើសអាចត្រូវបានហាមឃាត់នូវ ការនាំចូល ការនាំចេញ ការចែកចាយ ការផលិត និងការប្រើប្រាស់ឧបករណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទនោះ។ បន្ទាប់ពីការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ឬអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើបទល្មើសពុំត្រូវបានរកឃើញ ឬពុំមានភស្តុតាងច្បាស់លាស់ ដែលអាចចោទប្រកាន់បាន ព្រះរាជអាជ្ញានឹងលើកលែងការចោទប្រកាន់ និង

[53] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៥៩ វាក្យខណ្ឌទី១

[54] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៣១ ចំណុចខ

ដោះលែងវត្ថុតាងដែលត្រូវបានរឹបអូសនោះទៅឲ្យជនសង្ស័យនោះវិញ។ ក្នុងករណីនេះដើមបណ្ដឹងត្រូវទទួលខុសត្រូវលើការខូចខាតរបស់ជនសង្ស័យដែលកើតមានឡើងតាមរយៈ បណ្ដឹងរបស់ដើមបណ្ដឹងនោះ។[55]

**គ.វិធានការតាមច្រកព្រំដែន**

វិធានការនេះ និងត្រូវបានអនុវត្តឡើងដោយមន្ត្រីនគរបាលគយ និងរដ្ឋាករ នៅក្នុងដែនសមត្ថកិច្ច និងទៅតាមកម្រិតនៃសិទ្ធិអំណាចរបស់ខ្លួនប៉ុណ្ណោះ។ វិធានការតាមមាត់ច្រកព្រំដែនអនុវត្តបានតែចំពោះអំពើល្មើសដែលបម្រុងនឹងឆ្លងព្រំដែនចូលមកទឹកដីកម្ពុជា ឬក៏បម្រុងនឹងឆ្លងព្រំដែនចេញពីទឹកដីកម្ពុជាទៅកាន់បរទេសប៉ុណ្ណោះ។ អនុលោមតាមមាត្រា ៦៣ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលក្នុងក្របខណ្ឌនៃការត្រួតពិនិត្យ រដ្ឋបាលគយ និងរដ្ឋាករឃាត់ទុកបាននូវទំនិញ ដែលម្ចាស់សិទ្ធិនោះសំអាងថា ជាទំនិញក្លែងបន្លំ។ រដ្ឋបាលគយ និងរដ្ឋាករត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ដើមបណ្ដឹង និងអ្នកកាន់កាប់ទំនិញ អំពីការឃាត់ទុកនូវទំនិញទាំងនោះ។ ការឃាត់ទុកនេះ អាចធ្វើឡើងសម្រាប់តែរយៈពេល**១០ថ្ងៃ**នៃថ្ងៃធ្វើការ ដើម្បីរងចាំចំណាត់ការទៅតុលាការបន្តទៅទៀតតែប៉ុណ្ណោះ។

***២.៣.៤.៣ វិធានការតាមផ្លូវតុលាការ***

ការដាក់ពាក្យបណ្ដឹងរបស់ម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម អាចដាក់ពាក្យនៅភ្នាក់ងារគយ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការក៏បាន។ ពាក្យបណ្ដឹងត្រូវធ្វើជាលាយល័ក្ខអក្សរ និងត្រូវមានឯកសារយោងដែលពាក់ព័ន្ធ ដូចជាវិញ្ញាបនបត្រដែលចុះបញ្ជីសេចក្ដីថ្លែងការពីមូលហេតុនៃការប្ដឹង និងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថាទំនិញនេះមានពាក់ម៉ាកក្លែងក្លាយមែន រួមទាំងការរៀបចំយ៉ាងល្អិតល្អន់ពីទំនិញ ដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ក៏ដូចជាគំរូនៃផលិតផលពិតប្រាកដ និងសំណូមពរឈ្មោះ អាស័យដ្ឋានរបស់អ្នកប្ដឹង ឬតាមរយៈតំណាងរបស់គេ ដែលត្រូវបានរៀបរាប់ឲ្យបានសព្វគ្រប់ តាមការកំណត់លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្ដឹងនោះត្រូវបានប្រគល់សិទ្ធិឲ្យទៅអ្នកតំណាងជាចុងក្រោយ ត្រូវបង់កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

---

[55] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៣ វាក្យខណ្ឌទី៣

ក្នុងរយៈពេល១០ថ្ងៃនៃការធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹងរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ត្រឹមត្រូវ ឬបដិសេធ ឬរក្សាទុកសម្រាប់ពិចារណាណៅពេលក្រោយ។

- **សំណងរដ្ឋប្បវេណី**

អ្នកនិពន្ធ ដែលត្រូវគេរំលោភបំពាន អាចប្តឹងទៅតុលាការដើម្បីបញ្ឈប់ការរំលោភបំពានសិទ្ធិរបស់ខ្លួនក្នុងគោលបំណងទប់ស្កាត់នូវការខូចខាត។[56] ករណីអំពើរំលោភបំពាននោះបម្រុងនឹងកើតឡើងម្ចាស់សិទ្ធិអាចស្នើសុំឲ្យឃាត់ចុងចោទពីការរំលោភបំពានសិទ្ធិរបស់គាត់។ ក្រៅពីការទូទាត់សំណង ម្ចាស់សិទ្ធិអាចពិនិត្យមើលពីផលប្រយោជន៍ដែលបានមកពីអំពើល្មើសនោះព្រមទាំងរឹបអូសយកនូវឧបករណ៍ និងសម្ភារៈក្នុងអំពើនោះទៀតផង។

តុលាការអាចបញ្ជាឲ្យរឹបអូសយក ឬបំផ្លាញចោលនូវឧបករណ៍និងសម្ភារៈដែលបានផលិត ឬប្រើប្រាស់។ ក្នុងរយៈពេល ៣០ថ្ងៃនៃការរឹបអូសនោះ ម្ចាស់សម្ភារៈដែលគេបានរឹបអូសយកនោះ អាចស្នើសុំទៅតុលាការឲ្យដោះលែងក្នុងករណីមានភស្តុតាងផ្ទុយ។ តុលាការមានអំណាច ចាត់វិធានការដែលចាំបាច់ដើម្បីធានារក្សាទុកនូវផលិតផលខុសច្បាប់។ ដើម្បីរក្សាសុវត្ថិភាព ម្ចាស់បណ្តឹងត្រូវទទួលខុសត្រូវនូវរាល់ការខូចខាតចំពោះចុងចម្លើយ ប្រសិនបើតុលាការមិនបានរកឃើញភស្តុតាងពិតប្រាកដ។

- **ទោសព្រហ្មទណ្ឌ**

ច្បាប់បានកំណត់ពីទណ្ឌកម្មពិន័យចំពោះបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធៈ

- **បទល្មើសនៃការផលិត ឬការផលិតឡើងវិញ**

បទល្មើសនៃការផលិត ការផលិតឡើងវិញ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាពី៦ (ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[57]

- **បទល្មើសនៃការនាំចូល ឬនាំចេញនូវផលិតផល**

ការនាំចូល ឬនាំចេញនូវផលិតផលបានពីបទល្មើស ដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/

---

[56] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា ៥៧

[57] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់បប្រហែល មាត្រា៦៤ កថាខណ្ឌ២

និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[58]

**- បទល្មើសនៃការសម្តែង ឬការផ្សាយ**

បទល្មើសនៃការសម្តែង ឬការផ្សាយ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោស ត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដងនៃទោសពីមុន។[59]

[58] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៤ កថាខណ្ឌ៣

[59] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៤ កថាខណ្ឌ៤

# ជំពូកទី ៣
# ការការពារសិទ្ធិប្រហាក់ប្រហែល

# ជំពូកទី ៣
# ការការពារសិទ្ធិប្រហាក់ប្រហែល

## ៣.១ សញ្ញាណគតិយុត្ត

### ៣.១.១ និយមន័យ

សិទ្ធិប្រហាក់ប្រហែល សំដៅដល់សិទ្ធិរបស់តួអង្គបីគឺ សិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ។

សិទ្ធិប្រហាក់ប្រហែល ជាសិទ្ធិមួយដែលជាប់ទាក់ទងនឹងសិទ្ធិអ្នកនិពន្ធ។ គោលបំណងនៃសិទ្ធិប្រហាក់ប្រហែល គឺការការពារនូវផលប្រយោជន៍ស្របច្បាប់របស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលបានរួមចំណែកបង្កើតស្នាដៃដើម្បីជាប្រយោជន៍សាធារណៈ ឬអ្នកផលិតសម្ភារៈ ដែលធ្វើឲ្យស្នាដៃនោះមានគុណភាព ក្រោមប្រព័ន្ធការពារនៃគ្រប់ប្រទេស ដោយមានជំនាញរៀបចំបច្ចេកទេសគ្រប់គ្រាន់ដើម្បីទទួលស្គាល់នូវសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ ច្បាប់ស្តីពីសិទ្ធិប្រហាក់ប្រហែល ត្រូវបានចាត់ទុកជាលទ្ធផលដែលកើតចេញពីសកម្មភាពនៃរូបវ័ន្តបុគ្គល ឬនីតិបុគ្គលត្រូវទទួលបាននូវការការពារស្របច្បាប់ដោយពួកគេជាអ្នកនិពន្ធ ដូចជាអ្នកចម្រៀង តន្ត្រីករ ដែលបានសម្តែងជាសាធារណៈ។

### ៣.១.២ ប្រធាននៃសិទ្ធប្រហាក់ប្រហែល

ប្រភេទនៃសិទ្ធិប្រហាក់ប្រហែល ដែលកំណត់ដោយច្បាប់ជាតិត្រូវបានចែកជាបី ប្រភេទមានដូចខាងក្រោម៖

***ក. អ្នកសម្តែង***

ការសម្តែង ជាការបញ្ចេញស្នាដៃលើឆាកដូចជា៖ រាំ ប្រគុំតន្ត្រី ច្រៀង ឬ បង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗទៀតនូវស្នាដៃសិល្បៈ ប្រពៃណី ទំនៀមទំលាប់ អក្សរសាស្ត្រ ការអប់រំ ឬវិទ្យាសាស្ត្រ។[60]

**ក.១ សិទ្ធិអ្នកសម្តែង**

ក្នុងស្ថានភាពខ្លះអ្នកសម្តែង ត្រូវបានគេផ្តល់សិទ្ធិក្នុងការការពារលើ ការថតបញ្ចូល ចាក់ផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈ នៃការសម្តែងរបស់ពួកគេ ដោយគ្មានការយល់ព្រម និងសិទ្ធិការពារការផលិតឡើងវិញ នៃការសម្តែងនោះហើយសិទ្ធិចាក់ផ្សាយជាសាធារណៈអាចជាទម្រង់លាភការ។

[60] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា២ ចំណុចគ

សិទ្ធិរបស់អ្នកសម្តែងត្រូវបានគេទទួលស្គាល់ ដោយសារតែការបង្កើតរបស់គេ វាចាំបាច់សម្រាប់ជីវិត ឧទាហរណ៍ ស្នាដៃខ្សែភាពយន្ត តន្ត្រី ល្ខោន និងរបាំ ពីព្រោះពួកគេអាចត្រូវបានគេទទួលស្គាល់ផលប្រយោជន៍ពីការការពារនៃការសម្តែងនោះ។

អ្នកសម្តែង មានសិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ ឬអនុញ្ញាតឲ្យតតិយជនអនុវត្តនូវកិច្ចដូចខាងក្រោម៖[61]

- ផ្សព្វផ្សាយជាសាធារណៈ ឬតាមអង្គភាពទូរផ្សាយ
- ថតបញ្ចូលហ្វូណូក្រាម
- ការផលិតឡើងវិញនូវការសម្តែងដែលបានថតចូលហ្វូណូក្រាម
- ចែកចាយសាធារណៈតាមរយៈការលក់ ឬការផ្ទេរ សិទ្ធិនូវហ្វូណូក្រាមច្បាប់ដើម
- ការដាក់ជួល ឬការឲ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬច្បាប់ចម្លង។

ជួនកាលសិទ្ធិប្រហាក់ប្រហែល មិនត្រូវបានការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធទេ ពីព្រោះស្នាដៃទាំងនោះវាផុតរយៈពេលនៃការការពារ។ <u>ឧទាហរណ៍</u>៖ ស្នាដៃ ព្យាណូ(PIANO) របស់លោក **Beethoven** គេអាចយកសម្តែងជាសាធារណៈ ឬថតជាCD ឡើងវិញដោយសារតែគាត់បានស្លាប់តាំងពីឆ្នាំ១៨២៧ ហើយស្នាដៃរបស់គាត់ត្រូវបានចាត់ទុកជាប្រយោជន៍សាធារណៈ គឺមិនមានកិច្ចការពារឡើយ។ ហេតុនេះ នរណាក៏មានសិទ្ធិប្រើប្រាស់ដោយសេរី ដោយមិនចាំបាច់សុំការអនុញ្ញាតឡើយ។

**ក.២ ការផ្ទេរសិទ្ធិបេតិកភណ្ឌ**

ទោះបីមានការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនក៏ដោយ អ្នកសម្តែង នៅមានសិទ្ធិតម្រូវឲ្យគេសរសេរឈ្មោះខ្លួនលើ ការសម្តែងផ្ទាល់ ឬការសម្តែងដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីប្រើប្រាស់នៃការសម្តែងនោះ ពុំតម្រូវឲ្យមានការសរសេរឈ្មោះ។ អ្នកសម្តែង នៅមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំភ្លៃស ការកាត់ខ្លឹមសារខ្លះ ឬការកែប្រែខ្លឹមសារនៃការសម្តែង ជាហេតុធ្វើឲ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង។[62]

[61] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤១

[62] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា ៤២

***ខ. ផលិតករហ្វូណូក្រាម និង ផលិតករវីឌីអូ***

**ខ.១និយមន័យ**

**ផលិតករហ្វូណូក្រាម** គឺជាបុគ្គលដែលបានផលិតវត្ថុដែលបានបញ្ចូលសម្លេង នៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិម្មិតសញ្ញានៃសម្លេង ក្រៅពីទម្រង់ នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងទៀត។

**ផលិតករវីដេអូ** ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានការផ្តួចផ្តើមគំនិត និងការទទួលខុសត្រូវក្នុងការថត បញ្ចូលតាមបច្ចេកទេសផ្សាយរូបភាពជាឈុតៗដែលមាន ឬគ្មានសម្លេងដើម្បីផលិតវីដេអូ។[63]

**ខ.២ សិទ្ធិផលិតករហ្វូណូក្រាម**

ផលិតករហ្វូណូក្រាម មានសិទ្ធិផ្តាច់មុខលើស្នាដៃរបស់ខ្លួន ក្នុងការថត ឬផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃរបស់ខ្លួន។[64] រាល់សកម្មភាពរបស់តតិយជនដែលបានផលិតថតចម្លង ការលក់ ការចែកចាយ សិទ្ធិនាំចូលស្នាដៃ ផ្សព្វផ្សាយក្នុងគោលបំណងយកជាប្រាក់ ដោយពុំមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម ត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិនៃផលិតករហ្វូណូក្រាម។

**ខ.៣ ការផ្ទេរសិទ្ធិផលិតករហ្វូណូក្រាម**

ការផ្ទេរសិទ្ធិរបស់ផលិតករហ្វូណូក្រាម គឺអនុវត្តតាមបទបញ្ញត្តិនៃមាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣។

***គ.អង្គភាពទូរផ្សាយ***

**គ.១ និយមន័យ**

អង្គភាពទូរផ្សាយសំដៅលើស្ថានីយ៍វិទ្យុ ស្ថានីយ៍ទូរទស្សន៍ និងស្ថានីយ៍ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប និងអាចជាមធ្យាបាយផ្សេងៗទៀត។[65]

**គ.២ សិទ្ធិអង្គភាពទូរផ្សាយ**

អង្គភាពទូរផ្សាយ មានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ឬហាមឃាត់តតិយជនមិនឲ្យថតចម្លង ឬសិទ្ធិមិនឲ្យធ្វើអាជីវកម្ម នូវកម្មវិធីរបស់ខ្លួនក្នុងគោលដៅដើម្បីលក់ ឬចាក់ផ្សាយ ការចែកចាយ ការដាក់ជួលជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីផ្សាយរបស់ស្ថានីយ៍សាមី។

---

[63] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤៦

[64] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៤៤

[65] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា២ ចំណុច ឌ

ឧទាហរណ៍៖ កម្មវិធីទូរទស្សន៍(PNN TV)មិនអាចអោយទូរទស្សន៍ណាមួយក្នុងស្រុកមកផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតពី(PNN TV) នោះទេ។

**គ.៣ ការផ្ទេរសិទ្ធិអង្គភាពទូរផ្សាយ**

ការផ្ទេរសិទ្ធិរបស់អង្គភាពទូរផ្សាយ គឺអនុវត្តតាមបញ្ញត្តិនៃមាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣។

សរុបមក ការផ្ទេរសិទ្ធិ អ្នកសម្តែង ផលិតករហ្វូណូក្រាម អង្គភាពទូរផ្សាយអាចផ្ទេរសិទ្ធិបេតិកភណ្ឌបានតាមរយៈ ការផលិតឡើងវិញ ផលិតបន្ត និងការផ្សព្វផ្សាយជាសាធារណៈ។

រូបភាពនៃការផ្ទេរសិទ្ធិអាចដូចជា៖

- តាមរយៈកិច្ចសន្យា ឬផ្តល់អាជ្ញាប័ណ្ណ
- អាចផ្ទេរទៅ ទាយាទរបស់ខ្លួន ឬអាចប្រគល់ជូនតតិយជន តាមបទបញ្ញត្តិ នៃមតកសាសន៍
- អាចផ្ទេរសិទ្ធិទាំងស្រុង ឬផ្ទេរជាភាគខ្លះបាន ដើម្បីធ្វើអាជីវកម្មរបស់ អ្នកសម្តែង ផលិតករហ្វូណូក្រាម អង្គភាពទូរផ្សាយ ទទួលបានកម្រៃពីការផ្ទេរសិទ្ធិនេះអនុលោមតាមប្រការទាំងឡាយនៃកិច្ចសន្យា។

### ៣.១.៣ ស្នាដៃដែលទទួលបាននូវការការពារ

ស្នាដៃដែលទទួលបានការការពារមានដូចជា៖

- ការថតបទចម្រៀង ការសម្តែងរឿង ការច្រៀង ការរាំ ការប្រគុំតន្ត្រី ឬបង្ហាញតាមមធ្យោបាយផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទំលាប់ អក្សរសាស្ត្រ ការអប់រំ ឬវិទ្យាសាស្ត្រ
- ការសម្តែងសៀក សម្តែងកាយវិការផ្សេងៗ
- ការថតជាសម្លេង ដូចជា ការថតជាCD ឬDVD
- កម្មវិធីចាក់ផ្សាយតាមទូរទស្សន៍ ដូចជាការបង្កើតកម្មវិធីអប់រំ កម្មវិធីកំសាន្ត កម្មវិធីពិភាក្សាវែកញែកពីតថភាពសង្គម ជាដើម។

## ៣.២ លក្ខខណ្ឌដើម្បីទទួលបាននូវការការពារ

### ៣.២.១ លក្ខខណ្ឌគ្រឹះ

យោងតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣ ស្នាដៃមួយដើម្បីអាចទទួលបាននូវការកាពារនោះ គឺស្នាដៃនោះត្រូវតែជាស្នាដៃដើម ហើយស្នាដៃនោះត្រូវតែកើតឡើងពីគំនិតប្រាជ្ញាផ្ទាល់របស់ម្ចាស់ស្នាដៃ។ ឧទាហរណ៍៖ ទូរទស្សន៍CTN

បានបង្កើតកម្មវិធីកំសាន្តមួយដែលបានចាក់ផ្សាយលើកញ្ចក់ទូរទស្សន៍ជារៀងរាល់ចុងសប្តាហ៍ដែលក្នុង កម្មវិធីនោះមានឈ្មោះថារាត្រីកំសាន្ត ដូចនេះកម្មវិធីនេះមិនអាចអោយអង្គភាពទូរផ្សាយដ៏ទៃទៀតមានកម្មវិធីដូចគ្នាទេព្រោះវាជាការរំលោភសិទ្ធិ និងធ្វើឲ្យទស្សនិកជនមានការភ័ន្តច្រឡំ។

### ៣.២.២ លក្ខខណ្ឌតម្រង់

*ក. ការការពារស្នាដៃដោយស្វ័យប្រវត្តិ*

មិនខុសពីស្នាដៃអ្នកនិពន្ធទេ ច្បាប់សិទ្ធិអ្នកនិពន្ធ មិនតម្រូវឲ្យម្ចាស់ស្នាដៃត្រូវតែ ចុះបញ្ជីជាមួយមន្ត្រីកាន់កាប់បញ្ជីឡើយ ពោលគឺម្ចាស់ស្នាដៃអ្នកមានសិទ្ធិជ្រើសរើសមធ្យោបាយសមស្របមួយសម្រាប់ការពារស្នាដៃរបស់ខ្លួន គឺការចុះបញ្ជីដោយស្ម័គ្រចិត្ត នៅក្រសួងវប្បធម៌ និងវិចត្រសិល្បៈក៏បាន ឬមិនចាំបាច់ចុះបញ្ជីដោយគ្រាន់តែតម្កល់( ជាសិទ្ធិដែលទទួលបាននូវកិច្ចការពារដោយស្វ័យប្រវត្តិ) ស្នាដៃនៅក្រសួងដែលទទួលបន្ទុកនេះក៏បាន។

ច្បាប់សិទ្ធិអ្នកនិពន្ធ មិនបានបញ្ញត្តិអំពីលក្ខខណ្ឌ ដើម្បីចុះបញ្ជីស្នាដៃប្រហាក់ប្រហែល ជាស្នាដៃបន្ទាប់បន្សំ ឬស្នាដៃរណបទៅនឹងស្នាដៃអ្នកនិពន្ធ នោះមានន័យថាស្នាដៃប្រហាក់ប្រហែលមិនត្រូវបានបង្កើតឡើងដោយគំនិត និងមនោសច្ចេតនារបស់អ្នកនិពន្ធទាំងស្រុង។ ដូចនេះមុននឹងដាក់ពាក្យសុំចុះបញ្ជី ឬតម្កល់ស្នាដៃប្រហាក់ប្រហែលមានសំណួរមួយចោទសួរថា តើចាំបាច់ត្រូវមានការអនុញ្ញាតពីអ្នកនិពន្ធឬទេ ?

*ខ. ការតម្កល់និងការចុះបញ្ជី*

ច្បាប់នេះត្រូវយកមកអនុវត្តចំពោះ សិទ្ធិអ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូរផ្សាយ។ រាល់ស្នាដៃ ដែលទទួលបាននូវកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ។ ការចុះបញ្ជីធ្វើឡើងដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅពេលដែលម្ចាស់សិទ្ធិបានបំពេញនូវលក្ខខណ្ឌចប់សព្វគ្រប់របស់អាជ្ញាធរមានសមត្ថកិច្ចរួចហើយ ក្រសួងដែលមានសមត្ថកិច្ចចុះបញ្ជីនឹងចេញនូវវិញ្ញាបនប័ត្រដល់ស្នាដៃដែលបានចុះបញ្ជី។

## ៣.៣ សិទ្ធិ និងប្រយោជន៍ដែលទទួលបាន

### ៣.៣.១ សិទ្ធិដែលទទួលបាន

#### *៣.៣.១.១ សិទ្ធិសីលធម៌*

មិនខុសពីសិទ្ធិសីលធម៌នៃស្នាដៃអ្នកនិពន្ធឡើយ ម្ចាស់សិទ្ធិប្រហាក់ប្រហែល ត្រូវបានច្បាប់ការពារមិនឲ្យតតិយជនរំលោភសិទ្ធិសីលធម៌របស់ខ្លួនតាមរយៈ ការដក ឬកែប្រែឈ្មោះលើស្នាដៃ ការបំភ្លើស ការកាត់ខ្លឹមសារនៃស្នាដៃ ឬកែប្រែខ្លឹមសារនៃស្នាដៃ។

### ៣.៣.១.២ សិទ្ធិបេតិកភណ្ឌ

សិទ្ធិបេតិកភណ្ឌ សំដៅលើសិទ្ធិហាមឃាត់តតិយជនមិនឲ្យប្រើប្រាស់ ឬធ្វើអាជីវកម្មលើស្នាដៃដោយពុំមានការអនុញ្ញាតជាមុនពីម្ចាស់ស្នាដៃក្នុងរយៈពេលកំណត់ជាក់លាក់។

- **សិទ្ធិធ្វើអាជីវកម្ម**

ម្ចាស់ស្នាដៃប្រហាក់ប្រហែលមានសិទ្ធិផ្តាច់មុខលើស្នាដៃរបស់ខ្លួន។ ប៉ុន្តែសិទ្ធិនេះជាសិទ្ធិពុំឯករាជ្យពីសិទ្ធិអ្នកនិពន្ធឡើយ។ ដោយហេតុថា ស្នាដៃប្រហាក់ប្រហែលពឹងផ្អែកលើស្នាដៃអ្នកនិពន្ធ ការធ្វើអាជីវកម្មលើស្នាដៃប្រហាក់ប្រហែល ជាទូទៅត្រូវមានការយល់ព្រម ឬសហការពីអ្នកនិពន្ធ។ ឧទាហរណ៍ តារាសម្តែងមានសិទ្ធិផ្តាច់មុខលើការសម្តែងរបស់គាត់ ប៉ុន្តែតារាសម្តែងរូបនោះពុំអាចធ្វើការផ្សព្វផ្សាយ លក់ ឬជួលនូវការសម្តែងរបស់ខ្លួននៅក្នុងបទចម្រៀងដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធបានឡើយ។

ជាទូទៅ សិទ្ធិប្រហាក់ប្រហែលអាចអនុវត្តទៅបានត្រូវមានការអនុញ្ញាតពីសំណាក់ម្ចាស់សិទ្ធិអ្នកនិពន្ធ ដូចនេះដើម្បីការពារអំពើរំលោភសិទ្ធិអ្នកនិពន្ធ ដែលអាចកើតមានបានតាមរយៈការអនុវត្តសិទ្ធិប្រហាក់ប្រហែលយើងមានយន្តការពីរ គឺការគ្រប់គ្រងតាមរយៈការបង្កើតខ្សែសង្វាក់កិច្ចសន្យាទាក់ទងនឹងការអនុវត្តសិទ្ធិរបស់ភាគីពាក់ព័ន្ធ ឬការគ្រប់គ្រងសិទ្ធិរួម។

- **អង្គភាពគ្រប់គ្រងសិទ្ធិរួម**

ដើម្បីធានាការអនុវត្តសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅកម្ពុជាឲ្យប្រកបដោយប្រសិទ្ធិភាព និងជៀសវាងការរំលោភសិទ្ធិអ្នកនិពន្ធ តាមរយៈការអនុវត្តសិទ្ធិប្រហាក់ប្រហែល ម្ចាស់សិទ្ធិទាំងពីរអាចសហការគ្នាបង្កើតស្ថាប័ន គ្រប់គ្រងសិទ្ធិរួមមួយតាមរយៈ កិច្ចសន្យាបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម។[66] ការបង្កើតអង្គភាពនេះ មានគោលដៅចម្បងដើម្បីគ្រប់គ្រងការធ្វើពាណិជ្ជកម្មលើស្នាដៃប្រហាក់ប្រហែល និងការបែងចែកផលប្រយោជន៍សេដ្ឋកិច្ចដែលកើតចេញពីស្នាដៃរវាងអ្នកនិពន្ធ និង ម្ចាស់ស្នាដៃប្រហាក់ប្រហែល។

ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមលើសិទ្ធិអ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម ត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ និងត្រូវទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ចំពោះអង្គភាពគ្រប់គ្រងសិទ្ធិរួមលើសិទ្ធិផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបនៃអង្គភាពទូរផ្សាយត្រូវមានការទទួលស្គាល់ពីក្រសួងពត៌មាន។

[66] អង្គភាពគ្រប់គ្រងសិទ្ធិរួម ជានីតិបុគ្គលដែលមានភារកិច្ចចាត់ចែងការងារស្តីពីលាភការដែលទទួលបានពីការបង្កើតអាជីវកម្មលើស្នាដៃ។

### ៣.៣.១.៣ ការកម្រិតសិទ្ធិ

មិនត្រូវបានចាត់ទុកជាអំពើរំលោភសិទ្ធិប្រហាក់ប្រហែលឡើយ ចំពោះកាតថតសម្លេង ការដកស្រង់ ការសម្ដែងឡើងវិញនូវស្នាដៃ ក្នុងក្របខណ្ឌនៃការប្រើប្រាស់ឯកជន ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាព័ត៌មាន។

មានការអញ្ញត្រកម្ម ពិសេសៗលើស្នាដៃអ្នកសម្ដែង ចំពោះសិទ្ធិផ្ដាច់មុខរបស់អ្នកសម្ដែង មិនអាចអនុវត្តប្រឆាំងនឹងតតិយជន ដែលមានបំណងប្រើប្រាស់ ឬបានប្រើប្រាស់ស្នាដៃខ្លួនបានឡើយ នៅពេលដែលអ្នកសម្ដែងអនុញ្ញាតឲ្យគេថតបញ្ចូល ការសម្ដែងរបស់ខ្លួនក្នុង ហ្វូណូក្រាម មានជារូបភាព ឬសោតទស្សន៍។[67] ដូចគ្នាដែរសិទ្ធិផ្ដាច់មុខនេះមិនអាចអនុវត្តប្រឆាំងនឹងអង្គភាពទូរផ្សាយណាមួយបានឡើយក្នុងករណីដែលមានការថតចម្លង និងការផលិតឡើងវិញត្រូវបានធ្វើឡើងដោយមធ្យោបាយផ្ទាល់ខ្លួនរបស់អង្គភាពនោះ ដើម្បីចាក់ផ្សាយក្នុងកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយនោះក្នុងគោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម។ ប៉ុន្តែស្នាដៃថតចម្លង ឬផលិតឡើងវិញ របស់អង្គភាពទូរផ្សាយនោះត្រូវកម្ទេចចោល អង្គភាពទូរផ្សាយមានសិទ្ធិរក្សាស្នាដៃចម្លងមួយច្បាប់គត់ទុកជាឯកសារ។

ជារួម អ្នកស្ដែង ផលិតករហ្វូណូក្រាម អង្គភាពទូរផ្សាយ មិនអាចហាមឃាត់ ឬពុំចាំបាច់បង់កម្រៃនូវសកម្មភាពទាំងឡាយដូចជា៖[68]

- សេចក្ដីរាយការណ៍ស្ដីពីបច្ចុប្បន្នភាពក្នុងលក្ខខណ្ឌដែលសេចក្ដីរាយការណ៍នោះបានដកស្រង់ជាផ្នែកខ្លីៗពីការសម្ដែង ឬពីខ្លឹមសារហ្វូណូក្រាម ឬពីក្នុងការផ្សាយតាមទូរផ្សាយ
- ការថតចម្លង ដែលធ្វើឡើងសម្រាប់តែប្រើប្រាស់ក្នុងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ
- ការថតចម្លង សម្រាប់បម្រើក្នុងលក្ខខណ្ឌនៃការសិក្សា លើកលែងតែការសម្ដែង ឬហ្វូណូក្រាមដែលផលិតសម្រាប់តែគោលបំណងនៃការសិក្សា
- អាគតដ្ឋានជាសម្រង់ខ្លីៗពីការសម្ដែង ឬហ្វូណូក្រាម ឬកម្មវិធីចាក់ផ្សាយតាមទូរផ្សាយសមស្របតាមទម្លាប់ល្អ ដើម្បីប្រើប្រាស់ក្នុងទិសដៅព័ត៌មាន។
- ការប្រើប្រាស់ផ្សេងៗទៀតដែលជា ករណីលើកលែងពិសេសចំពោះស្នាដៃនានា ដែលទទួលបាននូវកិច្ចការពារសិទ្ធិអ្នកនិពន្ធ ដោយអនុលោមតាមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

[67] ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៥១

[68] ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា ៥០

- ការចាប់យករូបភាពនិងសម្លេង ដើម្បីផ្សព្វផ្សាយបន្តទាំងស្រុងឬភាគខ្លះដោយអង្គភាពទូរផ្សាយស្តីពីបច្ចុប្បន្នភាពនៃពិធីបុណ្យ អង្គប្រជុំ ឬព្រឹត្តិការណ៍នានារបស់ជាតិពីស្ថានីយ៍ដើមក្នុងពេលតែមួយ។

### ៣.៣.២ ផលប្រយោជន៍ដែលទទួលបាន

**❖ ការពារវប្បធម៌**

ការសម្តែង បានបង្ហាញនូវចំណេះដឹងពីទំនៀមទំលាប់ ឬវប្បធម៌ប្រពៃណី។ តាមរយៈការបង្ហាញទាំងនេះវាធ្វើអោយស្នាដៃវប្បធម៌ទាំងនោះមានភាពរស់រវើក និងស្ថិតនៅក្នុងការចងចាំរបស់សាធារណៈជន។ ម៉្យាងទៀត គ្មានជនណាម្នាក់ហ៊ានលួចចម្លងស្នាដៃវប្បធម៌ទាំងនោះឡើយ។

**❖ ផ្តល់នូវទីផ្សារអន្តរជាតិ**

ផ្តល់នូវមធ្យោបាយសម្រាប់ការធ្វើអាជីវកម្មលើទីផ្សារអន្តរជាតិ ការពារផលិតផលហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ជួយបង្កើនឡើងនូវមូលដ្ឋានឧស្សាហកម្ម នៃការផ្សព្វផ្សាយវប្បធម៌ក្នុងប្រទេស និងក្រៅប្រទេស។

### ៣.៣.៣ រយៈពេលនៃការការពារ

រយៈពេលនៃការការពារសិទ្ធិប្រហាក់ប្រហែលក្រោមសន្ធិសញ្ញាទីក្រុង ROME មានរយៈពេល ២០ឆ្នាំចាប់ពីដំណាច់ឆ្នាំនៃការសម្តែង ឬហ្វូណូក្រាមនោះត្រូវបានថតបញ្ចូល ឬការសម្តែងនោះត្រូវបានធ្វើឡើង។ ថ្វីត្បិតតែក្នុងកិច្ចព្រមព្រៀង TRIPS និងសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែង និងហ្វូណូក្រាម ហៅកាត់ថា WPPT បានចែងពីរយៈពេលការការពារសិទ្ធិអ្នកសម្តែង និងផលិតករហ្វូណូក្រាម ចំនួន៥០ឆ្នាំ ចាប់ពីថ្ងៃដែលបានថតបញ្ចូលការសម្តែង។ ក្រោមកិច្ចព្រមព្រៀង TRIPS សិទ្ធិអង្គភាពទូរផ្សាយត្រូវបានការពាររយៈពេល ២០ឆ្នាំ ចាប់ពីថ្ងៃចាក់ផ្សាយ។

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ បានកំណត់យករយៈពេល ៥០ឆ្នាំដូចៗគ្នា ក្នុងចំណោមសិទ្ធិប្រហាក់ប្រហែលទាំងបីនោះមានដូចជា៖

- រយៈពេលនៃការការពារសិទ្ធិអ្នកសម្តែង គឺ៥០ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម ឬក្នុងករណីដែលពុំបានថតការសម្តែងបញ្ចូលក្នុងហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ប្រក្រតិទិន ដែលការសម្តែងបានប្រព្រឹត្តទៅ។[69]

---

[69] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៥២ ចំណុច១

- រយៈពេលនៃការការពារផលិតករហ្វូណូក្រាម គឺ៥០ឆ្នាំគិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិន ដែលបានបោះពុម្ពផ្សាយហ្វូណូក្រាម ឬក្នុងករណីពុំបានបោះពុម្ពផ្សាយហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិន ដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាម។[70]
- រយៈពេលនៃការការពារកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយ គឺ៥០ឆ្នាំគិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិនដែលកម្មវិធីបានផ្សាយ។[71]

### ៣.៣.៤ វិធានការប្រឆាំងការរំលោភបំពានសិទ្ធិប្រហាក់ប្រហែល

ជាទូទៅលក្ខខណ្ឌនៃការទាមទារសំណង សម្រាប់ការរំលោភបំពានលើសិទ្ធិប្រហាក់ប្រហែល មានលក្ខណៈស្រដៀងគ្នានឹងការរំលោភបំពានលើម្ចាស់សិទ្ធិអ្នកនិពន្ធដែលបានអធិប្បាយខាងលើ ដូចជា វិធានការបណ្តោះអាសន្ន សំណងរដ្ឋប្បវេណី ទោសព្រហ្មទណ្ឌ វិធានការតាមច្រកព្រំដែននិង វិធានការផ្សេងៗទៀត។

❖ **សំណងរដ្ឋប្បវេណី**

បុគ្គលណាដែលទទួលរងនូវការរលោភសិទ្ធិ ជាសិទ្ធិអ្នកនិពន្ធ ឬសិទ្ធិប្រហាក់ប្រហែលក្តី បុគ្គលនោះមានសិទ្ធិប្តឹងទៅតុលាការដើម្បីធ្វើការហាមឃាត់ និងបញ្ឈប់សកម្មភាពរំលោភបំពាន ដែលកើតឡើង។ បើការរំលោភបំពាននោះនៅតែបន្តដើមចោទជាម្ចាស់ស្នាដៃមានសិទ្ធិទាមទារ សំណងជម្ងឺចិត្ត សងការខូចខាត និងប្រគល់មកវិញនូវភស្តុតាង។[72]

❖ **ទោសព្រហ្មទណ្ឌ**

- **ទណ្ឌកម្មនៃការផលិត ឬផលិតឡើងវិញ**

ការផលិត ឬផលិតឡើងវិញដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ដល់ ១២(ដប់ពីរ)ខែ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[73]

---

[70] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមាត្រា៥៣ ចំណុច២

[71] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមាត្រា៥៣ ចំណុច៣

[72] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមាត្រា៥៧

[73] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមាត្រា៦៥ កថាខណ្ឌ១

- **ទណ្ឌកម្មនៃការនាំចូល ឬនាំចេញ**

ការនាំចូល ឬនាំចេញនូវហ្វូណូក្រាម កាសែត ឬការសែតវិដេអូ ដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬនិងត្រូវផ្តន្ទាទោស ជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ។ បើមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង។[74]

- **ទណ្ឌកម្មនៃការចាក់ផ្សាយតាមទូរផ្សាយ**

ការចាក់ចាក់ផ្សាយតាមទូរផ្សាយតាមទូរផ្សាយ ដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង។[75]

[74] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៥ កថាខណ្ឌ២

[75] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មាត្រា៦៥ កថាខណ្ឌ៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពី បានសិក្សាលើប្រធានបទ ការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅកម្ពុជារួចមក យើងសង្កេតឃើញថា វិស័យកម្មសិទ្ធិបញ្ញាមានសារៈសំខាន់ណាស់ព្រោះស្ទើរគ្រប់វត្ថុទាំងអស់នៅជុំវិញខ្លួនយើងសុទ្ធតែជាលទ្ធផលដែលកើតចេញពីគំនិតបញ្ញារបស់មនុស្ស។ ជាការពិតបញ្ហាកម្មសិទ្ធិសិទ្ធិបញ្ញា គឺជាបញ្ហាមួយដែលប្រទេសជាច្រើនកំពុងជួប ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ ដោយសង្កេតឃើញថាការលួចចម្លងស្នាដៃដើមជាច្រើនរបស់ម្ចាស់ស្នាដៃ គឺជាសកម្មភាពមួយដែលអ្នកនិពន្ធជាច្រើនកំពុងជួបផលវិបាក ហើយពិបាកនឹងរកដំណោះស្រាយ។

ដោយមើលឃើញពីផលវិបាកនេះ ហើយទើបកម្ពុជាបានចូលជាសមាជិកនៃកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ដូចជាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥(កិច្ចព្រមព្រៀង TRIPS ) អនុសញ្ញាទៅក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៨ អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ ពិធីសារទីក្រុងម៉ាឌ្រីតជាអន្តរជាតិ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ សន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ និង កិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពីការចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧។ អនុលោមតាមកិច្ចព្រមព្រៀង TRIPS កម្ពុជាបានបង្កើតច្បាប់ជាតិមួយ គឺច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានចូលជាធរមាននៅឆ្នាំ២០០៣។ ច្បាប់នេះមានគោលបំណងធានាការគោរព សិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែលនៅកម្ពុជា និងការពារនូវផលិតផលវប្បធម៌ ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ដើម្បីរួមចំណែកការអភិវឌ្ឍន៍លើវិស័យវប្បធម៌។ ស្នាដៃដែលត្រូវទទួលបានការការពារ និងមានស្នាដៃមួយចំនួនដែលមិនទទួលបាននូវការការពារត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់នេះ។ ម្យ៉ាងទៀត ពាក់ព័ន្ធទៅនឹងសិទ្ធិទាំងឡាយ ដែលជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធក៏ត្រូវបានបញ្ជាក់ផងដែរ។ ដូចនេះ រាល់អំពើរំលោភបំពានដែលប៉ះពាល់ដល់សិទ្ធិម្ចាស់ស្នាដៃដូចកំណត់ក្នុងច្បាប់នេះ និងត្រូវចាត់ទុកជាអំពើខុសច្បាប់ ហើយត្រូវទទួលនូវទណ្ឌកម្មលើអំពើដែលខ្លួនបានប្រព្រឹត្ត តួយ៉ាង អាចជាការទទួលនូវសំណងរដ្ឋប្បវេណី ឬអាចឈានដល់ការទទួលទោសព្រហ្មទណ្ឌផងដែរ។

តាមការស្រាវជ្រាវកន្លងមកយើងសង្កេតឃើញថា ការលួចចម្លងស្នាដៃ គឺជាបញ្ហាមួយដែលអ្នកនិពន្ធ ឬម្ចាស់ស្នាដៃបានជួបប្រទះជាយូរឆ្នាំមកហើយ វាជាបញ្ហាក្តៅគគុកមួយដែលប្រទេសជាច្រើនកំពុងរកវិធានការដើម្បីទប់ស្កាត់។ ការលួចចម្លងនេះធ្វើអោយម្ចាស់ស្នាដៃបាត់បង់នូវកម្លាំងចិត្ត

ក្នុងការបង្កើតស្នាដៃថ្មី បាត់បង់នូវប្រាក់ចំណូលដែលកើតចេញពីស្នាដៃរបស់ខ្លួន បាត់បង់កិត្តិយសកេរ្តិ៍ឈ្មោះ។ ទង្វើនេះវាបានធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់វិស័យវប្បធម៌របស់ប្រទេសកម្ពុជា។

ដូច្នោះហើយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក៏បានបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមមួយដើម្បីជួយការពារ និងគ្រប់គ្រងដល់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ បន្ថែមពីនេះ តុលាការជាស្ថាប័នមួយដែលមានសមត្ថកិច្ចដោះស្រាយវិវាទ ក្នុងករណីដែលមានការរំលោភបំពានផ្សេងៗ។ ក្នុងមានខ្ញុំជាយុវជនជំនាន់ក្រោយ ដែលធ្លាប់បានសិក្សាមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា ហើយបានយល់ដឹងពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានេះ នាងខ្ញុំមិនគាំទ្រនូវអំពើរំលោភសិទ្ធិគ្រប់រូបភាព ព្រោះវាជាអំពើមួយដែលវាបានទៅបំផ្លាញនូវប្រយោជន៍អ្នកដទៃ ដែលជាម្ចាស់ស្នាដៃពិតប្រាកដ។ ពិសេសធ្វើអោយម្ចាស់ស្នាដៃទាំងនោះបាត់បង់នូវកម្លាំងចិត្ត បាត់បង់តម្លៃក្នុងការបង្កើតស្នាដៃថ្មីរបស់ខ្លួន។ ការធ្វើបែបនេះជាអំពើមួយដែលធ្វើអោយបាត់បង់នូវធនធានមនុស្សក្នុងសង្គម ហើយបំផ្លាញវប្បធម៌ ប្រពៃណីខ្មែរផងដែរ។

ជាចុងក្រោយនាងខ្ញុំសូមលើកទឹកចិត្ត ដល់អ្នកនិពន្ធទាំងអស់ដែលកំពុងតែមមាញឹកក្នុងការបង្កើតស្នាដៃថ្មី សូមបន្តរិះរកនូវស្នាដៃណាដែលល្អៗទុកអោយកូនខ្មែរជំនាន់ក្រោយបានដឹង និងជាប្រយោជន៍ជួយលើកស្ទួយដល់វិស័យវប្បធម៌ខ្មែរឲ្យមានភាពរីកចម្រើន។ ពិសេស ការខិតខំប្រឹងប្រែង និងសមិទ្ធិផលរបស់អ្នកនិពន្ធទាំងនោះ គឺជាកម្លាំងចិត្តដល់មនុស្សជំនាន់ក្រោយដែលមានបំណងចង់ក្លាយជាអ្នកនិពន្ធផងដែរ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការបកស្រាយខាងលើបានបង្ហាញថា ប្រទេសកម្ពុជាជាប្រទេសមួយដែលបានយកចិត្តទុកដាក់លើកម្មសិទ្ធិបញ្ញានេះ ដោយមានក្រសួងពាក់ព័ន្ធមួយចំនួនជាស្ថាប័នរដ្ឋជួយសម្រួលដល់ការអនុវត្តសិទ្ធិរបស់ម្ចាស់តក្កកម្ម ឬម្ចាស់ស្នាដៃ។ ប៉ុន្តែការអនុវត្តជាក់ស្តែង គេសង្កេតឃើញថា ការអនុវត្តច្បាប់នៅមានកម្រិតនៅឡើយ។ ហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថាប័នដែលពាក់ព័ន្ធនានាគួរតែៈ

- បំពេញបន្ថែមនូវបទបញ្ញត្តិដើម្បីបំពេញកង្វះខាតដែលតែងតែកើតមាននៅក្នុងសង្គមបច្ចុប្បន្ន
- លើកទឹកចិត្តដល់អ្នកនិពន្ធ ឬម្ចាស់ស្នាដៃតាមរយៈការផ្តល់ជារង្វាន់លើកទឹកចិត្ត ដើម្បីឲ្យអ្នកនិពន្ធ ឬម្ចាស់ស្នាដៃទាំងនោះមានកម្លាំងចិត្តបន្តបង្កើតនូវស្នាដៃថ្មីៗជាច្រើនទៀត
- ចាត់វិធានការអោយបានតឹងរឹងចំពោះជនដែលបានយកស្នាដៃរបស់អ្នកដ៏ទៃទៅលួចចម្លង កែប្រែដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាតពីម្ចាស់ស្នាដៃ
- លើកកម្ពស់ស្នាដៃក្នុងស្រុក ដើម្បីឲ្យអ្នកនិពន្ធ ឬម្ចាស់ស្នាដៃទទួលបាននូវប្រាក់ចំណូលគ្រប់គ្រាន់ និងមានថវិកាអាចផលិតស្នាដៃក្រោយៗទៀតទុកអោយមនុស្សជំនាន់ក្រោយបានដឹង។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

**ក. លិខិតបទដ្ឋានគតិយុត្ត**

១. ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣

២. ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម-និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

៣. អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨

**ខ. សៀវភៅ និងឯកសារ**

១. ឯកសារមេរៀននីតិកម្មសិទ្ធបញ្ញា ឆ្នាំ ២០០៩ (**សាស្ត្រាចារ្យបណ្ឌិត ឃឹម គីរី**)

២. នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០២០-២០២១ (**សាស្ត្រាចារ្យ ទេព សុខ**)

៣.សេចក្តីផ្តើមនៃការសិក្សានីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣ (**លឹម យូសួ**)

៤. នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៤ (**សាស្ត្រាចារ្យ កាន់ សុទ្ធប៉ូលីន**)

៥. សិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ី បោះពុម្ពផ្សាយជាភាសាខ្មែរលើកទី១ ឆ្នាំ២០០៩ ភ្នំពេញ (**និពន្ធដោយ តាម៉ុតស៊ូ ហូហ្សិយមី**)

៦. នីតិកម្មសិទ្ធបញ្ញា ឆ្នាំ ២០១៣ (**ឥន យឿន** និង **អ៊ុក វណ្ណារ័ត្ន**)

៧. កម្រងច្បាប់ពាណិជ្ជកម្ម និង ច្បាប់កម្មសិទ្ធិបញ្ញា ភាគ១

**គ. គេហទំព័រ**

http://www.cambodiaip.gov.kh (30 April 2021)
http://www.mcfa.gov.kh/ (30 April 2021)

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១**

១. ច្បាប់រដ្ឋធម្មនុញ្ញ

២. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣. ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣

៤. ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម-និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

**ឧបសម្ព័ន្ធ២**

៥. ប្រកាសលេខ ៦០ ប្រ.ក ចុះថ្ងៃ១៨ ខែមិនា ឆ្នាំ២០០៣

៦. ប្រកាសលេខ ១១២ ប្រ.ក ចុះថ្ងៃ០៥ ខែកក្កដា ឆ្នាំ២០១៦

៧. អនុក្រឹត្យលេខ១៤២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨

# ឧបសម្ព័ន្ធ១

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ ៣/០៥
ថ្ងៃទី ... ម៉ោង ...
ប្រគល់ទៅ ...

# ច្បាប់

# ស្ដីពី

# សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងការពារនូវផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាមនិងអង្គភាពផ្សាយ សំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវ ស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ ។

**មាត្រា ២.–**

ក្នុងន័យនៃច្បាប់នេះ ពាក្យមួយចំនួនដូចខាងក្រោមមានអត្ថន័យដូចតទៅ :

ក-**ស្នាដៃ** ជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

ខ-**អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

គ-**ការសម្តែង** ជាការបញ្ចេញស្នាដៃលើឆាកដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬបង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ ការអប់រំ ឬវិទ្យាសាស្ត្រ ។

ឃ-**ការសូត្រ** ជាការបញ្ចេញសម្លេងដោយការនិយាយ ការអាននិងការសូត្រនូវស្នាដៃផ្សេងៗ ។

ង-**អ្នកសម្តែង** ជាសិល្បករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជនដែលធ្វើការសម្តែង ។

ច-**ប្រព័ន្ធទិន្នន័យ** ជាសំណុំព័ត៌មាន អត្ថបទ លេខ ឌីយ៉ាក្រាម ដែលបង្កើតនិងស្រាវជ្រាវដោយប្រព័ន្ធកុំព្យូទ័រ ។

ឆ-**ស្នាដៃសោតទស្សន៍**· ជាស្នាដៃបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឱ្យមើលឃើញបាន ទោះបីមានឬពុំមានបញ្ចូលសម្លេង ហើយបើមានបញ្ចូលសម្លេងគឺអាចស្តាប់ឮសូរសម្លេងបាន ។

ជ-**ការផ្សាយ** ជាការផ្សាយសម្លេង រូបភាព ឯកសារ ឬសារនានាគ្រប់ប្រ-

ភេទតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ឈ-ការផ្សព្វផ្សាយជាសាធារណៈ:** ជាការផ្សាយតាមខ្សែ ឬគ្មានខ្សែក្រៅរង្វង់គ្រួសារនូវរូបភាព ឬសម្លេង ឬរូបភាពជាមួយសម្លេងនៃស្នាដៃណាមួយ ដែលអាចឱ្យសាធារណជនទទួលបាននៅទីកន្លែងដើម ឬទីកន្លែងដទៃទៀត ដោយមិនគិតថា ជននោះទទួលឬមិនទទួលនូវរូបភាព ឬសម្លេងនោះ ក្នុងពេលនិងទីកន្លែងជាមួយគ្នា ឬក្នុងពេលនិងទីកន្លែងខុសគ្នាតាមការជ្រើសរើសផ្ទាល់ខ្លួនរបស់គេ ។

**ញ-ហ្វូណូក្រាម** ជាវត្ថុដែលបានថតបញ្ចូលសម្លេងនៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសម្លេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត ។

**ដ-ផលិតករហ្វូណូក្រាម** ជាជនដែលផលិតហ្វូណូក្រាម ដូចមានចែងនៅក្នុងចំណុច ញ ។

**ឋ-កម្មវិធីកុំព្យូទ័រ** ជាសំណុំនៃសេចក្តីណែនាំដែលធ្វើរៀងតាមអក្សរ ឬលេខកូដ ឬគំនូសបំព្រួញ ឬតាមទម្រង់ណាមួយជាហេតុធ្វើឱ្យគេបំពេញបាន ឬទទួលបាននូវកិច្ចការ ឬលទ្ធផលពិសេសណាមួយតាមមធ្យោបាយកុំព្យូទ័រ ឬតាមវិធីសាស្ត្រអេឡិចត្រូនិច ដើម្បីបំពីកិច្ចការពត៌មានបាន កាលណាកម្មវិធីនោះត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ ។

**ឌ-ការផលិតឡើងវិញ** ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់តាមមធ្យោបាយ ឬទម្រង់ណាមួយគិតបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាមដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នតាមទម្រង់អេឡិចត្រូនិច ។

**ឍ-អង្គភាពទូរផ្សាយ** ពីស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ណ-សិទ្ធិប្រហាក់ប្រហែល** ជាសិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ ។

**មាត្រា ៣.–**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានកិច្ចការពារពីច្បាប់នេះមានស្នាដៃអ្នកនិពន្ធ

ស្នាដៃអ្នកសម្តែង ហ្វូណូក្រាមនិងការផ្សាយតាមទូរផ្សាយ ។

**១-ស្នាដៃអ្នកនិពន្ធសំដៅ :**

ក-ស្នាដៃដែលបង្កើតឡើងដោយជនមានសញ្ជាតិខ្មែរ ឬជនដែលមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាននីតិបុគ្គល ហើយត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ហើយដែលត្រូវបានយកមកបោះពុម្ពផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងអំឡុង ៣០(សាមសិប)ថ្ងៃ ។

គ-ស្នាដៃសោតទស្សន៍ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ-ស្នាដៃស្ថាបត្យកម្មដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗទៀតដែលភ្ជាប់ទៅនឹងអាគារ ឬរចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង-ស្នាដៃដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ ។

**២-ស្នាដៃអ្នកសម្តែងសំដៅ :**

ក-ស្នាដៃរបស់អ្នកសម្តែងដែលមានសញ្ជាតិខ្មែរ ។

ខ-ស្នាដៃរបស់អ្នកសម្តែងដែលពុំមានសញ្ជាតិខ្មែរ តែការសម្តែងនោះ :

- បានប្រព្រឹត្តឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ
- បានថតបញ្ចូលជាហ្វូណូក្រាមដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ឬ
- ពុំទាន់បានថតបញ្ចូលជាហ្វូណូក្រាម ប៉ុន្តែបានផ្សព្វផ្សាយតាមទូរ-ផ្សាយដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ។

**៣-ហ្វូណូក្រាមសំដៅ :**

ក-ហ្វូណូក្រាមរបស់ផលិតករមានសញ្ជាតិខ្មែរ ។

ខ-ហ្វូណូក្រាម ដែលបានថតបញ្ចូលសូរសម្លេងជាលើកដំបូងនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។

គ-ហ្វូណូក្រាម ដែលបានផលិតផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**៤-ការផ្សាយតាមទូរផ្សាយសំដៅ :**

ក-ការផ្សាយនៃអង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ការផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅក្នុងព្រះរាជណាចក្រកម្ពុជា ។

បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ចំពោះអ្នកសម្តែង ផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយដែលអាចទទួលនូវកិច្ចការពារតាមសន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

## ជំពូកទី ២
## សិទ្ធិអ្នកនិពន្ធ
### ផ្នែកទី ១
### ស្នាដៃ

**មាត្រា ៤.-**

ត្រូវចាត់ទុកថាជាស្នាដៃដើមគឺស្នាដៃទាំងឡាយដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធនៃស្នាដៃនោះ ។

**មាត្រា ៥.-**

ស្នាដៃមួយទោះបីពុំទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី ស្នាដៃនោះត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិតប្រាជ្ញាអ្នកនិពន្ធ ។

**មាត្រា ៦.-**

ស្នាដៃសហការជាស្នាដៃដែលមានរូបវន្តបុគ្គលច្រើននាក់ចូលរួមសហការដើម្បី

បង្កើតស្នាដៃនោះ ។

ស្នាដៃបន្តជាស្នាដៃបង្កើតឡើងផ្អែកតាមស្នាដៃដើម តាមរយៈការបកប្រែ ការយកលំនាំតាមឬការសម្រួល ។

ស្នាដៃសមូហភាពគឺជាស្នាដៃបង្កើតឡើងដោយរូបវន្តបុគ្គលច្រើននាក់ តាមគំនិតផ្តួចផ្តើមរបស់រូបវន្តបុគ្គលម្នាក់ដែលបានធ្វើការបោះពុម្ពផ្សាយក្រោមការដឹកនាំនិងក្នុងនាមរបស់បុគ្គលនោះ ។

មាត្រា ៧.–

ស្នាដៃទាំងឡាយ យោងតាមមាត្រា ៣ ដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រនិងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរនិងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ-ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ-ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង-ការសម្តែងសៀកនិងការសម្តែងកាយវិការ ។

ច-ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ-ស្នាដៃសោតទស្សន៍ ។

ជ-ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូបឬសិល្បៈអនុវត្ត ។

ឈ-ស្នាដៃថតរូបនិងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ប្រាមលេខា ឬវិទ្យាសាស្ត្រនានា ។

ឋ-កម្មវិធីកុំព្យូទ័រនិងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឌ-ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

មាត្រា ៨.-

ស្នាដៃបន្តដែលនៅក្នុងនោះមាន ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអស្នាដៃផ្សេងទៀត ឬការចងក្រងជាប្រព័ន្ធទិន្នន័យ ទោះបីជាក្នុងម៉ាស៊ីនដែលអាចអានបាន ឬក៏ជាទម្រង់ផ្សេងទៀត ក៏ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះដែរ ។

កិច្ចការពារស្នាដៃណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនធ្វើឱ្យបាត់បង់សិទ្ធិចំពោះកិច្ចការពារស្នាដៃដើមដែលត្រូវបានបញ្ចូល ឬប្រើប្រាស់សម្រាប់ការបង្កើតស្នាដៃថ្មី ។

មាត្រា ៩.-

ចំណងជើងនៃស្នាដៃណាមួយដែលបង្ហាញពីលក្ខណៈស្ទួលនៃស្នាដៃដើម ចំណងជើងនោះត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ដូចគ្នានឹងស្នាដៃនោះដែរ ។

ស្នាដៃមួយ ទោះបីលែងទទួលបាននូវកិច្ចការពារពីច្បាប់តាមមាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់នេះក៏ដោយ ក៏គ្មានបុគ្គលណាម្នាក់មានសិទ្ធិប្រើប្រាស់ចំណងជើងនៃស្នាដៃនោះសម្រាប់ធ្វើជាចំណងជើងនៃស្នាដៃមួយផ្សេងទៀត ជាហេតុបង្កឱ្យមានការភ័ន្តច្រឡំ ។

មាត្រា ១០.-

ស្នាដៃដែលមិនស្ថិតនៅក្រោមការការពារនៃច្បាប់នេះមាន :

ក-រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យនិងលិខិតបទដ្ឋានផ្លូវការនានា ។

ខ-ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ ។

គ-សេចក្ដីសម្រេច សាលក្រមឬសាលដីកាផ្សេងៗរបស់តុលាការ ។

ឃ-អត្ថបទបកប្រែជាភាសាបរទេសនៃអត្ថបទក្នុងចំណុច ក ចំណុច ខ និង ចំណុច គ ខាងលើក្នុងមាត្រានេះ ។

ង-គំនិត នីតិវិធី ប្រព័ន្ធ របៀបប្រតិបត្តិការ ទស្សនៈ គោលការណ៍ ការរុករកឃើញឬទិន្នន័យសាមញ្ញ ទោះបីត្រូវបានផ្សព្វផ្សាយ អត្ថាធិប្បាយ ពន្យល់ឬមានក្នុងស្នាដៃណាមួយក៏ដោយ ។

## ផ្នែកទី ២

## អ្នកនិពន្ធ

**មាត្រា ១១.–**

ឋានៈជាអ្នកនិពន្ធគឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១២.–**

សហអ្នកនិពន្ធគឺជាម្ចាស់កម្មសិទ្ធិលើស្នាដៃសហការ ។ សហអ្នកនិពន្ធត្រូវតែប្រើសិទ្ធិរបស់ខ្លួនយោងតាមការឯកភាពជាឯកច្ឆន្ទនិងជាលាយលក្ខណ៍អក្សរ ។ នៅពេលមិនឯកភាពគ្នាត្រូវធ្វើពាក្យប្ដឹងទៅតុលាការ ។

**មាត្រា ១៣.–**

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់ស្នាដៃសមូហភាពដែលឈ្មោះបុគ្គលនោះត្រូវគេផ្សាយជាចំហក្នុងពេលធ្វើការផ្សព្វផ្សាយស្នាដៃ បុគ្គលនោះគឺជាអ្នកទទួលបាននូវសិទ្ធិអ្នកនិពន្ធ លើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១៤.–**

អ្នកនិពន្ធស្នាដៃ រហស្សនាម ឬអនាមិកជាអ្នកទទួលបានសិទ្ធិទាំងឡាយលើស្នាដៃនោះ ។

ដរាបណាអ្នកនិពន្ធនោះនៅតែពុំទាន់បង្ហាញឱ្យគេដឹងពីអត្តសញ្ញាណខ្លួន និងនៅពុំទាន់បង្ហាញភស្តុតាងដែលបញ្ជាក់ឱ្យដឹងពីឋានៈខ្លួន ដរាបនោះអ្នកនិពន្ធនៅតែត្រូវបានជំនួសមុខដោយអ្នកបោះពុម្ពឬអ្នកផ្សព្វផ្សាយលើកដំបូង ដែលនឹងត្រូវផ្តល់សិទ្ធិឱ្យអនុវត្តនិងការពារសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ ។ អ្នកបោះពុម្ពផ្សាយ ឬអ្នកផ្សព្វផ្សាយលើកដំបូងត្រូវមានកិច្ចសន្យាបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកនិពន្ធ រហស្សនាម ឬអានាមិក ។

វាក្យខ័ណ្ឌទី ២ មិនអាចអនុវត្តបានឡើយ បើរហស្សនាមដែលអ្នកនិពន្ធបានជ្រើសរើសយកនោះត្រូវបានផ្សាយឈ្មោះអ្នកនិពន្ធពិតប្រាកដជាចំហ ។

## មាត្រា ១៥.–

រូបវន្តបុគ្គលម្នាក់ឬច្រើននាក់ដែលបានបង្កើតស្នាដៃសោតទស្សន៍តាមគំនិតប្រាជ្ញារបស់ខ្លួន រូបវន្តបុគ្គលនោះត្រូវបានទទួលឋានៈជាអ្នកនិពន្ធស្នាដៃសោតទស្សន៍ ។

លើកលែងតែមានភស្តុតាងផ្ទុយ សហអ្នកនិពន្ធនៃស្នាដៃសោតទស្សន៍មាន :

ក-សមិទ្ធិករ ។

ខ-អ្នកនិពន្ធសេណារីយ៉ូ ។

គ-អ្នកនិពន្ធដោយយកលំនាំតាម ។

ឃ-អ្នកនិពន្ធអត្ថបទនិយាយ ។

ង-អ្នកនិពន្ធបទភ្លេងមាន ឬគ្មានទំនុកច្រៀងដែលជាបទភ្លេងត្រូវបានបង្កើតឡើងជាពិសេសសម្រាប់តែជាប្រយោជន៍ស្នាដៃនោះ ។

ច-អ្នកនិពន្ធសិល្បៈគំនូរសម្រាប់ស្នាដៃគំនូរជីវចល ។

## មាត្រា ១៦.–

អ្នកនិពន្ធស្នាដៃគឺជាអ្នកមានសិទ្ធិផ្តើមជាម្ចាស់លើសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។ ក្នុងករណីដែលអ្នកនិពន្ធបានបង្កើតស្នាដៃដើម្បីជាប្រយោជន៍ឱ្យដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជានិយោជកក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាការងារ និងកិច្ចសន្យាការប្រើប្រាស់ស្នាដៃ សិទ្ធិបេតិកភណ្ឌលើស្នាដៃនោះត្រូវបានចាត់ទុកថាបានផ្ទេរជូននិយោជក លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យាទាំងនោះ ។

**មាត្រា ១៧.–**

សមិទ្ធិករស្នាដៃសោតទស្សន៍មួយដែលមានការចូលរួមវិភាគទានពីសហអ្នកនិពន្ធបង្កើតស្នាដៃតាមកិច្ចសន្យាដោយមិនរាប់បញ្ចូលអ្នកនិពន្ធស្នាដៃភ្ជាប់ភ្លេង សមិទ្ធិករនោះទទួលបាននូវសិទ្ធិបេតិកភណ្ឌរបស់សហអ្នកនិពន្ធ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យា ។ ប៉ុន្តែសហអ្នកនិពន្ធនោះ នៅតែរក្សាសិទ្ធិបេតិកភណ្ឌរបស់គេបានតាមទំហំនៃការប្រើប្រាស់វិភាគទាន ក្នុងករណីការរួមវិភាគទាននោះបានប្រព្រឹត្តឡើងដាច់ដោយឡែកពីការបង្កើតស្នាដៃសោតទស្សន៍ ។

## ផ្នែកទី ៣
## សិទ្ធិអ្នកនិពន្ធ

**មាត្រា ១៨.–**

អ្នកនិពន្ធស្នាដៃជាអ្នកទទួលបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះ ហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវតែទទួលស្គាល់ ។

សិទ្ធិនេះមានសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌ ។

**មាត្រា ១៩.–**

សិទ្ធិសីលធម៌របស់អ្នកនិពន្ធគឺជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន មិនអាចរឹបអូសបាននិងមិនអាចផុតអាជ្ញាយុកាល ។ សិទ្ធិនេះអាចត្រូវបានផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ ដោយមូលហេតុអ្នកនិពន្ធបានទទួលមរណភាពឬប្រគល់ជូនតតិយជនបាន ដោយយោងតាមបទប្បញ្ញត្តិមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

**មាត្រា ២០.–**

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានបីចំណុចដូចខាងក្រោម :

ក-អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀបនិងពេលវេលានៃ

ការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ ។

ខ-អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន ។

គ-អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំភ្លៃ ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារ ជាហេតុធ្វើឱ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះខ្លួន ។

មាត្រា ២១.-

សិទ្ធិបេតិកភណ្ឌជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួន តាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈនិងការបង្កើតស្នាដៃបន្ត ។

លើកលែងតែក្នុងករណីនៃបទប្បញ្ញត្តិចែងក្នុងមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់នេះ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខធ្វើដោយខ្លួនឯងឬអនុញ្ញាតឱ្យគេធ្វើកិច្ចការដូចតទៅ :

ក-ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួន ។

ខ-ការយកលំនាំតាមឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ ។

គ-ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃសោតទស្សន៍ ឬស្នាដៃថតបញ្ចូលជាហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង ។

ឃ-ការចែកចាយជាសាធារណៈតាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ ។

ង-ការនាំចូលក្នុងប្រទេសនូវស្នាដៃចម្លងចេញពីស្នាដៃរបស់សាមីខ្លួនដែលជាអ្នកនិពន្ធ ។

ច-ការផលិតស្នាដៃឡើងវិញ ។

ឆ-ការសម្តែងស្នាដៃជាសាធារណៈ ។

ជ-ការបង្ហាញស្នាដៃជាសាធារណៈ ។

ឈ-ការផ្សាយស្នាដៃតាមរូបផ្សាយ ។

ញ-ការផ្សព្វផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀត ។

សិទ្ធិដាក់ជួលដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះការ

ផ្តលកម្មវិធីកុំព្យូទ័រឡើយ ក្នុងករណីដែលកម្មវិធីកុំព្យូទ័រនោះមិនមែនជាកម្មវត្ថុដ៏សំខាន់សម្រាប់ការដាក់ជួល ។

មាត្រា ២២.-

សិទ្ធិបេតិកភណ្ឌចំពោះកម្មវិធីកុំព្យូទ័រនិងឯកសារសមោធានដែលបង្កើតឡើងដោយនិយោជិតម្នាក់ឬច្រើននាក់ ក្នុងពេលបំពេញមុខនាទីឬក្នុងពេលធ្វើតាមសេចក្តីបង្គាប់របស់និយោជក ជាកម្មសិទ្ធិរបស់និយោជក លើកលែងតែមានកិច្ចសន្យាចែងផ្ទុយពីនេះ ។

ចំពោះជនណាម្នាក់ដែលបានជួលបុគ្គលណាផ្សេងឱ្យបង្កើតកម្មវិធីកុំព្យូទ័រឱ្យខ្លួនដោយឆ្លងតាមកិច្ចសន្យាបញ្ជាទិញ ជននោះត្រូវបានទទួលសិទ្ធិបេតិកភណ្ឌ ។

## ផ្នែកទី ៤
## ការកម្រិតសិទ្ធិអ្នកនិពន្ធ

មាត្រា ២៣.-

រូបវន្តបុគ្គលណាម្នាក់នាំចូលនូវស្នាដៃមួយច្បាប់សម្រាប់សេចក្តីត្រូវការផ្ទាល់ខ្លួនអាចប្រព្រឹត្តទៅបានដោយពុំចាំបាច់តម្រូវឱ្យមានការអនុញ្ញាតពីអ្នកនិពន្ធ ឬពីម្ចាស់សិទ្ធិលើស្នាដៃនោះឡើយ ។

មាត្រា ២៤.-

ការផលិតឡើងវិញចំនួនមួយច្បាប់ជាលក្ខណៈឯកជននូវស្នាដៃដែលបានបោះផ្សាយហើយសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននឹងត្រូវអនុវត្តបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់កម្មសិទ្ធិឡើយ ។

ការអនុញ្ញាតដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះមិនត្រូវយកមកអនុវត្តចំពោះការផលិតឡើងវិញនូវ :

ក-ស្នាដៃស្ថាបត្យកម្ម មានទម្រង់ជាអាគារ ឬសំណង់ផ្សេងៗ ។

ខ-ការចម្លងទាំងស្រុង ឬភាគសំខាន់ខ្លះនូវសៀវភៅតាមវិធីបោះពុម្ពជាថ្មី និងការចម្លងស្នាដៃព្យួរតន្ត្រីក្រោមរូបភាពជាអក្សរភ្លេង ។

គ-ការចម្លងទាំងស្រុងឬភាគសំខាន់ខ្លះនូវប្រព័ន្ធទិន្នន័យតាមទម្រង់ឌីជី-ថល ។

ឃ-កម្មវិធីកុំព្យូទ័រ លើកលែងតែច្បាប់ចម្លងកម្មវិធីដើម្បីរក្សាទុកសម្រាប់ការពារការបាត់បង់ ។

ង-ស្នាដៃណាមួយក្នុងលក្ខណៈដែលការផលិតឡើងវិញធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃស្នាដៃ ឬធ្វើឱ្យខូចខាតដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធឬម្ចាស់កម្មសិទ្ធិ ។

មាត្រា ២៥.–

អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់បានចំពោះ :

ក-ការសម្តែងស្នាដៃជាឯកជនដោយមិនគិតកម្រៃ ជាការសម្តែងក្នុងរង្វង់គ្រួសារឬញាតិមិត្ត ។

ខ-ការរៀបចំទុកក្នុងបណ្ណាល័យនូវសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឱ្យបានគង់វង្សឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ ។

គ-ការប្រើប្រាស់ស្នាដៃសម្រាប់ការសិក្សាដោយគ្មានរកប្រាក់កម្រៃ ។

ឃ-ការបកប្រែស្នាដៃពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ ។

ប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធនិងប្រភពនៃស្នាដៃ អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់ចំពោះកិច្ចការទាំងឡាយដូចតទៅ :

-ការវិភាគ និងអាគតដ្ឋានខ្លីៗនៃស្នាដៃដែលបញ្ជាក់ពីការរិះគន់ សង្គ្រាមចាំកកាគរុកោសល្យ វិទ្យាសាស្ត្រឬព័ត៌មានស្តីពីស្នាដៃនោះ

-ការផ្សាយទស្សនៈសារព័ត៌មាន

-ការផ្សព្វផ្សាយទាំងស្រុងឬភាគខ្លះនៃសុន្ទរកថាមានាដែលបានថ្លែងជាសា-ធារណៈក្នុងសារព័ត៌មានឬខ្សែផ្សាយ

-ការត្រាប់កំប្លែង ការត្រាប់តាមគំរូ ឬគំនូរតុក្កតាដោយផ្អែកតាមលំនាំដើមនៃស្នាដៃ

-ការចម្លងរូបភាពស្នាដៃសិល្បៈក្រាហ្វិកឬសិល្បៈសូនរូបដែលស្ថិតនៅទីកន្លែងសាធារណៈមួយ លើកលែងតែរូបភាពនោះត្រូវបានចាត់ទុកថាជាកម្មវត្ថុសំខាន់នៃការចម្លងបន្ត ។

មាត្រា ២៦.–

អ្នកនិពន្ធដែលបង្កើតស្នាដៃជាខ្សែភាពយន្ត វីដេអូ ល្ខោននិយាយ ប្រលោមលោកអំពីឆាកជីវិតនៃបុគ្គលឬគ្រួសារជាក់លាក់ណាមួយត្រូវមានការអនុញ្ញាតជាមុនពីបុគ្គលសាមីឬពីញាតិពន្ធដែលបានទទួលមរតកសាលនី ។

មាត្រា ២៧.–

ការផលិតឡើងវិញជាបណ្ដោះអាសន្ននូវស្នាដៃមួយបាន លុះត្រាតែការផលិតឡើងវិញនោះធ្វើឡើងស្របពេលជាមួយនឹងការប្រើប្រាស់ស្នាដៃដែលបានទទួលការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

មាត្រា ២៨.–

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាតឱ្យស្រង់អាគតដ្ឋានពីស្នាដៃណាមួយជាស្នាដៃដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់បញ្ចូលក្នុងស្នាដៃមួយផ្សេងទៀត ដោយពុំចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធនិងពុំចាំបាច់បង់ប្រាក់កម្រៃ ។

ការស្រង់អាគតដ្ឋានត្រូវបញ្ជាក់អំពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។ ការស្រង់អាគតដ្ឋាននេះមិនត្រូវធ្វើឱ្យហួសពីគោលដៅដែលត្រូវបំពេញនោះឡើយ ។

មាត្រា ២៩.–

ដោយមិនគិតពីបទប្បញ្ញត្តិក្នុងមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាត :

ក-ឱ្យប្រើប្រាស់ស្នាដៃណាមួយដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់ដើម្បីបញ្ជាក់ឱ្យបានច្បាស់ក្នុងទំព័រសៀវភៅឬសារពត៌មាន ឬតាមរលកវិទ្យុ ឬក្នុងការចាក់ផ្សាយសម្លេង ឬបញ្ចាំងរូបភាពដើម្បីជាប្រយោជន៍ដល់ការសិក្សាដោយពុំចាំបាច់បង់

ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

ខ-ឱ្យថតចម្លងបាននូវអត្ថបទដាច់ដោយឡែកនានា អត្ថបទផ្សាយនៅក្នុងទំព័រសារព័ត៌មាន ឬទស្សនាវដ្តី ឬថតចម្លងបាននូវខ្លឹមសារដកស្រង់ខ្លីៗចេញពីស្នាដៃណាមួយដែលត្រូវបានផ្សាយត្រឹមត្រូវតាមច្បាប់ ។ ការថតចម្លងនេះ ធ្វើឡើងតាមរយៈមធ្យោបាយ បច្ចេកទេសចម្លង ដោយមិនរកប្រាក់ចំណេញខាងពាណិជ្ជកម្មដើម្បីជាប្រយោជន៍ដល់ការបង្រៀនឬដល់ការប្រឡងដែលធ្វើឡើងនៅក្នុងគ្រឹះស្ថានសិក្សានានាសមស្របទៅតាមគោលដៅដែលត្រូវបំពេញ ។ ការថតចម្លងនូវអត្ថបទឬខ្លឹមសារខ្លីៗពុំចាំបាច់បង់ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ ប្រសិនបើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

## ផ្នែកទី ៥
## រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣០.–**

សិទ្ធិបេតិកភណ្ឌត្រូវបានការពារចាប់តាំងពីថ្ងៃដែលបានបង្កើតស្នាដៃ ។ រយៈពេលកិច្ចការពារសិទ្ធិនេះត្រូវប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធព្រមទាំងប្រព្រឹត្តទៅ ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ ។

កិច្ចការពារសិទ្ធិបេតិកភណ្ឌលើស្នាដៃសហការប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធដែលរស់នៅចុងក្រោយគេ ព្រមទាំងប្រព្រឹត្តទៅរយៈពេល ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធចុងក្រោយនេះ ។

**មាត្រា ៣១.–**

សិទ្ធិបេតិកភណ្ឌលើស្នាដៃមួយដែលត្រូវបានបោះពុម្ពផ្សាយជាអានាមិកក្តី ឬជារហស្សនាមក្តីត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះ ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបោះពុម្ពផ្សាយជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ប្រសិនបើពុំមានការបោះពុម្ពផ្សាយជាលើកដំបូងក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបានគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

បើសិនជាមុនពេលកំណត់នៃកិច្ចការពារពីច្បាប់ អត្តសញ្ញាណអ្នកនិពន្ធត្រូវបានបង្ហាញឱ្យស្គាល់ ឬត្រូវសាធារណជនបានស្គាល់ច្បាស់ឥតសង្ស័យ គឺបទប្បញ្ញត្តិនៃមាត្រា ៣០ ក្នុងច្បាប់នេះត្រូវយកមកអនុវត្ត ។

សិទ្ធិបេតិកភណ្ឌលើស្នាដៃសមូហភាព ឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ឆាមរណៈត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានផ្សព្វផ្សាយជាលើកដំបូងត្រឹមត្រូវតាមច្បាប់ ។

ប្រសិនបើពុំមានការផ្សព្វផ្សាយក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបានគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

## ផ្នែកទី ៦

## ការផ្ទេរសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣២.-**

ការផ្ទេរសិទ្ធិលើចំណុចណាមួយដែលមានចែងក្នុងមាត្រា ២១ ក្នុងច្បាប់នេះ មិនមែនជាការផ្ទេរសិទ្ធិលើចំណុចដទៃទៀតឡើយ ។

ប្រសិនបើមានកិច្ចសន្យាចែងអំពីការផ្ទេរ ឬការផ្តល់អាជ្ញាប័ណ្ណលើសិទ្ធិណាមួយដូចមានចែងក្នុងមាត្រានេះ ប្រសិទ្ធិភាពនៃការផ្ទេរឬការផ្តល់នោះត្រូវគោរពតាមល័ក្ខខ័ណ្ឌនៃរបៀបធ្វើអាជីវកម្មដូចមានចែងក្នុងកិច្ចសន្យា ។

**មាត្រា ៣៣.-**

ការគ្រប់គ្រងសិទ្ធិបេតិកភណ្ឌអាចផ្ទេរឱ្យទាយាទរបស់អ្នកនិពន្ធបានដោយមូលហេតុមរណភាពរបស់អ្នកនិពន្ធ ឬអាចប្រគល់ជូនតតិយជនបានដោយយោងតាមបទប្បញ្ញត្តិនៃមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

## ផ្នែកទី ៧
## ការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣៤.–**

កិច្ចសន្យាទាំងឡាយស្តីពីការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរជាក់លាក់ បើមិនដូច្នោះទេ កិច្ចសន្យានេះនឹងត្រូវចាត់ទុកជាមោឃៈ ។ មានតែអ្នកនិពន្ធឬម្ចាស់សិទ្ធិប៉ុណ្ណោះដែលមានសិទ្ធិលើកនូវហេតុផលដើម្បីស្នើសុំមោឃភាពនៃកិច្ចសន្យា ។

**មាត្រា ៣៥.–**

កិច្ចសន្យានៃការផ្ទេរសិទ្ធិធ្វើអាជីវកម្មរបស់អ្នកនិពន្ធត្រូវធ្វើជាលាយលក្ខ័អក្សរដោយបញ្ជាក់ដាច់ដោយឡែកពីគ្នាអំពីកម្រិត ទំហំ គោលដៅ ទីកន្លែងនិងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឱ្យបានច្បាស់លាស់ ។

**មាត្រា ៣៦.–**

ក្នុងក្របខ័ណ្ឌនៃការបង្កើតស្នាដៃសមូហភាព អ្នកនិពន្ធម្នាក់ៗអាចធ្វើអាជីវកម្មលើវិភាគទានរបស់ខ្លួនដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ប៉ុន្តែអ្នកនិពន្ធនោះមិនត្រូវបង្កឱ្យខូចខាតដល់អាជីវកម្មនៃស្នាដៃសមូហភាពនោះឡើយ ។

ចំពោះស្នាដៃសហការ ការធ្វើអាជីវកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសហអ្នកនិពន្ធ ។ នៅពេលសហអ្នកនិពន្ធមិនឯកភាពគ្នា តុលាការជាអ្នកសម្រេច ។

**មាត្រា ៣៧.–**

ការផ្ទេរសិទ្ធិដើម្បីធ្វើអាជីវកម្មលើស្នាដៃរបស់អ្នកនិពន្ធអាចផ្ទេរទាំងស្រុង ឬផ្ទេរជាភាគខ្លះបាន ។ ម្ចាស់សិទ្ធិនឹងទទួលបានកប្រៃពីការផ្ទេរសិទ្ធិនេះ អនុលោមតាមប្រការ

ទាំងឡាយនៃកិច្ចសន្យាផ្ទេរសិទ្ធិនោះ ។

## ផ្នែកទី ៨
## ការតម្កល់ និង ការចុះបញ្ជីនៃស្នាដៃ

**មាត្រា ៣៨.-**

រាល់ស្នាដៃទាំងអស់ត្រូវទទួលបានទូវកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ ។ អ្នកនិពន្ធឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**មាត្រា ៣៩.-**

ការចុះបញ្ជីអាចធ្វើឡើងបានដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ការចុះបញ្ជីត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយជាលើកដំបូង និងចុះថ្ងៃ ខែ ឆ្នាំ នៃការបង្កើតស្នាដៃព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ ។

**មាត្រា ៤០.-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញវិញ្ញាបនប័ត្រចំពោះស្នាដៃដែលបានចុះបញ្ជី ។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរួមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## សិទ្ធិប្រហាក់ប្រហែល
## ផ្នែកទី ១
## សិទ្ធិអ្នកសម្តែង

**មាត្រា ៤១.-**

អ្នកសម្តែងមានសិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ឬអនុញ្ញាត :

ក-ការផ្សាយតាមរូវផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ ទូវការសម្តែង

របស់ខ្លួន លើកលែងតែការផ្សាយទាំងនោះបានផ្សាយចេញពីហ្វូណូក្រាមស្តីពីការសម្តែង ដែលបានអនុញ្ញាតពីអ្នកសម្តែង ឬបានផ្សាយឡើងវិញតាមទូរផ្សាយ ឬបានការអនុញ្ញាត ពីអង្គភាពទូរផ្សាយដែលបានផ្សាយមុនគេនូវការសម្តែង ។

ខ-ការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនដែលមិនទាន់បាន ថតបញ្ចូលហ្វូណូក្រាម ។

គ-ការផលិតឡើងវិញនូវការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាម ។

ឃ-ការចែកចាយជាសាធារណៈតាមការលក់ឬការផ្ទេរកម្មសិទ្ធិនូវហ្វូណូ-ក្រាមច្បាប់ដើមដែលអ្នកសម្តែងពុំទាន់បានអនុញ្ញាតឱ្យធ្វើការចែកចាយ ។

ង-ការដាក់ជួលឬការឱ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬ ហ្វូណូក្រាមច្បាប់ចម្លងស្តីពីការសម្តែង ។

បើគ្មានកិច្ចព្រមព្រៀង ផ្ទុយពីនេះ អ្នកសម្តែងមានសិទ្ធិ ៖

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ ផ្សេងទៀតពុំមានសិទ្ធិធ្វើការចាក់ផ្សាយនូវការសម្តែងរបស់ខ្លួនបានទេ

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ នោះពុំមានសិទ្ធិថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនទេ ។

## មាត្រា ៤២.–

ទោះបីមានការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនហើយក៏ដោយ អ្នកសម្តែងនៅមាន សិទ្ធិតម្រូវឱ្យគេសរសេរឈ្មោះខ្លួនលើការសម្តែងផ្ទាល់ ឬការសម្តែងដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីប្រើប្រាស់នៃការសម្តែងនោះពុំតម្រូវឱ្យមានការសរសេរ ឈ្មោះ ។ អ្នកសម្តែងនៅមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំភ្លៃស ការកាត់តខ្លឹមសារ ខ្វះឬកែប្រែខ្លឹមសារនៃការសម្តែងជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង ។

## មាត្រា ៤៣.–

អ្នកសម្តែងមិនអាចហាមឃាត់នូវការផលិតឡើងវិញនិងការផ្សព្វផ្សាយជាសាធា-រណៈស្តីពីការសម្តែងរបស់ខ្លួនបានឡើយ បើការសម្តែងនោះមានលក្ខណៈបន្ទាប់បន្សំនៅ ក្នុងសាច់រឿងស្នូលរបស់ឈុត ឬល្ខោនដៃ ឬឯកសារសោតទស្សន៍ ។

## ផ្នែកទី ២
## សិទ្ធិរបស់ផលិតករហ្វូណូក្រាម

**មាត្រា ៤៤.-**

ផលិតករហ្វូណូក្រាមមានសិទ្ធិផ្តាច់មុខក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ខ្លួន ។

**មាត្រា ៤៥.-**

រាល់ការផលិតឡើងវិញ ការលក់ ការប្តូរ ការជួល ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមត្រូវមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម ។

ផលិតករហ្វូណូក្រាមមានសិទ្ធិចែកចាយជាសាធារណៈតាមការលក់ ឬការផ្ទេរកម្មសិទ្ធិនូវច្បាប់ដើមឬច្បាប់ចម្លង ក្នុងករណីដែលផលិតករហ្វូណូក្រាមនោះពុំទាន់អនុ-ញ្ញាតឱ្យជនណាម្នាក់ធ្វើការចែកចាយ ។

ផលិតករហ្វូណូក្រាមមានសិទ្ធិនាំចូលនូវច្បាប់ចម្លងនៃហ្វូណូក្រាមរបស់ខ្លួនក្នុងទិសដៅធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

## ផ្នែកទី ៣
## សិទ្ធិផលិតករវីដេអូ

**មាត្រា ៤៦.-**

ផលិតករវីដេអូគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានការផ្តួចផ្តើមគំនិតនិងការទទួលខុសត្រូវក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពជាឈុតៗដែលមានឬគ្មានសម្លេងដើម្បីផលិតវីដេអូ ។

រាល់ការផលិតឡើងវិញនូវវីដេអូដើម្បីផ្សព្វផ្សាយជាសាធារណៈ លក់ ដូរ ឬជួលចាំបាច់ត្រូវតែមានការអនុញ្ញាតពីផលិតករវីដេអូ ។

ការផ្ទេរសិទ្ធិរបស់ផលិតករវីដេអូដូចមានចែងក្នុងមាត្រានេះ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិអ្នកសម្តែងដែលបានរួមសហការផលិតជាវីដេអូបានឡើយ ។

## ផ្នែកទី ៤
## សិទ្ធិនៃអង្គភាពទូរផ្សាយ

**មាត្រា ៤៧.-**

អង្គភាពទូរផ្សាយមានស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍និងស្ថានីយទូរទស្សន៍ខ្សែកាប មានសិទ្ធិផ្តាច់មុខក្នុងការធ្វើ ឬអនុញ្ញាតការថតកម្មវិធីផ្សាយ ការផ្សព្វផ្សាយជាសាធារណៈ ការចាក់ផ្សាយឡើងវិញ ការផលិតឡើងវិញ ការចែកចាយ ឬការដាក់ជួលជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីផ្សាយរបស់ស្ថានីយសាមី ។

**មាត្រា ៤៨.-**

ការថតចម្លងនូវកម្មវិធីរបស់អង្គភាពទូរផ្សាយដើម្បីលក់ ជួល ប្តូរ ចាក់ផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនៅទីកន្លែងណាមួយត្រូវមានការអនុញ្ញាតពីអង្គភាពទូរផ្សាយសាមី ។

## ផ្នែកទី ៥
## លាភការ

**មាត្រា ៤៩.-**

ប្រសិនបើហ្វូណូក្រាមបានផលិតក្នុងគោលបំណងពាណិជ្ជកម្ម ឬជាការផលិតឡើងវិញត្រូវបានយកទៅផ្សព្វផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយផ្សេងទៀតជាសាធារណៈ ឬសម្តែងជាសាធារណៈ អ្នកសម្តែងនិងផលិតករហ្វូណូក្រាមត្រូវទទួលបាននូវលាភការគ្រប់គ្នាតែមួយលើកគត់ប្រកបដោយសមធម៌ ដែលអ្នកប្រើប្រាស់ត្រូវបង់លាភការនោះជូនអង្គភាពគ្រប់គ្រងសិទ្ធិរួម ។

អង្គភាពគ្រប់គ្រងសិទ្ធិរួមគឺជានីតិបុគ្គលមានភារកិច្ចចាត់ចែងការងារស្តីពីលាភការនេះដែលកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៦
## ការកម្រិតសិទ្ធិ

**មាត្រា ៥០.-**

ដោយមិនគិតដល់បទប្បញ្ញត្តិនៃមាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ នៃច្បាប់នេះ សកម្មភាពទាំងឡាយដូចតទៅនេះ ត្រូវអនុញ្ញាតឱ្យអនុវត្តបានដោយពុំចាំបាច់ទទួលការយល់ព្រមពីសិទ្ធិវន្ត និងពុំចាំបាច់បង់ប្រាក់កម្រៃ :

ក-សេចក្តីរាយការណ៍ស្តីពីបច្ចុប្បន្នភាពក្នុងលក្ខខណ្ឌដែលសេចក្តីរាយការណ៍នោះបានដកស្រង់ជាផ្នែកខ្លីៗពីការសម្តែង ឬពីខ្លឹមសារហ្វូណូក្រាម ឬពីក្នុងការផ្សាយតាមខ្សែផ្សាយ ។

ខ-ការថតចម្លងដែលធ្វើឡើងសម្រាប់តែប្រើប្រាស់ក្នុងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ។

គ-ការថតចម្លងសម្រាប់បម្រើក្នុងក្របខ័ណ្ឌនៃការសិក្សាលើកលែងតែការសម្តែង ឬហ្វូណូក្រាមដែលផលិតសម្រាប់តែគោលបំណងនៃការសិក្សា ។

ឃ-អាគតដ្ឋានជាសម្រង់ខ្លីៗពីការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីចាក់ផ្សាយតាមខ្សែផ្សាយសមស្របតាមទម្លាប់ល្អ ដើម្បីប្រើប្រាស់ក្នុងទិសដៅព័ត៌មាន ។

ង-ការប្រើប្រាស់ផ្សេងៗទៀតដែលជាករណីលើកលែង ពិសេសចំពោះស្នាដៃនានាដែលទទួលបាននូវកិច្ចការពារសិទ្ធិអ្នកនិពន្ធដោយអនុលោមតាមច្បាប់នេះ ។

ច-ការចាប់យករូបភាពនិងសម្លេងដើម្បីផ្សព្វផ្សាយបន្តទាំងស្រុង ឬភាគខ្លះដោយអង្គភាពខ្សែផ្សាយស្តីពីបច្ចុប្បន្នភាពនៃពិធីបុណ្យ អង្គប្រជុំ ឬព្រឹត្តការណ៍នានារបស់ជាតិពីស្ថានីយដើមក្នុងពេលតែមួយ ។

**មាត្រា ៥១.-**

បទប្បញ្ញត្តិនៃមាត្រា ៤១ នៃច្បាប់នេះ មិនត្រូវអនុវត្តនៅពេលណាដែលអ្នកសម្តែងអនុញ្ញាតឱ្យគេថតបញ្ចូលការសម្តែងរបស់ខ្លួនទៅក្នុងហ្វូណូក្រាមមានរូបភាពឬសោតទស្សន៍ ។

**មាត្រា ៥២.–**

បទប្បញ្ញត្តិនៃមាត្រា ៤១ ក្នុងច្បាប់នេះ មិនត្រូវយកទៅអនុវត្តចំពោះអង្គភាពទូរផ្សាយណាមួយដែលធ្វើការថតចម្លងនិងផលិតឡើងវិញដោយមធ្យោបាយផ្ទាល់ខ្លួន ដើម្បីចាក់ផ្សាយក្នុងកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយនោះ ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ។

រាល់ការផលិតឡើងវិញនូវស្នាដៃ ឬច្បាប់ចម្លងដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងលើនៃមាត្រានេះ ត្រូវបំផ្លាញចោលឱ្យអស់ក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីការផលិត លើកលែងតែករណីត្រូវរក្សាទុកស្នាដៃចម្លងមួយច្បាប់គត់សម្រាប់ជាឯកសារ ។

## ផ្នែកទី ៧
## រយៈពេលនៃកិច្ចការពារ

**មាត្រា ៥៣.–**

១-រយៈពេលនៃកិច្ចការពារអ្នកសម្ដែងគឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម ឬក្នុងករណីដែលពុំបានថតការសម្ដែងបញ្ចូលក្នុងហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលការសម្ដែងបានប្រព្រឹត្តទៅ ។

២-រយៈពេលនៃកិច្ចការពារផលិតករហ្វូណូក្រាមគឺ ៥០(ហាសិប)ឆ្នាំ គិតពីចាប់ដំណាច់ឆ្នាំប្រក្រតីទិនដែលបានបោះផ្សាយហ្វូណូក្រាម ឬក្នុងករណីពុំបានបោះផ្សាយហ្វូណូក្រាម គឺគិតពីចាប់ដំណាច់ឆ្នាំប្រក្រតីទិន ដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាម ។

៣-រយៈពេលនៃកិច្ចការពារកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយ គឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលកម្មវិធីបានផ្សាយ ។

## ផ្នែកទី ៨
## ការផ្ទេរសិទ្ធិ

**មាត្រា ៥៤.–**

បទប្បញ្ញត្តិនៃមាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ផ្នែកទី ៩
## ការតម្កល់

**មាត្រា ៥៥.–**

បទប្បញ្ញត្តិនៃមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ជំពូកទី ៤
## ការគ្រប់គ្រងរួមលើសិទ្ធិនានា

**មាត្រា ៥៦.–**

អ្នកនិពន្ធនិងម្ចាស់សិទ្ធិប្រហាក់ប្រហែលអាចបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដើម្បីការពារនិងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ ។

ការបង្កើតអង្គភាពគ្រប់គ្រងរួមលើសិទ្ធិអ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូ-ក្រាម ឬផលិតករវីដេអូ ត្រូវតែមានការទទួលស្គាល់ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

អង្គភាពគ្រប់គ្រងរួមលើសិទ្ធិផ្សាយតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបនៃអង្គ-ភាពទូរផ្សាយត្រូវមានការទទួលស្គាល់ពីក្រសួងពត៌មាន ។

## ជំពូកទី ៥
##ករណីវិវាទ និង ទោសប្បញ្ញត្តិ

**មាត្រា ៥៧.-**

បុគ្គលណាដែលបានទទួលរង ឬអាចទទួលរងនូវការប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនជាអ្នកនិពន្ធក្តី ឬសិទ្ធិប្រហាក់ប្រហែលក្តី បុគ្គលនោះមានសិទ្ធិប្តឹងទៅតុលាការដើម្បី :

ក-ធ្វើការហាមប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់នោះអាចនឹងកើតមាននៅក្នុងពេលឆាប់ៗខាងមុខ ។

ខ-បង្គាប់ឱ្យចុងចម្លើយឈប់ធ្វើការប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់បែបនេះនៅតែបន្តសកម្មភាព ។ ដើមចោទអាចទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត សងការខូចខាតនិងប្រគល់មកវិញនូវវត្ថុតាងមានឧបករណ៍ ឬសម្ភារៈដែលជាប់រឿងហេតុព្រមទាំងប្រគល់នូវប្រាក់ចំណេញដែលបានមកពីអំពើខុសច្បាប់នោះ ។

**មាត្រា ៥៨.-**

តុលាការមានសមត្ថកិច្ចរឹបអូសឬបំផ្លាញចោលនូវវត្ថុតាងមានឧបករណ៍ សម្ភារៈដែលត្រូវបានផលិត បានប្រើប្រាស់ ឬបានដាក់ឱ្យចរាចរដោយខុសច្បាប់ ឬឧបករណ៍សម្រាប់ធ្វើការបំពានដែលឧបករណ៍ឬសម្ភារៈទាំងនោះកំពុងស្ថិតក្នុងការកាន់កាប់របស់ចុងចម្លើយ ឬកំពុងត្រូវបានឃាត់ទុក ។

**មាត្រា ៥៩.-**

តុលាការមានសមត្ថកិច្ចចាត់វិធានការចាំបាច់ជាបណ្តោះអាសន្ន សម្រាប់ធានានូវការរក្សាទុកវត្ថុតាង ដែលផលិតចេញពីការចម្លងខុសច្បាប់នូវស្នាដៃណាមួយ ។

ដើមចោទមានកាតព្វកិច្ចជួសជុលការខូចខាតដែលខ្លួនបានប្រព្រឹត្តទៅលើចុងចម្លើយ ក្នុងករណីបណ្តឹងនោះត្រូវបានតុលាការរកឃើញថាជាបណ្តឹងពុំមានមូលហេតុត្រឹមត្រូវ ។

### មាត្រា ៦០.-

ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃនៃការឃាត់ទុកនូវឧបករណ៍ ឬសម្ភារៈ បុគ្គលជាម្ចាស់ ឬតតិយជនជាអ្នកកាន់កាប់ឧបករណ៍ ឬសម្ភារៈដែលត្រូវបានឃាត់ទុក អាចស្នើសុំទៅតុលាការឱ្យលើកលែងការឃាត់ទុក ឬសម្រេចកម្រិតអនុភាពនៃការឃាត់ទុកនោះ ។

### មាត្រា ៦១.-

ការឃាត់ទុកនូវវត្ថុតាង មានឧបករណ៍ឬសម្ភារៈទាំងឡាយណាដោយពុំបានប្ដឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃឃាត់ទុក ការលើកលែងការឃាត់ទុកតាមសំណើសុំរបស់បុគ្គលជាម្ចាស់ ឬតតិយជនជាអ្នកកាន់កាប់ ជាសមត្ថកិច្ចរបស់តុលាការ ។

### មាត្រា ៦២.-

យោងតាមមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ ត្រូវចាត់ទុកជាបទល្មើសដែរ អំពើទាំងឡាយដូចតទៅ :

១-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាមក្នុងគោលបំណងធ្វើឱ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនៃស្នាដៃហួសកម្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឱ្យខូចគុណភាពនូវច្បាប់ចម្លង ។

២-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឱ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធីផ្សាយតាមសញ្ញាលេខកូដដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈតាមវិធីផ្សេងរួមមានការផ្សាយតាមផ្កាយរណប ។

៣-ការលុបចោលឬការកែប្រែព័ត៌មានស្ដីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

៤-ការចែកចាយ ឬការនាំចូលដើម្បីចែកចាយ ការផ្សាយតាមអង្គភាពទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនសាធារណជននូវស្នាដៃ ឬការសម្ដែង

ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថាព័ត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិចជាព័ត៌មានដែលត្រូវគេលុបចោលឬកែប្រែរួចហើយ ។

ពាក្យថា **"ព័ត៌មានស្តីពីរបបសិទ្ធិ"** មានន័យថា :

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណអ្នកនិពន្ធ ភិនភាគស្នាដៃ អត្តសញ្ញាណអ្នកសម្តែង ភិនភាគនៃអ្នកសម្តែង អត្តសញ្ញាណផលិតករហ្វូណូក្រាម ភិនភាគហ្វូណូក្រាម អត្តសញ្ញាណអង្គភាពទូរផ្សាយនិងភិនភាគកម្មវិធីអង្គភាពទូរផ្សាយ

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណម្ចាស់កម្មសិទ្ធិ ឬភិនភាគនៃព័ត៌មានស្តីពីលក្ខខណ្ឌនិងបែបបទនៃការប្រើប្រាស់ស្នាដៃនិងផលិតផលផ្សេងទៀត ដូចមានចែងនៅក្នុងច្បាប់នេះ និងស្គាល់ភិនភាគលេខកូដ ឬសញ្ញាលេខកូដ ដែលចែងឱ្យដឹងនូវព័ត៌មានទាំងនោះ ។

**មាត្រា ៦៣.-**

តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យ រដ្ឋបាលគយនិងរដ្ឋាករអាចឃាត់ទុកបាននូវទំនិញដែលម្ចាស់សិទ្ធិនោះសំអាងថាជាទំនិញក្លែងបន្លំ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចដើមបណ្តឹង និងអ្នកកាន់កាប់ទំនិញអំពីការឃាត់ទុកនូវទំនិញទាំងនោះ ។

លើកលែងតែមានបទប្បញ្ញត្តិស្តីពីរដ្ឋបាលគយនិងរដ្ឋាករចែងផ្ទុយពីបទប្បញ្ញត្តិនេះ វិធានឃាត់ទុកទំនិញអាចលុបចេញដោយស្របច្បាប់បាន ប្រសិនបើក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងស្តីពីការឃាត់ទុកទំនិញនោះ អ្នកប្តឹងពុំបានបង្ហាញភស្តុតាងឱ្យបានត្រឹមត្រូវដើម្បីបញ្ជាក់ទៅរដ្ឋបាលគយនិងរដ្ឋាករឱ្យដឹងថាសាមីខ្លួនបាន :

-ស្នើសុំទៅតុលាការចាត់វិធានការរក្សាទុកទំនិញដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ

-ប្តឹងទៅតុលាការមានសមត្ថកិច្ចដោយមានភ្ជាប់ជាមួយនូវការធានាគ្រប់គ្រាន់ដើម្បីការពារទុកជាមុននូវការទទួលខុសត្រូវរបស់ខ្លួនដែលអាចកើតមានជាយថា-

ហេតុបាន ។

អ្នកប្តឹងត្រូវតែផ្តល់សំណងលើការខូចខាតដែលបណ្តាលមកពីការឃាត់ទុកមិនិញនោះ ប្រសិនបើបណ្តឹងរបស់ខ្លួនត្រូវបានរកឃើញថាជាបណ្តឹងគ្មានមូលដ្ឋានត្រឹមត្រូវ ។

បទប្បញ្ញត្តិស្តីពីវិធានការតាមមាត់ច្រកព្រំដែននៃច្បាប់ស្តីពី "ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់" ត្រូវយកមកអនុវត្តបន្ថែមក្នុងមាត្រានេះ ។

## មាត្រា ៦៤.-

ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានកំណត់ក្នុងច្បាប់នេះ តាមរយៈការ ផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដោយប្រើមធ្យោ-បាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់ ។

បទល្មើសនៃការផលិតឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវផលិតផលបានពីបទល្មើសដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២ (ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីបទល្មើសបានប្រព្រឹត្តច្រើន ដង ការផ្តន្ទាទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត ។ ករណីមិនរាងចាល ត្រូវផ្តន្ទា ទោសទ្វេដងនៃទោសពីមុន ។

## មាត្រា ៦៥.-

ការផលិតឬការផលិតឡើងវិញដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករ ហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី

៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវហ្វូណូក្រាម កាសែត ឬកាសែតវីដេអូដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការចាក់ផ្សាយតាមទូរផ្សាយដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦៦.–**

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចចេញសេចក្តីសម្រេចដូចតទៅ :

-រឹបអូសមួយភាគឬទាំងស្រុងនូវប្រាក់ចំណូលបានមកពីបទល្មើសនិងឧបករណ៍ដែលដាក់តាំងដោយឡែកសម្រាប់ការប្រព្រឹត្តទៅនូវបទល្មើសនោះ

-បង្គាប់ឱ្យយកឧបករណ៍ឬសម្ភារៈដែលរឹបអូសទៅប្រគល់ជូនម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលដោយមិនទាន់គិតគូរដល់ការសងសោហ៊ុយជម្ងឺចិត្ត

-បង្គាប់ឱ្យបំផ្លាញចោលនូវសម្ភារៈនិងឧបករណ៍ដែលបានពីការរឹបអូស ។

## ជំពូកទី ៦

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ

**មាត្រា ៦៧.–**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធនិង

សិទ្ធិប្រហាក់ប្រហែលដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបាន ។

ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៨.–**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញសេចក្តីប្រកាសអំពីការបញ្ឈប់ជាបន្ទាន់នូវរាល់អាជីវកម្មដែលផ្ទុយនឹងច្បាប់នេះ ។

ក្រោយពីច្បាប់នេះចូលជាធរមាន ៦(ប្រាំមួយ)ខែ ទោសប្បញ្ញត្តិនៃមាត្រា ៦៤ និង មាត្រា ៦៥ ត្រូវយកមកអនុវត្តចំពោះអាជីវកម្មកំពុងមានសកម្មភាពផ្ទុយនឹងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៦៩.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

ពរល.០៣.០៣.១១៣

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៤៥ ចល

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
ព្រះហស្តលេខា
នរោត្តម បុប្ផាទេវី

ចម្លងត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ណាង តាន់**

# ព្រះរាជក្រម

នស/រកម/០២០២/០០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារម៉ាក ពាណិជ្ជនាមដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជានិងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ។

**មាត្រា ២.-**

**ក-ម៉ាក** គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាហៅថា សេវាសញ្ញា ។

**ខ-ម៉ាកសមូហភាព** គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសំគាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី ។

**គ-ពាណិជ្ជនាម** គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះនិងសញ្ញាសំគាល់សំរាប់បញ្ជាក់និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

**មាត្រា ៣.-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៤.-**

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ ៖

ក- ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ- ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីល-ធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភាន់ច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

ឃ- ម៉ាកដែលដូចគ្នានិង/ ឬត្រាប់តាម ឬមានចំណុចណាមួយដូចសញ្ញាជាតិ ទង់ជាតិនិងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ ។

ង- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះសំរាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហ-គ្រាសមួយទៀត ។

ច- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

\- ឆ- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញឬសេវាដូចគ្នា ឬទំនិញឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

## ជំពូកទី ២
## ការចុះបញ្ជីនិងសិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

មាត្រា ៥.-

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់ :

-គំរូម៉ាក

-បញ្ជីទំនិញឬសេវាដែលត្រូវចុះបញ្ជី ដោយរាយលំអិតតាមក្រុមមុខទំនិញទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធ ។

ខ- ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងពាណិជ្ជកម្ម ។

មាត្រា ៦.-

សិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាក ត្រូវបានផ្តល់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាពនៃការចុះបញ្ជី ដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមាន តាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយដែលជាសមាជិកនៃអនុសញ្ញាក្រុងប៉ារីស ។

ខ- តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

មាត្រា ៧.-

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ។

មាត្រា ៨.-

ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវ :

ក- ពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃមាត្រា ៥ និងបទបញ្ញាដែលជាប់ទាក់ទង ។

ខ- ពិនិត្យនិងកំណត់ថាម៉ាកនោះគឺជាម៉ាកស្របតាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ២ ចំណុច ក និងមិនអាចចុះបញ្ជីបានតាមមាត្រា ៤ ដោយលើកលែងតែចំណុច ឆ នៃមាត្រា ៤ នេះចេញ ។

មាត្រា ៩.-

អាទិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានកំណត់ដូចតទៅ :

ក- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូចឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំតាមពេលវេលាខុសគ្នា មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធការចុះបញ្ជីម៉ាកណាមួយនៃម៉ាកទាំងនោះរហូតដល់ពេលដែលសិទ្ធិនៃអ្នកស្នើសុំទាំងនោះត្រូវបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ឬត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា និងមានការយល់ព្រមពីមន្ត្រីកាន់កាប់បញ្ជី ។

ខ- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំក្នុងពេលជាមួយគ្នា ក្រោយពីការពិគ្រោះឯកភាពគ្នាទៅវិញទៅមកក្នុងចំណោមអ្នកស្នើសុំទាំងអស់ មានអ្នកស្នើសុំតែម្នាក់គត់ដែលអាចទទួលបាននូវការចុះបញ្ជីម៉ាក ។

មាត្រា ១០.-

សិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថាល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ បានត្រូវបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក ចេញវិញ្ញាបនប័ត្រនៃការចុះបញ្ជីជូនអ្នកស្នើសុំនិងចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ខ- ពាក្យស្នើសុំចុះបញ្ជីដែលមិនបានសមស្របតាមមាត្រា ៨ អ្នកស្នើសុំចុះបញ្ជី អាចកែតម្រូវក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំពីអ្នកសុំចុះបញ្ជីតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

គ- ក្នុងរង្វង់ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការហើយ ជនណាដែលមានការពាក់ព័ន្ធ អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីម៉ាក តាមបែបបទដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច ក មាត្រា ៤ និងមាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ ។

ឃ- មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវសេចក្តីជូនដំណឹងនោះមួយច្បាប់ទៅអ្នកសុំចុះបញ្ជីតាមពេលវេលានិងបែបបទដែលបានកំណត់ ។ បន្ទាប់មកអ្នកស្នើសុំចុះបញ្ជីត្រូវបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីនូវចម្លើយបញ្ជាក់អំពីមូលដ្ឋានបង្អែកទាំងឡាយសម្រាប់ការចុះបញ្ជីរបស់ខ្លួន ។ ប្រសិនបើមិនបានឆ្លើយតបទេ ម្ចាស់ម៉ាកនោះត្រូវបាត់ទុកថាបានបោះបង់ចោលការចុះបញ្ជីរបស់ខ្លួន ។

ង- ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាងមានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាងនិងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវ

សម្រេចថាម៉ាកដែលបានចុះបញ្ជីនេះត្រូវរក្សាទុក ឬបដិសេធ ។

**មាត្រា ១១.-**

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយវិរោធភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាក ដែលខ្លួនបានចុះបញ្ជីរួចហើយនិងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញនិងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះហើយដែលអាចបណ្តាលឱ្យមានការភាន់ច្រឡំជាសាធារណៈ ។

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

**មាត្រា ១២.-**

សុពលភាពក្នុងការចុះបញ្ជីម៉ាកនិងការចុះបញ្ជីសាជាថ្មីត្រូវបានកំណត់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព ១០(ដប់) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។

ខ- តាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយ អាចធ្វើឡើងសាជាថ្មីសំរាប់រយៈពេល ១០ (ដប់)ឆ្នាំ ម្តងជាបន្តបន្ទាប់ក្នុងល័ក្ខខ័ណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ ។

គ- ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយ មុនពេលដែលច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការការពារ ដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។

ឃ- ការអនុគ្រោះចំពោះការយឺតយ៉ាវក្នុងការចុះបញ្ជីសាជាថ្មីត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ (ប្រាំមួយ) ខែ ។

## ជំពូកទី ៣

## មោឃភាពនិងការលុបម៉ាកចេញពីបញ្ជី

**មាត្រា ១៣.-**

មោឃភាពនិងអានុភាពនៃមោឃភាពត្រូវបានកំណត់ដូចខាងក្រោម :

ក- ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវទុកការចុះបញ្ជីជាមោឃៈ ប្រសិនបើជនដែលស្នើសុំឱ្យមានមោឃភាពនោះ បង្ហាញថាមានល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច ក និងមាត្រា ៤ មិនត្រូវបានបំពេញ ។

គ- មោឃភាពនៃការចុះបញ្ជីម៉ាកត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយត្រូវបានកត់ត្រានិងបោះពុម្ពផ្សាយជាបន្ទាន់ ។

**មាត្រា ១៤.-**

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដូចខាងក្រោម :

ក- អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយតាមរយៈពេលដែលបានកំណត់ក្នុងមាត្រា ១២ ចំណុច ខ និងចំណុច ឃ ។

ខ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ៖

គ- ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនគោរពល័ក្ខខ័ណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់នៅក្នុង មាត្រា ៨ ។

ឃ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយលែងមានអាស័យដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ជឿជាក់ដោយផ្អែកលើភ័ស្តុតាងថា ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនមែនជាម្ចាស់ស្របច្បាប់ ។

ច- ជឿជាក់ថាម៉ាកដែលបានចុះបញ្ជីរួច ហើយប្រហាក់ប្រហែលឬដូចគ្នាទៅនឹងម៉ាកល្បីដែលជាកម្មសិទ្ធិរបស់ភាគីទីបី ។

**មាត្រា ១៥.-**

ម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ត្រូវបានលុបចេញពីបញ្ជី ។ ប្រសិនបើម្ចាស់ម៉ាកបង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះ នឹងមិនត្រូវបានលុបចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្មលុបម៉ាកចេញពីបញ្ជី ១ (មួយ) ខែ មុនកាលបរិច្ឆេទ ៥(ប្រាំ) ឆ្នាំ នៃការមិនបានប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ ។

## ជំពូកទី ៤

## ម៉ាកសមូហភាព

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងពីមាត្រា ៣ ដល់មាត្រា ១៥ ព្រមទាំងមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះម៉ាកសមូហភាព ។

មាត្រា ១៧.-

បែបបទនៃការចុះបញ្ជីម៉ាកសមូហភាពមានដូចតទៅ :

ក- ពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពត្រូវបញ្ជាក់ថាជាម៉ាកសមូហភាព និងត្រូវភ្ជាប់មកជាមួយនូវបទបញ្ញត្តិរួមស្តីពីការគ្រប់គ្រង ការប្រើប្រាស់ម៉ាកសមូហភាពនោះមួយច្បាប់ ។

ខ- ម្ចាស់ម៉ាកសមូហភាព ដែលបានចុះបញ្ជីហើយ ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីអំពីការផ្លាស់ប្តូរទាំងឡាយតាមបទបញ្ញាដែលបានយោងក្នុងកថាខណ្ឌ ក ។

មាត្រា ១៨.-

បន្ថែមលើខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ចំណុច ក និងចំណុច ខ មន្ត្រីកាន់កាប់បញ្ជីត្រូវបាត់ទុកការចុះបញ្ជីម៉ាកសមូហភាពជាមោឃៈ ប្រសិនបើជនដែលទាមទារនូវមោឃភាពនោះបង្ហាញថា មានតែម្ចាស់ដែលបានចុះបញ្ជីម្នាក់ឯងប៉ុណ្ណោះដែលប្រើប្រាស់ម៉ាក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់រំលោភទៅនឹងបទបញ្ញត្តិរួមដែលបានបញ្ញត្តិនៅក្នុងមាត្រា ១៧ ចំណុច ក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់តាមរបៀបមួយដែលអាចបំភាន់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជនអំពីប្រភពដើម ឬលក្ខណៈរួមផ្សេងទៀតនៃទំនិញ ឬសេវាដែលពាក់ព័ន្ធ ។

## ជំពូកទី ៥

## ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក

មាត្រា ១៩.-

ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះបញ្ជីម៉ាក ឬពាក្យស្នើសុំ

ទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះ ត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាពពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះត្រូវបានប្រើប្រាស់ ។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបានការ ។

ខ- ការចុះបញ្ជីម៉ាកសមូហភាពមួយ ឬពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពនោះមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ ។

## ជំពូកទី ៦
## ពាណិជ្ជនាម

**មាត្រា ២០.-**

នាម ឬសញ្ញាសំគាល់មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចបំភាន់ដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាសដែលកំណត់ដោយនាមនោះ ។

**មាត្រា ២១.-**

ការការពារនិងការរំលោភលើពាណិជ្ជនាមត្រូវបានចែងដូចខាងក្រោម :

ក- ទោះជាច្បាប់ ឬបទបញ្ញាទាំងឡាយចែងអំពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជនាមក៏ដោយ ក៏នាមទាំងនោះត្រូវបានការពារប្រឆាំងនឹងទង្វើមិនស្របច្បាប់របស់ភាគីទីបី ទោះមុនការចុះបញ្ជី ឬគ្មានការចុះបញ្ជីក៏ដោយ ។

ខ- ការប្រើប្រាស់ពាណិជ្ជនាមជាបន្តបន្ទាប់ដោយភាគីទីបី ទោះបីជាពាណិជ្ជនាម ឬម៉ាក ឬជាម៉ាកសមូហភាព ឬការប្រើប្រាស់ណាមួយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំត្រូវចាត់ទុកជាមិនស្របច្បាប់ ។

## ជំពូកទី ៧

## អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

**មាត្រា ២២.-**

អំពើនៃការប្រកួតប្រជែងណាដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ ។

**មាត្រា ២៣.-**

ទង្វើទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកថាបានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ :

ក- ការបង្កើតឱ្យមានការភាន់ច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

ខ- ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះសហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

គ- ការបញ្ជាក់ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជ-កម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំអំពីប្រភេទ ដំណើរការផលិត លក្ខណៈភាពសមស្របសំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ ។

## ជំពូកទី ៨

## ការរំលោភនិងវិធានការដោះស្រាយ

**មាត្រា ២៤.-**

ដោយផ្អែកតាមមាត្រា ១២ ខាងលើ ការរំលោភលើម៉ាកគឺជាការប្រព្រឹត្តដែលទាក់ទងទៅនឹងមាត្រា ១១ នៃច្បាប់នេះ ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាកដែល

បានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពុំមានការយល់ព្រមពីម្ចាស់ម៉ាក ។

មាត្រា ២៥.-

ការប្រើប្រាស់នូវសញ្ញាដូចឬប្រហាក់ប្រហែល ដែលធ្វើឱ្យភាន់ច្រឡំទៅនឹងម៉ាកល្បីដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ :

ក- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលដូចឬប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ។

ខ- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលមិនដូចឬមិនប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនឹងទំនិញឬសេវានោះបញ្ជាក់នូវការពាក់ព័ន្ធរវាងទំនិញនិងសេវានោះជាមួយនឹងម្ចាស់នៃម៉ាកល្បី ហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បីអាចនឹងត្រូវខូចខាតដោយការប្រើប្រាស់នោះ ។

មាត្រា ២៦.-

ការប្រើប្រាស់នូវសញ្ញាដែលដូចឬប្រហាក់ប្រហែលនឹងម៉ាកល្បីដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលនឹងទំនិញឬសេវានៃម៉ាកល្បីនោះ ។

មាត្រា ២៧.-

តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណ តុលាការអាចចេញនូវសេចក្ដីសម្រេចបណ្ដោះអាសន្នមួយដើម្បីទប់ស្កាត់ការរំលោភ ការដែលនឹងមានការ

វិលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ និងសម្រេចឱ្យសងការខូចខាត ហើយផ្តល់នូវដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យជួសជុលនូវសំណងដីជាក់លាក់មួយ ប៉ុន្តែបើម្ចាស់ម៉ាក បានបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន ។

មាត្រា ២៨.-

តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬជនណាមួយដែលមានការពាក់ព័ន្ធដូចជា សមាគម ឬសហជីពនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ តុលាការអាចសំរេចឱ្យមានការជួសជុលសំណង ចំពោះករណីនៃការប្រកួតប្រជែងមិនស្មោះត្រង់ដូចមានចែងនៅក្នុងមាត្រា ២២ និងមាត្រា ២៣ ។

## ជំពូកទី ៩

## វិធានការបណ្តោះអាសន្ន

មាត្រា ២៩.-

តាមសំណើរបស់អ្នកប្តឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធ ។

មាត្រា ៣០.-

នៅពេលចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបានចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលភស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវ ៖

ក- ភស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថា ដើមចោទគឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្ដឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះ អាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។

ខ- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយនិងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

**មាត្រា ៣១.-**

នៅពេលដែលវិធានការបណ្ដោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយ អំពីសេចក្ដីសម្រេចស្ដីពីការចាត់វិធានការបណ្ដោះអាសន្ននោះ ។

**មាត្រា ៣២.-**

នៅពេលដែលវិធានការបណ្ដោះអាសន្ន ត្រូវបានដាក់ចេញតាមមាត្រា ៣០ និងមាត្រា ៣១ ចុងចម្លើយអាចដាក់ពាក្យបណ្ដឹងទៅតុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញក្នុងរយៈពេល ១៥ ( ដប់ប្រាំ ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ។ តុលាការត្រូវផ្ដល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ព័ន្ធ ហើយត្រូវពិនិត្យវិធានការនោះឡើងវិញនិងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់ ។

**មាត្រា ៣៣.-**

ក្នុងករណីដើមចោទ នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្ដោះអាសន្នហើយ ឬនៅ ក្នុងរយៈពេលមួយសមស្របដែលកំណត់ដោយតុលាការនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ពុំបានផ្ដួចផ្ដើមបន្តសំណុំរឿងបណ្ដឹងដែលនាំដល់សេចក្ដីសម្រេចអំពីអង្គសេចក្ដីនៃករណី

តុលាការត្រូវលុបនូវវិធានការបណ្តោះអាសន្ននោះចោលវិញ ដោយផ្អែកតាមសំណើរបស់ចុងចម្លើយ ។

មាត្រា ៣៤.-

ក្នុងករណីដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោលវិញ ឬក្នុងករណីដែលតុលាការសម្រេចនូវអង្គសេចក្តីនៃករណីតាមដំណាក់ការជំរះក្តីស្របតាមមាត្រា ៣៣ តាមការផ្តួចផ្តើមរបស់ដើមចោទ ប៉ុន្តែបែរជាគ្មានការរំលោភ ឬការគំរាមរំលោភវិញ ដោយយោងតាមសំណើរបស់ចុងចម្លើយ តុលាការត្រូវសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្របចំពោះការខូចខាតនានាដែលកើតមានឡើងដោយការអនុវត្តនូវវិធានការបណ្តោះអាសន្ននោះ ។

## ជំពូកទី ១០

## វិធានការឃាត់ទុកនៅច្រកព្រំដែន

មាត្រា ៣៥.-

ម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយអាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យល្បាទុកនូវការធ្វើបែបបទទំនិញណាដែលសង្ស័យថាមានម៉ាកក្លែងក្លាយដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

មាត្រា ៣៦.-

ពាក្យបណ្តឹងទាំងឡាយដែលបានលើកនៅក្នុងមាត្រា ៣៥ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវអមដោយ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ។

ខ- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹងនិងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន ។

គ. ការរៀបរាប់ពីល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផង ប្រសិនបើមានសំណូមពរ ។

ឃ. ឈ្មោះនិងអាសយដ្ឋានរបស់អ្នកប្តឹងនិងតំណាងរបស់គេដែលត្រូវ រៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ ។

ង. លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹង នោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ ។

ច. កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង តាមមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នក ប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុក សម្រាប់ពិចារណានៅពេលក្រោយ ។

**មាត្រា ៣៨.-**

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតដែលកំណត់ ដោយអនុក្រឹត្យ មានសិទ្ធិស្នើឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានាដែលមាន តំលៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ សម្រាប់ការពារអ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬ ម្ចាស់ទំនិញនិងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃ ប្រាក់កក់នេះត្រូវបានកំណត់តាមរបៀបនិងបែបបទមួយដែលមិនត្រូវឱ្យរារាំងដល់ការ អនុវត្តនីតិវិធីនេះដោយមិនសមហេតុផល ។

**មាត្រា ៣៩.-**

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងក្នុងមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង ។ ការព្យួរទុក នេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូងនិងក្នុងរយៈពេលដែលបានពន្យារមិនលើសពី

១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅអ្នកនាំចូលនិងអ្នកប្តឹងអំពីការឃួរទុកនូវការធ្វើបែបបទទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការឃួរទុកនេះផង ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងពីឈ្មោះនិងអាស័យដ្ឋាននៃអ្នកប្តឹងដល់អ្នកនាំចូលផងដែរ ។

## មាត្រា ៤០.-

ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដែលអ្នកប្តឹងបានទទួលនូវពត៌មានអំពីការឃាត់ទំនិញ ប្រសិនបើរដ្ឋបាលគយនិងរដ្ឋាករបានទទួលនូវពត៌មានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីមិនត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវមិនបានអនុវត្តនូវវិធានការបណ្តោះអាសន្ន ដើម្បីពន្យារការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែងតែក្នុងករណីដែលល័ក្ខខ័ណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព ។

ក្នុងករណីសមស្រប រយៈពេលនេះអាចត្រូវពន្យារ ១០ (ដប់) ថ្ងៃទៀតនៃថ្ងៃធ្វើការ ។

ប្រសិនបើចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញមានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយដើម្បីសម្រេចនៅក្នុងរយៈពេលមួយសមស្របថា តើវិធានការនេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល ។

## មាត្រា ៤១.-

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធមានសិទ្ធិសម្រេចឱ្យអ្នកប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញនិងអ្នកទទួលទំនិញនូវសំណងសមស្របចំពោះការខូចខាតរបស់គេដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទំនិញដូចមានចែងក្នុងមាត្រា ៣៩ ។ ក្នុងករណីភាគីណាមួយមិនយល់ព្រមតាមសេចក្តីសម្រេចនោះភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ ។

មាត្រា ៤២.-

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញពិនិត្យទំនិញដែលបានឃុំទុកតាមបែបបទគយ ដូចមានចែងក្នុងមាត្រា ៣៩ និងដកយកនូវគំរូដើម្បីពិនិត្យសាកល្បងនិងវិភាគ ក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថាទំនិញនោះពាក់មាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដែលទំនិញត្រូវបានបញ្ជាក់ឱ្យដឹងថាជាទំនិញពាក់មាកក្លែងក្លាយ រដ្ឋបាលគយនិងរដ្ឋាករអាចជូនពត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះនិងអាសយដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួលនិងបរិមាណទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចផ្តល់ទៅឱ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះ ឬនូវពត៌មានដែលមាន ឬឯកសារដែលទាក់ទងទៅនឹងការនាំចូលឬនាំចេញនូវទំនិញប្រហាក់ប្រហែលពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះតាមសំណូមពររបស់ម្ចាស់សិទ្ធិ ។

មាត្រា ៤៣.-

រដ្ឋបាលគយនិងរដ្ឋាករអាចឃុំទុកនូវការផ្ញើបែបបទទំនិញដែលពាក់មាកក្លែងក្លាយ ដែលខ្លួនបានពិនិត្យឃើញមានភស្តុតាងជាលើកដំបូងថា កំពុងតែមានឬអាចនឹងមានការនាំចូលនូវទំនិញប្រភេទនេះ ។

មាត្រា ៤៤.-

រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅឱ្យម្ចាស់សិទ្ធិ អំពីទីកន្លែងនិងថ្ងៃដែលឃុំទុកនូវការផ្ញើបែបបទរបស់គយ ហើយរដ្ឋបាលគយនិងរដ្ឋាករក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្តល់នូវពត៌មានទាំងឡាយដែលអាចជាជំនួយក្នុងការអនុវត្តនូវអំណាចរបស់ខ្លួនផងដែរ ។

មាត្រា ៤៥.-

ដោយអនុលោមទៅនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ

អាជ្ញាធរសាធារណៈនិងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយដោយសមស្រប នៅពេលដែលសកម្មភាពទាំងនោះត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់ ។

មាត្រា ៤៦.-

រដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈសេចក្ដីសម្រេចរបស់តុលាការមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះ ។ រដ្ឋបាលគយនិងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឱ្យនៅក្រោមនីតិវិធីផ្សេងទៀតរបស់គយឡើយ ។

មាត្រា ៤៧.-

ទំនិញពាក់ម៉ាកក្លែងក្លាយដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលនៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរអាចស្ថិតនៅក្រៅការអនុវត្តនៃច្បាប់នេះ ។

## ជំពូកទី ១១

## ការប្ដូរម្ចាស់កម្មសិទ្ធិ

មាត្រា ៤៨.-

តាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្ដូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះបញ្ជី និងចុះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។ ការប្ដូរបែបនេះនឹងមិនមានអានុភាព ចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

មាត្រា ៤៩.-

ការប្ដូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកសមូហភាព តម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន ។

**មាត្រា ៥០.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃពាណិជ្ជនាម ត្រូវធ្វើឡើងដោយការផ្ទេរសហគ្រាសទាំងមូល ឬមួយផ្នែកហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥១.-**

ការប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីម៉ាកត្រូវចាត់ទុកជាមោឃៈ ប្រសិនបើម៉ាកនោះទំនងជាមានលក្ខណៈបោកបញ្ឆោត ឬបណ្តាលឱ្យមានការភាន់ច្រឡំ ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របដើម្បីគោលបំណងនៃទំនិញ ឬសេវាដែលម៉ាកនោះបម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ។

**មាត្រា ៥២.-**

កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយពាក់ព័ន្ធនឹងម៉ាកដែលបានចុះបញ្ជីរួចហើយ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីដែលត្រូវរក្សាការសម្ងាត់ចំពោះខ្លឹមសារនៃកិច្ចសន្យានោះ ប៉ុន្តែត្រូវចុះបញ្ជីនិងចុះផ្សាយនូវពត៌មានដែលពាក់ព័ន្ធ ។ កិច្ចសន្យាអាជ្ញាប័ណ្ណនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយរហូតដល់ការចុះបញ្ជីនោះត្រូវបានធ្វើរួចជាស្ថាពរ ។

## ជំពូកទី ១២
## ការកាន់កាប់បញ្ជីម៉ាក

**មាត្រា ៥៣.-**

ក្រសួងពាណិជ្ជកម្មមានតួនាទីបំពេញការកិច្ចដែលទាក់ទងទៅនឹងនីតិវិធីដើម្បីធ្វើការចុះបញ្ជីម៉ាក និងដើម្បីធ្វើការគ្រប់គ្រងម៉ាកដែលបានចុះបញ្ជីរួចហើយ ដូចបានបញ្ជាក់នៅក្នុងច្បាប់នេះនិងនៅក្នុងបទបញ្ញាទាំងឡាយ ។

**មាត្រា ៥៤.-**

ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចកាន់កាប់និងចុះបញ្ជីម៉ាក ។ ម៉ាកសមូហភាពនឹងត្រូវចុះបញ្ជីនៅក្នុងផ្នែកពិសេសមួយនៃបញ្ជីម៉ាក ។ គ្រប់ការកត់ត្រាដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

ជនណាក៏ដោយក៏អាចមានសិទ្ធិសុំមើលបញ្ជីម៉ាកបានដែរ ហើយអាចដកស្រង់ចេញពីបញ្ជីនោះនូវពត៌មានផ្សេងៗ ដែលស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជា ។

**មាត្រា ៥៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពនៅក្នុងព្រឹត្តិប័ត្រផ្លូវការនូវគ្រប់ការចុះបញ្ជី ការចុះបញ្ជីសាឡើងវិញ ការបដិសេធ ការលុបម៉ាកចេញពីបញ្ជីនិងការងារផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៦.-**

តាមប្រការទាំងឡាយនៃបទបញ្ជា មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវកំហុសផ្សេងៗនៅក្នុងការកត់ត្រាដែលបានធ្វើឡើង ដោយអនុលោមតាមច្បាប់នេះ ឬតាមបទបញ្ជាទាំងឡាយ ។

នៅពេលទទួលសំណើជាលាយលក្ខណ៍អក្សរហើយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថាជាការត្រឹមត្រូវដើម្បីធ្វើដូច្នោះ មន្ត្រីកាន់កាប់បញ្ជីអាចបន្តពេលវេលាសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកនូវចំណាត់ការណាមួយតាមច្បាប់នេះ និងតាមបទបញ្ជាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធនិងតាមល័ក្ខខ័ណ្ឌដែលមន្ត្រីកាន់កាប់បញ្ជីដាក់បញ្ជាឱ្យ ។ ការបន្តនេះអាចត្រូវយល់ព្រម ទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

**មាត្រា ៥៧.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់នូវឱកាសសម្រាប់សវនាការដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួនមុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិ ដែលបានប្រគល់ឱ្យដោយច្បាប់នេះនិងដោយបទបញ្ញត្តិទាំងឡាយប្រឆាំងចំពោះភាគីនោះ ។

## ជំពូកទី ១៣

## ភ្នាក់ងារ

**មាត្រា ៥៨.-**

ក្នុងករណីដែលលំនៅឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៩.-**

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ១៤

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

**មាត្រា ៦០.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្មដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះ ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានគំនាស់ណាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

មាត្រា ៦១.-

នៅក្នុងច្បាប់នេះ :

**-ចំណាត់ថ្នាក់អន្តរជាតិ** មានន័យថា ចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងនីស ដែលចែងអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាកម្មសម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៥៧ ដែលបានកែសម្រួលនៅពេលចុងក្រោយ

**-អនុសញ្ញាទីក្រុងប៉ារីស** មានន័យថា អនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្ដីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ដែលបានកែសម្រួលនៅពេលចុងក្រោយ

**-កាលបរិច្ឆេទអាទិភាព** មានន័យថា ពេលវេលានៃការស្នើសុំមុនគេដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទទួលនូវសិទ្ធិអាទិភាព ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស

**-បទបញ្ជា** មានន័យថា ប្រកាសឬសេចក្ដីណែនាំដែលចេញដោយក្រសួងពាណិជ្ជកម្ម

**-ទំនិញដែលពាក់ម៉ាកក្លែងក្លាយ** មានន័យថា ទំនិញទាំងឡាយរួមទាំងសំបកវេចខ្ចប់ផងដែលមានម៉ាកដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវទាក់ទងនៅនឹងទំនិញនោះដោយគ្មានការអនុញ្ញាត ឬមិនអាចសំគាល់បាននូវលក្ខណៈខុសគ្នាពីទិដ្ឋភាពសំខាន់ៗនៃម៉ាក និងដែលរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកស្របច្បាប់ក្រោមច្បាប់នៃប្រទេសនាំចូល ។

## ជំពូកទី ១៥

## ទោសប្បញ្ញត្តិ

មាត្រា ៦២.-

សេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម អាចជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយភាគីជំទាស់ណាមួយ ហើយបណ្ដឹងតវ៉ានេះត្រូវធ្វើក្នុង

# ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ...៦០.ប្រ.ក....វស

# ប្រកាស
# ស្តីពី
# ការបញ្ចប់ជាបន្ទាន់នូវរាល់សកម្មភាព ដែលរំលោភបំពានលើ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០១៩៦/ ០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៣០៣/ ០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## <u>សម្រេច</u>

**<u>ប្រការ</u> ១.-**

**ស្នាដៃ** ជាផលិតផលខាងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬឧបករណ៍ កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**<u>ប្រការ</u> ២.-**

**អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

សិទ្ធិប្រហាក់ប្រហែល គឺសិទ្ធិអ្នកសំដែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពផ្សព្វផ្សាយ ។

**អង្គភាពផ្សព្វផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ប្រការ ៣.-**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង- ការសម្តែងសៀក និងការសម្តែងកាយវិការ ។

ច- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ- ស្នាដៃសោតទស្សន៍ ។

ជ- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូន្យរូប ឬសិល្បៈអនុវត្ត ។

ឈ- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នា នឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ហានលេខា ឬវិទ្យាសាស្ត្រនានា ។

ឋ-កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធាន ដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឌ- ផលិតផលថ្នៃកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**ប្រការ ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កើតស្នាដៃដូចមានចែងក្នុងប្រការពាខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិ លើស្នាដៃ ហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃរបស់ខ្លួន ។

**ប្រការ ៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលនូវសិទ្ធិស្របច្បាប់លើស្នាដៃដូចមានចែងក្នុងប្រការពាខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃនោះ ។

**ប្រការ ៦.-**

ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពដូចតទៅ ÷

ក-ការផលិត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃដោយគ្មានការអនុញ្ញាតពីម្ចាស់

ខ-ការក្លែងបន្លំ ក្នុងការផលិត ឬការផលិតឡើងវិញនូវស្លាកដែលរំលោភបំពានលើម្ចាស់កម្មសិទ្ធិ ។

គ-ការនាំចូលនូវផលិតផលនៃស្លាកពីបរទេសដើម្បីធ្វើអាជីវកម្ម ឬបង្កើតស្លាកបន្លំដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ឃ-ការនាំចេញនូវស្លាក ដើម្បីធ្វើអាជីវកម្មដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

**ប្រការ ៧.-**

ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៣ រាល់អំពើល្មើសដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**ប្រការ ៨.-**

ខុទ្ទកាល័យ អគ្គនាយកដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ គ្រប់អង្គភាពចំណុះក្រសួង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្តក្រុង ទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិ.ក ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

នរោត្តម . បុប្ផាទេវី

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងព័ត៌មាន
- ក្រសួងឧស្សាហកម្ម
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួង

"ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខ:** ១១២ ប្រក.............

# ប្រកាស
# ស្ដីពី
# អង្គភាពគ្រប់គ្រងសិទ្ធិរួម

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ/នស/រកត/០៩០១៣ចុះថ្ងៃទី២១ខែធ្នូឆ្នាំ២០១៣ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ប្រកាសឲ្យប្រើច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ២៨អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រង ទទួលស្គាល់ និងត្រួតពិនិត្យការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដើម្បី÷

- ការពារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅបរទេស
- ធានាការធ្វើអាជីវកម្មស្របច្បាប់លើស្នាដៃអ្នកនិពន្ធ និង ម្ចាស់សិទ្ធិប្រហាក់ប្រហែល
- លើកទឹកចិត្តនិងជំរុញការបង្កើតស្នាដៃថ្មីៗ ក្នុងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី ក្នុងន័យអភិវឌ្ឍវិស័យឧស្សាហកម្មវប្បធម៌
- ចូលរួមលើកកម្ពស់វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច
- បំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក លើវិស័យកម្មសិទ្ធិបញ្ញា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចតទៅ÷

- អង្គភាពគ្រប់គ្រងសិទ្ធិរួម សំដៅដល់អង្គភាពដែលជាតំណាងឲ្យអ្នកនិពន្ធ ម្ចាស់សិទ្ធិ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល ក្នុងការការពារ និងគ្រប់គ្រងសិទ្ធិ បេតិកភណ្ឌ និងសិទ្ធិសីលធម៌
- កិច្ចសន្យាអាជ្ញាបណ្ណ សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាង អ្នកប្រើប្រាស់ស្នាដៃ និងអង្គភាពគ្រប់គ្រងសិទ្ធិរួម
- អ្នកប្រើប្រាស់ស្នាដៃ សំដៅដល់អ្នកដែលប្រើប្រាស់ស្នាដៃ ដើម្បីស្វែងរក ផលប្រយោជន៍
- ទីតាំងធ្វើអាជីវកម្មលើស្នាដៃ សំដៅដល់ទីកន្លែងប្រើប្រាស់ស្នាដៃ ឬកន្លែង ប្រកបអាជីវកម្មផ្សេងៗ។

**ប្រការ៤.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួម បង្កើតឡើងដោយអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលមានសញ្ជាតិខ្មែរ។

អង្គភាពនេះមានមុខងារ តួនាទី កាតព្វកិច្ចការពារនិងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ ជំនួសមុខឲ្យសមាជិកខ្លួនចំពោះមុខច្បាប់។

ភារកិច្ចនៃអង្គភាពនេះមានជាអាទិ៍៖

- ផ្តល់កិច្ចសន្យាអាជ្ញាបណ្ណឲ្យប្រើប្រាស់ស្នាដៃ
- ប្រមូលលាភការពីទីតាំងធ្វើអាជីវកម្មលើស្នាដៃសមាជិករបស់ខ្លួន និងបែងចែកលាភការ ជូនសមាជិកខ្លួនតាមលក្ខន្តិកៈរបស់អង្គភាព

- ដោះស្រាយវិវាទដែលទាក់ទងលើការប្រើប្រាស់ស្នាដៃ
- ការពារស្នាដៃរបស់សមាជិកខ្លួន
- ធ្វើតារាងកំណត់អត្រាតម្លៃនៃការប្រើប្រាស់ស្នាដៃដែលទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធ្វើបញ្ជីគណនេយ្យប្រកបដោយតម្លាភាព
- បង្កើតនីតិវិធី និងយន្តការដើម្បីគ្រប់គ្រង និងតាមដានការប្រើប្រាស់ស្នាដៃ
- ដឹកនាំការងាររដ្ឋបាលប្រចាំថ្ងៃតាមជំនាញនីមួយៗរបស់អង្គភាព
- បង្កើតលក្ខន្តិកៈសម្រាប់អង្គភាពឲ្យសមស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា។

រាល់ការធ្វើអាជីវកម្មលើស្នាដៃរបស់សមាជិកខ្លួននៅបរទេស អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវសហការជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួម ឬអង្គភាពដែលមានប្រភេទប្រហាក់ប្រហែលនៅបរទេស ដើម្បីប្រមូល បែងចែកលាភការ និងការពារផលប្រយោជន៍ផ្សេងៗទៀតជូនសមាជិករបស់ខ្លួន។

**ប្រការ៥.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវប្រតិបត្តិតាមលក្ខន្តិកៈរបស់ខ្លួន។ ការបង្កើតសាខា ការផ្លាស់ប្តូរទីតាំង ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ការកែសម្រួលរចនាសម្ព័ន្ធរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវជូនដំណឹងមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៦.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួមបង្កើតឡើង ដើម្បីគ្រប់គ្រងលើសិទ្ធិមួយ ឬច្រើនដូចខាងក្រោម៖

- សិទ្ធិផលិតឡើងវិញនូវស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ
- សិទ្ធិបោះពុម្ពផ្សាយស្នាដៃ
- សិទ្ធិផលិតបន្ត
- សិទ្ធិសម្តែងស្នាដៃនាដកម្ម
- សិទ្ធិផ្សព្វផ្សាយជាសាធារណៈ
- សិទ្ធិចែកចាយជាសាធារណៈ

អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយភ្ជាប់មកជាមួយនូវលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព។/

**ប្រការ៧.-**

ការដាក់ពាក្យស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវធ្វើនៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៨.-**

រយៈពេលនៃការទទួលស្គាល់ ឬមិនទទួលស្គាល់ការស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម មានរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌនៃការស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រេចទទួលស្គាល់ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសំណុំឯកសារកែតម្រូវរួច។

ការទទួលស្គាល់អង្គភាពគ្រប់គ្រងសិទ្ធិរួម មានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ និងអាចបន្តសុពលភាពរយៈពេល២ (ពីរ)ឆ្នាំម្តង។

**ប្រការ៩.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវកំណត់លក្ខខណ្ឌនៃការសុំចូលជាសមាជិកដូចខាងក្រោម÷

អ្នកនិពន្ធ ម្ចាស់សិទ្ធិ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល មានសញ្ជាតិខ្មែរ ឬជនបរទេសដែលមានលំនៅដ្ឋាន ឬការិយាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃដាក់តំកល់នៅក្នុងអង្គភាពគ្រប់គ្រងសិទ្ធិរួម។

**ប្រការ១០.-**

ប្រភពថវិការបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមមានជាអាទិ៍÷

- ថវិកាពីការប្រមូលលាភការក្នុងការប្រើប្រាស់ស្នាដៃ
- ជំនួយពីសប្បុរសជន ដៃគូអភិវឌ្ឍន៍ ឬរាជរដ្ឋាភិបាលនិង
- ប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត។

អង្គភាពគ្រប់គ្រងសិទ្ធិរួមប្រើប្រាស់ប្រភពថវិកាខាងលើ ដើម្បីចំណាយលើការរៀបចំនិងការប្រព្រឹត្តទៅ ឬការចំណាយផ្សេងៗទៀតរបស់អង្គភាពស្របតាមលក្ខន្តិកៈអង្គភាព។

**ប្រការ១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលត្រូវការប្រើប្រាស់ស្នាដៃណាមួយរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវសុំការអនុញ្ញាតពីអង្គភាពគ្រប់គ្រងសិទ្ធិរួមនោះ។ អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវផ្តល់ការអនុញ្ញាតប្រើប្រាស់ស្នាដៃ ប្រសិនបើអ្នកប្រើប្រាស់យល់ព្រមបង់លាភការទៅតាមអត្រាតម្លៃសេវានិងលក្ខខណ្ឌដែលបានកំណត់របស់អង្គភាព។ ការអនុញ្ញាតនេះ ត្រូវធ្វើជាកិច្ចសន្យា

ត្រូវកំណត់ពីប្រភេទនៃការប្រើប្រាស់ស្នាដៃ ចំនួនស្នាដៃ ទីកន្លែង និងពេលវេលាជាដើម។ កិច្ចសន្យាតម្រូវឲ្យអ្នកប្រើប្រាស់ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរស្តីពីការផ្លាស់ប្តូរទីកន្លែង ឬពេលវេលាមកឲ្យអង្គភាពគ្រប់គ្រងសិទ្ធិរួមជាមុន ដើម្បីធ្វើការពិភាក្សាឡើងវិញ។

ការប្រើប្រាស់ស្នាដៃនៅកន្លែងធ្វើអាជីវកម្ម ត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអង្គភាពគ្រប់គ្រងសិទ្ធិរួម។ ក្នុងករណីល្មើស ម្ចាស់អាជីវកម្មត្រូវទទួលទោសតាមច្បាប់។

**ប្រការ១២.-**

រាល់ករណីវិវាទដែលកើតឡើងរវាងអង្គភាពគ្រប់គ្រងសិទ្ធិរួម ជាមួយសមាជិក ឬជាមួយអ្នកប្រើប្រាស់ស្នាដៃ ភាគីនីមួយៗមានសិទ្ធិស្នើសុំមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជួយសម្របសម្រួលមុននឹងឈានទៅដល់តុលាការ។

**ប្រការ១៣.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវផ្ញើរបាយការណ៍ប្រចាំឆមាស និងរៀងរាល់ដំណាច់ឆ្នាំមកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីវាយតម្លៃអំពីសុចរិតភាពការងារ និងតម្លាភាពរបស់អង្គភាព។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានតួនាទីត្រួតពិនិត្យរាល់សកម្មភាពគ្រប់អង្គភាពគ្រប់គ្រងសិទ្ធិរួមក្នុងគោលបំណងធានានូវសុក្រឹត្យភាពនៃការអនុវត្តមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនក្រោមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល លក្ខន្តិកៈរបស់អង្គភាព និងបទដ្ឋានគតិយុត្តផ្សេងៗក្នុងករណីមានភាពមិនប្រក្រតីណាមួយ។

**ប្រការ១៤.-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចធ្វើការបញ្ឈប់ការទទួលស្គាល់ ឬធ្វើការផ្អាកជាបណ្តោះអាសន្ននៃដំណើរការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមណាមួយ ក្នុងករណីមានភាពមិនប្រក្រតីកើតឡើងនៅក្នុងអង្គភាព ឬបានអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិជាធរមាន។

ដំណើរការប្រព្រឹត្តទៅជាថ្មីឡើងវិញនៃអង្គភាពគ្រប់គ្រងសិទ្ធិរួមបាន លុះត្រាតែការស៊ើបអង្កេតភាពមិនប្រក្រតីដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបិទបញ្ចប់ និងទទួលបាននូវការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសារជាថ្មី។

អង្គភាពគ្រប់គ្រងសិទ្ធិរួមអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានដោយស្នើសុំមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីពិនិត្យនិងសម្រេច។

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាកម្មវត្ថុនៃបណ្តឹងទៅតុលាការ។

**ប្រការ១៥.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៦.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្តត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ភឿង-សកុណា**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨

# សេចក្តីសម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.** -

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលហៅកាត់ថា គ.ក.ប ។

**មាត្រា ២.** -

អនុក្រឹត្យនេះ មានគោលបំណង ជំរុញ ធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិតែមួយ និងពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ ផ្សព្វផ្សាយ និង អនុវត្តច្បាប់ និង បទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានាឱ្យមានភាពរលូន ស្របតាមការសន្យា របស់ព្រះរាជាណាចក្រកម្ពុជា នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហការទទួល និង ប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ពីអង្គការអន្តរជាតិ និង ប្រទេសនានា ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី ២

## សមាសភាព និង ភារកិច្ច

**មាត្រា ៣.** -

គ.ក.ប មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| - តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - តំណាង ក្រសួងព័ត៌មាន | សមាជិក |
| - តំណាង ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ | សមាជិក |
| - តំណាង ក្រសួងសុខាភិបាល | សមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| - តំណាង ក្រសួង បរិស្ថាន | សមាជិក |

២

| | |
|---|---|
| - តំណាង ក្រសួងយុត្តិធម៌ | សមាជិក |
| - តំណាង ក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| - តំណាង ក្រសួងទេសចរណ៍ | សមាជិក |

**មាត្រា ៨. –**

គ.ក.ប មានភារកិច្ចដូចតទៅ ៖

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការ ទ្វេភាគី ឬពហុភាគី លើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស និង អង្គការអន្តរជាតិនានា
- សម្របសម្រួលឱ្យមានភាពរលូនលើរាល់ការងារ ដែលទាក់ទងដល់កម្មសិទ្ធិបញ្ញា រវាងក្រសួងពាក់ព័ន្ធ
- សហការជំរុញការរៀបចំសេចក្តីព្រាងច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា និងក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា
- ទទួល និង ប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធ នឹង វិស័យកម្មសិទ្ធិបញ្ញា ពីបណ្តាប្រទេស និង អង្គការអន្តរជាតិនានា
- សហការជាមួយក្រសួងពាក់ព័ន្ធ ផ្សព្វផ្សាយច្បាប់ និង បទប្បញ្ញត្តិនានា ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា ដល់មហាជន មន្ត្រីអនុវត្តច្បាប់ និង សិស្ស និស្សិត តាមគ្រឹះស្ថានអប់រំសិក្សា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និង បញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា
- សហការសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និង អនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីពិចារណាអំពីអត្ថប្រយោជន៍ ចំណុចខ្លាំង ចំណុចខ្សោយ មុននឹងរាយការណ៍សុំការយល់ព្រមចូលជាសមាជិកពីប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល យ៉ាងតិច១ឆ្នាំម្តង និងតាមដំណាក់កាលនីមួយៗ ។

**មាត្រា ៩. –**

សមាជិកនៃ គ.ក.ប ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ។

គ.ក.ប មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងពាណិជ្ជកម្ម ដើម្បីសម្រួលការងារ ។

**មាត្រា ៦.** –

គ.ក.ប មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម÷

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ប្រធាន
- មន្ត្រីបច្ចេកទេស នៃក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា ៣ សមាជិក

លេខាធិការដ្ឋាន គ.ក.ប មានទីតាំងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម និង អាចប្រើប្រាស់មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៧.** –

គ.ក.ប មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់ក្រសួងពាណិជ្ជកម្ម ។ ប្រភពធនធាន និង ថវិការបស់ គ.ក.ប រួមមាន÷

- ថវិកាជាតិ
- ហិរញ្ញប្បទានសហប្រតិបត្តិការ ពីក្នុង និង ក្រៅប្រទេស ដែលផ្តល់ដោយអង្គការអន្តរជាតិ និង ដៃគូអភិវឌ្ឍន៍នានា ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៨.** –

សេចក្តីសម្រេចលេខ ១៦ សសរ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា និង បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ